WFP World Food Programme wfp.org

National Institute of Statistics
Ministry of Planning
CAMBODIA

# របាយការណ៍វិភាគនិន្នាការ សន្តិសុខស្បៀងអាហារ និងអាហារូបត្ថម្ភ

# អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ឆ្នាំ២០១៤ - ២០១៩/២០

**ខែកក្កដា ឆ្នាំ២០២២**

## មាតិកា


បញ្ជីរូបភាព ........................................ ៤
បញ្ជីតារាង ........................................ ៥
ពាក្យកាត់ និងវាក្យសព្ទ ........................................ ៦
បុព្វកថា ........................................ ៧
អារម្ភកថា ........................................ ៨
សេចក្តីសង្ខេប ........................................ ៩
សាវតា ........................................ ៩
សន្តិសុខស្បៀងអាហារ ........................................ ៩
ភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច ........................................ ១០
ការបរិភោគស្បៀងអាហារ ........................................ ១០
គុណភាពនៃរបបអាហារ ........................................ ១១
ការអនុវត្តអាហារូបត្ថម្ភ ........................................ ១២
ឥរិយាបទដោះស្រាយស្បៀងអាហារតាមបែបអវិជ្ជមាន ........................................ ១២
ការពិនិត្យឱ្យស៊ីជម្រៅ ........................................ ១២
សន្និដ្ឋាន ........................................ ១៣
១. សេចក្តីផ្តើម ........................................ ១៥
១.១. សាវតា ........................................ ១៥
១.២. គោលបំណង ........................................ ១៦
២. វិធីសាស្រ្ត ........................................ ១៦
៣. សន្តិសុខស្បៀងអាហារ និងអាហារូបត្ថម្ភ ........................................ ១៩
៣.១.សន្ទស្សន៍សន្តិសុខស្បៀង ........................................ ១៩
៣.២.លទ្ធភាពផ្នែកសេដ្ឋកិច្ចដើម្បីបំពេញតម្រូវការចាំបាច់ ........................................ ២២
៣.៣.ការចំណាយលើស្បៀងអាហារ ........................................ ២៤
៣.៤. ភាពញឹកញាប់នៃការបរិភោគស្បៀងអាហារ ........................................ ២៦
៣.៥.ពិន្ទុនៃការបរិភោគស្បៀងអាហារ ........................................ ២៩
៣.៦.ពិន្ទុរបបអាហារចម្រុះ ........................................ ៣៣

៣.៧.ពិន្ទុនៃការបរិភោគស្បៀងអាហារ-អាហារូបត្ថម្ភ ........ ៣៦
៣.៨.យុទ្ធសាស្ត្រដោះស្រាយផ្អែកលើការកាត់បន្ថយស្បៀងអាហារ ........ ៣៩
៣.៩.យុទ្ធសាស្ត្រដោះស្រាយបញ្ហាផ្អែកលើសកម្មភាពរស់នៅ ........ ៤២
៣.១០.ពិន្ទុនៃភាពអត់ឃ្លានតាមគ្រួសារ ........ ៤៤
៤. សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ........ ៤៥
សន្តិសុខស្បៀង ........ ៤៥
ភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច ........ ៤៥
ការបរិភោគស្បៀងអាហារ ........ ៤៦
គុណភាពរបបអាហារ ........ ៤៧
ការអនុវត្តចំពោះអាហាររូបត្ថម្ភ ........ ៤៧
ឥរិយាបទដោះស្រាយបញ្ហាតាមបែបអវិជ្ជមាន ........ ៤៨
ពិនិត្យវិភាគឱ្យស៊ីជម្រៅ ........ ៤៨
សេចក្តីសន្និដ្ឋាន ........ ៤៨
ឧបសម្ព័ន្ធ: សង្ខេបសូចនាករនៃសន្តិសុខស្បៀង និងអាហារូបត្ថម្ភ(FSN) ........ ៥០
១.១ សន្ទស្សន៍សន្តិសុខស្បៀង ........ ៥១
១.១ សន្ទស្សន៍សន្តិសុខស្បៀង(ត) ........ ៥២
១.២ លទ្ធភាពផ្នែកសេដ្ឋកិច្ចដើម្បីបំពេញតម្រូវការចាំបាច់ (ECMEN) ........ ៥៣
១.៣ ការចំណាយនិងការរួមចំណែកនៃចំណាយ ........ ៥៥
១.៤ ភាពញឹកញាប់នៃការប្រើប្រាស់អាហាររបស់គ្រួសារ ........ ៦៤
១.៥ ពិន្ទុប្រើប្រាស់អាហាររបស់គ្រួសារ ........ ៧០
១.៦ ភាពចម្រុះនៃរបបអាហាររបស់គ្រួសារ ........ ៧២
១.៧ ការប្រើប្រាស់អាហារ - អាហារូបត្ថម្ភរបស់គ្រួសារ ........ ៧៤
១.៨ យុទ្ធសាស្ត្រដោះស្រាយលើស្បៀងអាហារ ........ ៨០
១.៩ យុទ្ធសាស្ត្រដោះស្រាយពឹងផ្អែកលើរបរចិញ្ចឹមជីវិត ........ ៨៦
១.១០ ភាពអត់ឃ្លានតាមគ្រួសារ ........ ៨៨

## បញ្ជីរូបភាព


រូបភាព ១: ទំហំសំណាកគំរូនៃការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចឆ្នាំ២០១៩/២០ ........................................ ១៧
រូបភាព ២: ក្របខណ្ឌនៃការវិភាគសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ........................................ ១៩
រូបភាព ៣: ភាគរយនៃគ្រួសារបែងចែកលំអិតតាមក្រុមសន្តិសុខស្បៀង ........................................ ២១
រូបភាព ៤: ភាគរយនៃគ្រួសារបែងចែកលំអិតតាមក្រុមសន្តិសុខស្បៀងនិងតាមឆ្នាំ........................................ ២២
រូបភាព ៥: និន្នាការជាភាគរយនៃគ្រួសារបែងចែកតាមក្រុមនៃសមត្ថភាពសេដ្ឋកិច្ចឆ្នាំ២០១៤-២០១៩/២០ ... ២៣
រូបភាព ៦: និន្នាការជាភាគរយនៃគ្រួសារបែងចែកលំអិតតាមក្រុមនៃសមត្ថភាពសេដ្ឋកិច្ច ........................................ ២៤
រូបភាព ៧: និន្នាការជាមធ្យមភាគនៃចំណាយប្រើប្រាស់លើម្ហូបអាហារឆ្នាំ២០១៤-២០១៩/២០ ........................................ ២៥
រូបភាព ៨: ភាគរយនៃគ្រួសារបែងចែកតាមក្រុមចំណែកនៃការចំណាយលើម្ហូបអាហារនិងឆ្នាំ ........................................ ២៥
រូបភាព ៩: ភាគរយនៃគ្រួសារបែងចែកលំអិតតាមក្រុមចំណែកនៃការចំណាយលើម្ហូបអាហារ ........................................ ២៦
រូបភាព ១០: ចំនួនថ្ងៃជាមធ្យមនៃការប្រើប្រាស់ម្ហូបអាហារទាំង៩ក្រុមមុខទំនិញ ........................................ ២៩
រូបភាព ១១: ភាគរយនៃគ្រួសារបែងចែកតាមក្រុមចំណាយលើស្បៀងអាហារ និងឆ្នាំ ........................................ ៣២
រូបភាព ១២: ភាគរយនៃគ្រួសារបែងចែកលំអិតតាមក្រុមចំណាយលើស្បៀងអាហារឆ្នាំ២០១៤-២០១៩/២០. ៣៣
រូបភាព ១៣: ភាគរយនៃគ្រួសារដែលមានរបបអាហារចម្រុះ ទាប មធ្យម និងខ្ពស់ ចែកតាមឆ្នាំ........................................ ៣៤
រូបភាព ១៤: ភាគរយនៃគ្រួសារដែលមានរបបអាហារចម្រុះ ទាប មធ្យម និងខ្ពស់ ចែកលំអិតតាមក្រុម ........................................ ៣៥
រូបភាព ១៥: និន្នាការជាមធ្យមពិន្ទុនៃគ្រួសារមានរបបអាហារចម្រុះចែកលំអិតតាមក្រុមឆ្នាំ២០១៤-២០១៩/២០...៣៥
រូបភាព ១៦: ភាគរយនៃគ្រួសារបានប្រើប្រាស់វីតាមីន A ប្រូតេអ៊ីន និងអាហារសម្បូរជាតិដែក........................................ ៣៧
រូបភាព ១៧: ភាគរយនៃគ្រួសារបានប្រើប្រាស់វីតាមីន A ប្រូតេអ៊ីន........................................ ៣៨
រូបភាព ១៨: ភាគរយនៃគ្រួសារបានប្រើប្រាស់អាហារមានប្រូតេអ៊ីនច្រើន ........................................ ៣៨
រូបភាព ១៩: ភាគរយនៃគ្រួសារបានប្រើប្រាស់អាហារមានជាតិដែក ........................................ ៣៩
រូបភាព ២០: និន្នាការនៃសន្ទស្សន៍យុទ្ធសាស្ត្រដោះស្រាយចែកតាមក្រុមលំអិតឆ្នាំ២០១៤-២០១៩/២០ ........ ៤០
រូបភាព ២១: ភាគរយនៃគ្រួសារប្រើប្រាស់យុទ្ធសាស្ត្រដំណោះស្រាយ ឆ្នាំ២០១៤-២០១៩/២០........................................ ៤១
រូបភាព ២២: ភាគរយនៃគ្រួសារប្រើប្រាស់យុទ្ធសាស្ត្រដំណោះស្រាយទទួលទានអាហារយ៉ាងតិចមួយមុខ ....... ៤១
រូបភាព ២៣: ភាគរយនៃគ្រួសារប្រើប្រាស់យុទ្ធសាស្ត្រដោះស្រាយតាមជីវភាពរស់នៅ........................................ ៤៣
រូបភាព ២៤: ភាគរយនៃគ្រួសាប្រើប្រាស់យុទ្ធសាស្ត្រដោះស្រាយបែងចែកលំអិតតាមក្រុម........................................ ៤៣
រូបភាព ២៥: ភាគរយនៃគ្រួសារប្រើប្រាស់យុទ្ធសាស្ត្រដោះស្រាយបែងចែកលំអិតតាមយុទ្ធសាស្ត្រ ........................................ ៤៤
រូបភាព ២៦: ភាគរយនៃគ្រួសារបែងចែកតាមក្រុមភាពអត់ឃ្លាន ........................................ ៤៤
រូបភាព ២៧: ភាគរយនៃគ្រួសារបែងចែកលំអិតតាមក្រុមភាពអត់ឃ្លាន........................................ ៤៥

# បញ្ជីតារាង

តារាង ១: ទំហំសំណាកគំរូនៃការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ច ២០១៤-២០១៧ និង ២០១៩/២០ តាមតំបន់ទីប្រជុំជន និងតំបន់ជនបទ ........ ១៨
តារាង ២: ការបញ្ចូលគ្នាសន្ទស្សន៍សន្តិសុខស្បៀង(CARI) ........ ២០
តារាង ៣: ខ្សែបន្ទាត់ភាពក្រីក្រជាតិ ពីវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ (រៀល/ម្នាក់/ថ្ងៃ) ........ ២២
តារាង ៤: ចំណុចដែលបានកំណត់លទ្ធភាពសេដ្ឋកិច្ចដើម្បីបំពេញតម្រូវការចាំបាច់........ ២៣
តារាង ៥: ក្រុមមុខទំនិញម្ហូបអាហារ និងក្រុមសំណាកគំរូ ព្រមទាំងមេគុណក្រុមមុខទំនិញ ........ ៣០
តារាង ៦: ចំណុចកម្រិតសម្រាប់ពិន្ទុនៃការបរិភោគស្បៀងអាហារ (ស្តង់ដារ និងកែតម្រូវ) ........ ៣១

# ពាក្យកាត់ និងខាក្យសព្ទ

| | |
|---|---|
| CARI | វសសសៈ វិធីសាស្ត្ររួមសម្រាប់ការរាយការណ៍សូចនាករនៃសន្តិសុខស្បៀង (Consolidated Approach for Reporting Indicators of Food Security) |
| CSES | អសសកៈ អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា (Cambodia Socio-Economic Survey) |
| DDS | ពិន្ទុរបបអាហារចម្រុះ (Dietary diversity score) |
| ECMEN | លទ្ធភាពផ្នែកសេដ្ឋកិច្ចដើម្បីបំពេញតម្រូវការចាំបាច់ (Economic capacity to meet essential needs) |
| FCG | ចំណែកក្រុមប្រើប្រាស់ស្បៀងអាហារ (Food consumption group) |
| FCS | ពិន្ទុនៃការបរិភោគស្បៀងអាហារ (Food consumption score |
| FCS-N | ពិន្ទុនៃការបរិភោគស្បៀងអាហារ-អាហារូបត្ថម្ភ (Food consumption score-nutrition) |
| FES | ចំណែកភាគចំណាយលើម្ហូបអាហារ (Food expenditure share) |
| HHS | ពិន្ទុនៃភាពអត់ឃ្លានរបស់គ្រួសារ (Household hunger score) |
| IDPoor | អត្តសញ្ញាណកម្មគ្រួសារក្រីក្រ (Identification of Poor Households) |
| LCSI | សន្ទស្សន៍យុទ្ធសាស្ត្រដោះស្រាយសម្រាប់ជីវភាពរស់នៅ (Livelihood Coping Strategy Index) |
| NIS | វិទ្យាស្ថានជាតិស្ថិតិ (National Institute of Statistics) |
| rCSI | សន្ទស្សន៍យុទ្ធសាស្ត្រដោះស្រាយតាមការកាត់បន្ថយរបបអាហារ (reduced Coping Strategy Index) |
| WFP | កម្មវិធីស្បៀងអាហារពិភពលោករបស់អង្គការសហប្រជាជាតិ(World Food Programme) |

# បុព្វកថា

ខ្ញុំមានសេចក្តីសោមនស្សរីករាយក្នុងការបង្ហាញ និងចែករំលែកនូវរបាយការណ៍ស្តីពីការវិភាគនិន្នាការសន្តិសុខស្បៀង នៅក្នុងប្រទេសកម្ពុជា។ របាយការណ៍នេះ គឺជាលទ្ធផលនៃកិច្ចសហការយ៉ាងជិតស្និទ្ធរវាងវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ នៃរាជរដ្ឋាភិបាលកម្ពុជា និងកម្មវិធីស្បៀងអាហារពិភពលោករបស់អង្គការសហប្រជាជាតិ(WFP)។

របាយការណ៍នេះបង្ហាញពីលទ្ធផលនៃការវិភាគស្ថិតិដែលបានចងក្រងឡើងដោយក្រុមវិភាគទិន្នន័យសន្តិសុខស្បៀង ពីវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ និង ពីផ្នែកវិភាគភាពងាយរងគ្រោះនិងការធ្វើផែនទី របស់កម្មវិធីស្បៀងអាហារពិភពលោក (WFP)។ ប្រភពទិន្នន័យសំខាន់ៗដែលប្រើប្រាស់សម្រាប់ការវិភាគរបាយការណ៍នេះគឺបានមកពីទិន្នន័យអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា (ឬហៅកាត់ថា CSES) ឆ្នាំ២០១៤-២០១៩/២០។

របាយការណ៍នេះ ផ្តល់នូវទិដ្ឋភាពទូទៅនៃសន្តិសុខស្បៀងអាហារនៅក្នុងប្រទេសកម្ពុជា តាមរយៈការវាយតម្លៃសូចនាករលើការប្រើប្រាស់ឬការទទួលទានម្ហូបអាហារ ភាពសម្បូរបែបនៃរបបអាហារ យុទ្ធសាស្ត្រដោះស្រាយនានា និងការចំណាយដែលបានប្រមូលនៅកម្រិតគ្រួសារ ព្រមទាំងសមាសធាតុសូចនាករសន្តិសុខស្បៀងអាហារ ដូចជាវិធីសាស្ត្ររួមបញ្ចូល សូចនាករសម្រាប់រាយការណ៍សន្តិសុខស្បៀង។

ខ្ញុំសង្ឃឹមថា ព័ត៌មានដែលបានបង្ហាញក្នុងរបាយការណ៍នេះ ជាឯកសារយោងដ៏សំខាន់ ដើម្បីបំពេញសេចក្តីត្រូវការរបស់អ្នកធ្វើគោលនយោបាយ អ្នករៀបចំផែនការយុទ្ធសាស្ត្រ និងអ្នកស្រាវជ្រាវនានា ក្នុងការរៀបចំតាមដានពិនិត្យ និងអនុវត្តកម្មវិធី គម្រោង និងយុទ្ធសាស្ត្រស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅទូទាំងប្រទេសកម្ពុជា។

ការចងក្រងរបាយការណ៍នេះ នឹងមិនអាចធ្វើទៅបានទេ ប្រសិនបើគ្មានការចូលរួម និងផ្តល់ជាតុចូលពីក្រុមវិភាគទិន្នន័យសន្តិសុខស្បៀង និងការណែនាំដ៏ខ្ពង់ខ្ពស់ពីឯកឧត្តម លោកជំទាវ លោក លោកស្រីថ្នាក់ដឹកនាំរបស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ និងកម្មវិធីស្បៀងអាហារពិភពលោក (WFP)។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះគណៈគ្រប់គ្រង និងមន្ត្រីបច្ចេកទេសនៃស្ថាប័នទាំងពីរក្នុងការចងក្រងរបាយការណ៍ដ៏មានសារៈសំខាន់នេះ ទទួលបានជោគជ័យជាប្រយោជន៍សាធារណៈ។

**តំណាង និងនាយិកាកម្មវិធី**
**ស្បៀងអាហារពិភពលោកប្រចាំនៅកម្ពុជា**

**ក្លែរ ភូណាន់**

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងផែនការ**

**កិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន**

រាជធានីភ្នំពេញ
ខែកក្កដា ឆ្នាំ២០២២

# អារម្ភកថា

ការវិភាគស្ថិតិ និងការសរសេររបាយការណ៍នេះ ត្រូវបានធ្វើឡើងដោយក្រុមវិភាគទិន្នន័យសន្តិសុខស្បៀងពីវិទ្យាស្ថានជាតិស្ថិតិ និងក្រុមវិភាគទិន្នន័យភាពងាយរងគ្រោះ និងការធ្វើផែនទីរបស់កម្មវិធីស្បៀងអាហារពិភពលោករបស់អង្គការសហប្រជាជាតិ។ ក្រុមការងារទទួលបានគុណប្រយោជន៍យ៉ាងច្រើនពីការសហការគ្នារវាងវិទ្យាស្ថានជាតិស្ថិតិ និង កម្មវិធីស្បៀងអាហារពិភពលោក (WFP) ជាមួយនឹងការគាំទ្រដ៏រឹងមាំ និងការណែនាំពីថ្នាក់ដឹកនាំ និងមន្ត្រីពាក់ព័ន្ធផ្សេងៗទៀតនៃអង្គភាពស្ថាប័នទាំងពីរ។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះកិច្ចខិតខំប្រឹងប្រែងទាំងអស់ ដើម្បីធ្វើឱ្យរបាយការណ៍នេះសម្រេចបានជោគជ័យជាប្រយោជន៍សាធារណៈ។

## វិទ្យាស្ថានជាតិស្ថិតិ

លោកជំទាវ **ហង់ លីណា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ
លោក **ផន ចិន្តា** អគ្គនាយករង វិទ្យាស្ថានជាតិស្ថិតិ
លោក **វ៉ឹន ជី** អគ្គនាយករង វិទ្យាស្ថានជាតិស្ថិតិ
ឯកឧត្តម **ណោ វ៉ាន់ឌី** ប្រធាននាយកដ្ឋានស្ថិតិសេដ្ឋកិច្ច វិទ្យាស្ថានជាតិស្ថិតិ និងជាទីប្រឹក្សាក្រសួងផែនការ
លោក **គឹម ណេត** ប្រធាននាយកដ្ឋានស្ថិតិសង្គមកិច្ច វិទ្យាស្ថានជាតិស្ថិតិ
លោក **ប៉ូ ម៉ៅ** អនុប្រធាននាយកដ្ឋានស្ថិតិសង្គមកិច្ច វិទ្យាស្ថានជាតិស្ថិតិ
លោក **អឿ សុផល** អនុប្រធាននាយកដ្ឋានគណនេយ្យជាតិ វិទ្យាស្ថានជាតិស្ថិតិ
លោក **សូ តូនៃរ** អនុប្រធាននាយកដ្ឋានស្ថិតិសេដ្ឋកិច្ច វិទ្យាស្ថានជាតិស្ថិតិ
លោក **ចាវ ភាវ** ប្រធាននាយកដ្ឋានគ្រប់គ្រងទិន្នន័យ អភិវឌ្ឍន៍កម្មវិធី និងបច្ចេកវិទ្យា វិទ្យាស្ថានជាតិស្ថិតិ
លោក **លី សុផានិត** អនុប្រធាននាយកដ្ឋានស្ថិតិសេដ្ឋកិច្ច វិទ្យាស្ថានជាតិស្ថិតិ
កញ្ញា **ហង្ស ផល្លី** អនុប្រធាននាយកដ្ឋានស្ថិតិសេដ្ឋកិច្ច វិទ្យាស្ថានជាតិស្ថិតិ
កញ្ញា **ជួន សុគន្ធា** អនុប្រធាននាយកដ្ឋានស្ថិតិសេដ្ឋកិច្ច វិទ្យាស្ថានជាតិស្ថិតិ
លោក **ខៀវ ខេមរិន្ទ** អនុប្រធាននាយកដ្ឋានស្ថិតិសង្គមកិច្ច វិទ្យាស្ថានជាតិស្ថិតិ
លោកស្រី **យិត វីយ៉ា** អនុប្រធាននាយកដ្ឋានស្តង់ដារ និងវិភាគស្ថិតិ វិទ្យាស្ថានជាតិស្ថិតិ
កញ្ញា **ចាន់ សេរី** អនុប្រធាននាយកដ្ឋានស្ថិតិសង្គមកិច្ច វិទ្យាស្ថានជាតិស្ថិតិ

## កម្មវិធីស្បៀងអាហារពិភពលោកនៃអង្គការសហប្រជាជាតិ

លោក **ប៊ីនចាមីន ស្គូល** (Benjamin Scholz) ប្រធានផ្នែកស្រាវជ្រាវ វិភាគ និងតាមដាន (RAM)

លោក **ឡុង យ៉ាវ** មន្ត្រីវិភាគ និង ធ្វើផែនទី ភាពងាយរងគ្រោះ (VAM)

លោក **ជួរ ចាន់វិបុល** សហការីកម្មវិធីជាន់ខ្ពស់ ផ្នែកវិភាគនិងធ្វើផែនទី Senior Programme Associate, VAM,

លោក **ហួយ វណ្ណារ៉េត** សហការីកម្មវិធីផ្នែកវិភាគនិងធ្វើផែនទី Programme Associate, VAM

# សេចក្តីសង្ខេប

## សាវតា

**របាយការណ៍វិភាគនិន្នាការសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** គឺផ្អែកលើកិច្ចខិតខំប្រឹងប្រែងរួមគ្នារវាងវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ(MOP) និងកម្មវិធីស្បៀងអាហារពិភពលោករបស់អង្គការសហប្រជាជាតិ(WFP) ។ របាយការណ៍នេះផ្អែកលើការវិភាគទិន្នន័យ នៃការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា (អ.ស.ស.ក) ជាច្រើនជុំ (ពីឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៩/២០) ដែលបានចងក្រងឡើងដោយក្រុមវិភាគទិន្នន័យ សន្តិសុខស្បៀង និងអាហារូបត្ថម្ភរបស់វិទ្យាស្ថានជាតិស្ថិតិ និងក្រុមវិភាគទិន្នន័យភាពងាយរងគ្រោះនិងការធ្វើផែនទី របស់កម្មវិធីស្បៀងអាហារពិភពលោក។

ចាប់ពីខែកក្កដា ឆ្នាំ ២០១៩ ដល់ខែមិថុនា ឆ្នាំ២០២០ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ បានធ្វើការប្រមូលទិន្នន័យលើកទី១៧ នៃអង្កេត អ.ស.ស.ក ក្នុងចំណោមគ្រួសារសំណាកគំរូចំនួន១០,០៨០គ្រួសារនៅទូទាំង២៥រាជធានីខេត្តនៃប្រទេសកម្ពុជាដែលផ្តល់បច្ចុប្បន្នភាពអំពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភរបស់ប្រជាជនកម្ពុជា។ នៅពេលជំងឺកូវីដ១៩(COVID-19) បានចាប់ផ្តើមរីករាលដាលនៅក្នុងប្រទេសកម្ពុជា ចាប់ពីខែមីនា ឆ្នាំ២០២០ ទិន្នន័យដែលមានក្នុងការអង្កេត អ.ស.ស.ក ២០១៩/២០ តំណាងឱ្យទិន្នន័យគ្រាគោលដ៏ល្អមួយសម្រាប់វាស់វែងពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ (FSN) របស់គ្រួសារដែលមានផលប៉ះពាល់ដោយជំងឺរាតត្បាតជាលើកដំបូង។ នៅឆ្នាំ២០២០/២១ កម្មវិធីស្បៀងអាហារពិភពលោក (WFP) បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលអនុវត្តន៍ជាក់ស្តែងលើការវិភាគទិន្នន័យស្ថិតិសន្តិសុខស្បៀង និងអាហារូបត្ថម្ភចំនួនពីរលើកសម្រាប់មន្ត្រី វិទ្យាស្ថានជាតិស្ថិតិសំខាន់ៗដើម្បីធ្វើការវិភាគផលិតទិន្នន័យសូចនាករ FSN ផ្អែកលើសំណុំទិន្នន័យអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ពីឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៩/២០ ដែលទទួលបានលទ្ធផលដូចបានបង្ហាញនៅក្នុងរបាយការណ៍នេះ។

## សន្តិសុខស្បៀងអាហារ

វិធីសាស្ត្ររួមបញ្ចូលសូចនាករ សម្រាប់រាយការណ៍សន្តិសុខស្បៀងអាហារ(CARI) គឺជាវិធីសាស្ត្រមួយដើម្បីប្រមូលផ្តុំសូចនាករសន្តិសុខស្បៀងផ្សេងៗគ្នា រួមទាំងការដាក់ពិន្ទុ ការទទួលទានស្បៀងអាហារ (FCS) សន្ទស្សន៍យុទ្ធសាស្ត្រដោះស្រាយបញ្ហាខ្វះខាតស្បៀងអាហារផ្អែកលើការកាត់បន្ថយស្បៀងអាហារ និងការប្រកបរបរចិញ្ចឹមជីវិត (rCSI និង LCSI) និងសូចនាករលទ្ធភាពសេដ្ឋកិច្ចដើម្បីបំពេញតម្រូវការចាំបាច់ (ECMEN) នៅក្នុងសន្ទស្សន៍តែមួយ ដើម្បីរាយការណ៍អំពីស្ថានភាពសន្តិសុខស្បៀងអាហារទាំងមូល។ លទ្ធផលនៃវិធីសាស្ត្ររួមបញ្ចូលសូចនាករសម្រាប់រាយការណ៍សន្តិសុខស្បៀងអាហារ (CARI) បានបង្ហាញថាប្រហែល ៧៥% នៃគ្រួសារនៅក្នុងប្រទេសកម្ពុជា មានសន្តិសុខស្បៀងអាហារ និង២៥%មានភាពងាយរងគ្រោះនឹង**អសន្តិសុខស្បៀងអាហារនៅក្នុងឆ្នាំ២០១៩/២០។** ការរកឃើញ ដោយវិធីសាស្ត្របញ្ចូលសូចនាករសម្រាប់រាយការណ៍សន្តិសុខស្បៀងអាហារ (CARI) បង្ហាញឱ្យឃើញថា **អសន្តិសុខស្បៀងនៅកម្ពុជា គឺបណ្តាលមកជាចម្បងពីភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច។** ទោះបីជាគ្រួសារភាគច្រើនមានពិន្ទុនៃការទទួលទានស្បៀងអាហារដែលអាចទទួលយកបាន និងមិនប្រើប្រាស់យុទ្ធសាស្ត្រដោះស្រាយដែលបង្កគ្រោះថ្នាក់ក៏ដោយ ក៏សមាមាត្រអ្នករកប្រាក់ចំណូលបានតិចតួចនៅមានច្រើនហើយលទ្ធភាព សេដ្ឋកិច្ចសម្រាប់បំពេញតម្រូវការចាំបាច់របស់ពួកគេនៅមានកម្រិតនៅឡើយ។ គ្រួសារទាំងនេះអាចធ្លាក់ចូលទៅក្នុងអសន្តិសុខ ស្បៀងអាហារយ៉ាងងាយក្នុងគ្រាមានវិបត្តិ ឬគ្រោះមហន្តរាយ ដូចជាក្នុងអំឡុងពេលទឹកជំនន់តាមរដូវកាល ឬជះឥទ្ធិពលប៉ះពាល់ប្រាក់ចំណូលដែលទាក់ទងនឹងការរាតត្បាតនៃជំងឺកូវីដ-១៩ (COVID-១៩) និងថ្លៃម្ហូបអាហារកើនឡើងនៅពេលក្រោយវិបត្តិអ៊ុយក្រែនជាដើម។

## ភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច

ទោះបីជាមានភាពប្រសើរឡើងចាប់តាំងពីឆ្នាំ២០១៧ក៏ដោយ ក៏នៅមានគ្រួសារកម្ពុជា២៣% ពុំមានសមត្ថភាពឬលទ្ធភាពផ្នែកសេដ្ឋកិច្ចដើម្បីបំពេញតម្រូវការចាំបាច់របស់ពួកគេនៅឡើយនៅក្នុងឆ្នាំ២០១៩/២០ ដោយសារការចំណាយរបស់ពួកគេនៅទាបជាងខ្សែបន្ទាត់នៃភាពក្រីក្រថ្នាក់ជាតិ។ គ្រួសារកម្ពុជាប្រមាណជា ៣% ពុំមានសមត្ថភាពផ្នែកសេដ្ឋកិច្ចដើម្បីបំពេញតម្រូវការស្បៀងអាហាររបស់ពួកគេទេ ដោយសារការចំណាយរបស់ពួកគេនៅទាបជាងខ្សែបន្ទាត់នៃភាពក្រីក្រស្បៀងអាហារថ្នាក់ជាតិនៅឡើយ ហើយតួលេខនេះ គឺកើនខ្ពស់ជាងឆ្នាំ២០១៧ ជាង២ចំណុចភាគរយ។ សមាមាត្រនេះកើនឡើងដល់៥% ក្នុងចំណោមគ្រួសារដែលមានសមាជិកពិការ គ្រួសារក្រីក្រ និងគ្រួសារដែលមានស្ត្រីជាមេគ្រួសារ។

ការចំណាយលើការប្រើប្រាស់ស្បៀងអាហារត្រូវបានប្រើប្រាស់ជាតំណាងដើម្បីប៉ាន់ប្រមាណពីភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ចរបស់គ្រួសារចំពោះសន្តិសុខស្បៀងអាហារ និងកង្វះអាហារូបត្ថម្ភ។ ជាមធ្យម គ្រួសារកម្ពុជាចំណាយប្រហែលពាក់កណ្តាល (៤៨,៧%) នៃប្រាក់ចំណូលរបស់ពួកគេលើស្បៀងអាហារ និងគ្រួសារដែលត្រូវបានចាត់ថ្នាក់ក្នុង អត្តសញ្ញាណគ្រួសារក្រីក្រ (ID Poor) ចំណាយលើស្បៀងអាហាររហូតដល់ ៦០%។ បញ្ហានេះគឺមានសារៈសំខាន់ ដោយសារគ្រួសារដែលមានចំណែកនៃការចំណាយលើការប្រើប្រាស់ស្បៀងអាហារខ្ពស់ អាចមើលឃើញ លទ្ធភាពរបស់ពួកគេក្នុងការបំពេញតម្រូវការស្បៀងអាហារ និងអាហារូបត្ថម្ភត្រូវបានសម្របសម្រួលក្នុងគ្រាមានវិបត្តិនៃតម្លៃស្បៀងអាហារ ឬ ប្រាក់ចំណូល ដូចករណីក្នុងអំឡុងពេលជំងឺរាតត្បាត COVID-១៩ នៅក្នុងឆ្នាំ ២០២០/២០២១ និងអំឡុងពេលថ្លៃម្ហូបអាហារហក់ឡើងនៅឆ្នាំ២០២២។ ខណៈពេលដែលភាគរយនៃការចំណាយលើស្បៀងអាហារនៅទាប នៅក្នុងតំបន់ទីប្រជុំជន (៤៤% នៅក្នុងទីក្រុងភ្នំពេញ និង ៤៨% នៅក្នុងតំបន់ទីប្រជុំជន) ដែលគ្រួសារមានប្រាក់ចំណូលខ្ពស់ និងប្រាក់ចំណូលដែលអាចប្រើប្រាស់បានច្រើនជាងក្តីក៏ចំនួននៃការចំណាយគឺខ្ពស់ជាង ដោយសារតម្លៃម្ហូបអាហារជាទូទៅមានតម្លៃខ្ពស់ជាងនៅក្នុងតំបន់ទីប្រជុំជន។

## ការបរិភោគស្បៀងអាហារ

ជាទូទៅ កម្រិតនៃការបរិភោគស្បៀងអាហាររបស់ប្រជាជនកម្ពុជា ដែលបានគណនាវាស់វែងដោយពិន្ទុនៃការបរិភោគស្បៀងអាហារ(FCS) គឺគ្រប់គ្រាន់សម្រាប់គ្រួសារកម្ពុជា ដោយសារភាគច្រើននៃពួកគេអាចបំពេញតម្រូវការបរិភោគស្បៀងអាហារបានល្អឬដែលអាចទទួលយកបាន ពោលគឺពួកគេ បរិភោគបរិមាណអប្បបរមា និងភាពសម្បូរបែបនៃស្បៀងអាហារ ។

ទោះបីយ៉ាងណាក៏ដោយ ការថយចុះបន្តិចត្រូវបានកត់សម្គាល់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០១៩/២០។ ពិន្ទុនៃការបរិភោគស្បៀងអាហារ(FCS)ជាមធ្យម គឺមានភាពស៊ីគ្នាដែរដោយនៅក្នុងតំបន់ទីប្រជុំជនមានកម្រិតខ្ពស់ជាងនៅតំបន់ជនបទ ដែលបង្ហាញពីលទ្ធភាពទទួលបានស្បៀងអាហារប្រសើរជាង និងខ្ពស់បំផុតនៅក្នុងរាជធានីភ្នំពេញ នៅគ្រប់ឆ្នាំទាំងអស់ (លើកលែងតែឆ្នាំ២០១៥)។ ទន្ទឹមនឹងពិន្ទុនៃការបរិភោគស្បៀងអាហាររបស់គ្រួសារដែលមានស្ត្រីជាមេគ្រួសារមានកម្រិតទាបជាងមធ្យមភាគនៃថ្នាក់ជាតិ នៅគ្រប់ឆ្នាំអង្កេតមុនៗនោះ ពិន្ទុ**ការបរិភោគស្បៀងអាហាររបស់គ្រួសារ ដែលមានស្ត្រីជាមេគ្រួសារក្នុងឆ្នាំ២០១៩/២០ គឺមានមានកម្រិតទាបជាងក្នុងចំណោមគ្រួសារដែលត្រូវបានចាត់ថ្នាក់ក្នុងអត្តសញ្ញាណគ្រួសារក្រីក្រ**។[1]

លទ្ធផលបង្ហាញថា គ្រួសារកម្ពុជាបានបរិភោគស្បៀងអាហារមូលដ្ឋានដែលសំខាន់ជាងគេ (ជាពិសេសអង្ករ) ប្រូតេអ៊ីនក្នុងសាច់សត្វ (ជាពិសេសត្រីទឹកសាប) និងគ្រឿងទេស (ទឹកត្រី ទឹកស៊ីអ៊ីវ។ល។) ជាប្រចាំថ្ងៃ។ នៅក្នុងឆ្នាំ២០១៩/២០ ភាពញឹកញាប់នៃ**ការ បរិភោគស្បៀងអាហារមានជាតិប្រេង/ខ្លាញ់ និងជាតិស្ករបានកើនឡើងគួរឱ្យកត់សម្គាល់** បើធៀបនឹងឆ្នាំមុនៗ

[1] The Identification of Poor Households (“IDPoor”) programme is Cambodia’s national poverty identification programme and official targeting mechanism for programmes that support the poor.

ជាពិសេសនៅក្នុងរាជធានីភ្នំពេញ ដែលអាចបង្កើនហានិភ័យនៃការលើសទម្ងន់ និងជំងឺមិនឆ្លងផ្សេងៗ។ ស្រដៀងគ្នានេះដែរ ទឹកដោះគោ និងផលិតផលទឹកដោះគោត្រូវបានគ្រួសារកម្ពុជា បរិភោគញឹកញាប់ជាងមុនក្នុងឆ្នាំ២០១៩/២០ ជាមួយនឹងការបរិភោគមានកម្រិតខ្ពស់បំផុតនៅក្នុងរាជធានីភ្នំពេញ។ ទោះបីជាគ្រួសារបានទទួលទានផ្លែឈើ ញឹកញាប់ក៏ដោយក៏និន្នាការនៃ **ការបរិភោគបន្លែមានការថយចុះ** ជាពិសេសសម្រាប់បន្លែស្លឹកពណ៌បៃតង។

ទោះបីជាយ៉ាងណាក៏ដោយ ខណៈពេលដែលការបរិភោគត្រី និងសាច់ក្រហមជាមធ្យមក្នុងប្រទេសកម្ពុជា លើសពីគោលដៅនៃរបបអាហារដែលបានណែនាំ ការទទួលទានអាហារ និងសារធាតុចិញ្ចឹមសំខាន់ៗផ្សេងទៀត គឺនៅទាបជាងកម្រិតដែលបានណែនាំ រួមមានដូចជា ក្រុមសណ្តែក (៤% នៃការទទួលទានដែលបានណែនាំ) អាហារគ្រាប់ (៦%) ទឹកដោះគោ និងផលិតផលទឹកដោះគោ ( ១០%) គ្រាប់ធញ្ញជាតិ (១៣%) ផ្លែឈើ (២៤%) និងបន្លែ(៣៩%)[2] ។ នេះបង្ហាញថា ទោះបីជាកម្រិតនៃការបរិភោគស្បៀងអាហារបានល្អ ឬដែលអាចទទួលយកបាន ជាទូទៅក៏ដោយក៏ការសម្រេចបាននូវរបបស្បៀងអាហារដែលមានសុខភាពល្អនៅតែមានកម្រិតទាប និងត្រូវការធ្វើឱ្យប្រសើរឡើងថែមទៀត។

## គុណភាពនៃរបបអាហារ

លទ្ធផលពីការអង្កេត អ.ស.ស.ក (CSES) បញ្ជាក់ថា គុណភាពនៃរបបអាហារកាន់តែយ៉ាប់យ៉ឺនក្នុងឆ្នាំ២០១៩/២០ ដែលបង្ហាញការធ្លាក់ចុះនៃភាពចម្រុះរបស់របបអាហារ និង កង្វះជីវជាតិនៃការទទួលទានមីក្រូសារជាតិសំខាន់ៗ (រួមទាំងវីតាមីន A និងជីវជាតិដែកបានមកពីសាច់សត្វ)។ ខណៈពេលដែលភាពចម្រុះនៃរបបអាហារនៅតែមានកម្រិតខ្ពស់បំផុតនៅក្នុងរាជធានីភ្នំពេញ ដែលក្នុងចំណោម ៤គ្រួសារ គឺមាន១គ្រួសារមាន ភាពចម្រុះនៃរបបអាហារខ្ពស់នោះ ការយ៉ាប់យ៉ឺនជាទូទៅត្រូវបានគេកត់សម្គាល់ឃើញនៅគ្រប់តំបន់ទាំងអស់ចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០១៩/២០ ។

ការវិភាគគុណភាពអាហារូបត្ថម្ភបង្ហាញថា ការបរិភោគស្បៀងអាហារសម្បូរវីតាមីន A និងជីវជាតិដែកបានមកពីសាច់សត្វមានការថយចុះ ជាពិសេសនៅតំបន់ទីប្រជុំជន។ បញ្ហានេះ គឺសំខាន់ដោយសារតែកង្វះមីក្រូសារជាតិដូចជាវីតាមីន A និងជីវជាតិដែក ក្នុងរយៈពេលយូរគឺនាំឱ្យកង្វះអាហារូបត្ថម្ភរ៉ាំរ៉ៃ។ កង្វះមីក្រូសារជាតិប៉ះពាល់ដល់ស្ត្រីជាពិសេសពីព្រោះពួកគេមានតម្រូវការខ្ពស់ក្នុងអំឡុងពេលមានផ្ទៃពោះនិងសម្រាលកូន ហើយកង្វះសារធាតុចិញ្ចឹមទាំងនេះចំពោះស្ត្រី គឺនាំឱ្យទារកកើតមកមានទម្ងន់មិនគ្រប់ និងអាចបណ្តាលឱ្យអត្រាមរណភាពរបស់ កុមារមានកម្រឹតខ្ពស់។

នៅក្នុងឆ្នាំ២០១៩/២០ មានប្រហែលមួយគ្រួសារក្នុងចំណោម៥គ្រួសារ( ១៩,២%)មិនបានទទួលទានអាហារសម្បូរជាតិដែកដែលបានមកពីសាច់សត្វ (ដូចជាត្រី សាច់ បសុបក្សី)ជាប្រចាំនោះទេ ដែលធ្វើឱ្យពួកគេប្រឈមមុខនឹងភាពស្លេកស្លាំង ហើយច្រើនជាងមួយគ្រួសារក្នុងចំណោម៤គ្រួសារ (២៥,៥%) គឺមិនបានទទួលទានអាហារដែលសម្បូរវីតាមីនA ជាប្រចាំ (ដូចជាផ្លែឈើនិងបន្លែពណ៌ទឹកក្រូច) ដែលរំខានដល់ដំណើរការធម្មតានៃប្រព័ន្ធភាពស៊ាំ ការលូតលាស់ និងការអភិវឌ្ឍក៏ដូចជាការបន្តពូជ។

---

[2] https://globalnutritionreport.org/resources/nutrition-profiles/asia/south-eastern-asia/cambodia/#:~:text=Cambodia's%20obesity%20prevalence%20is%20lower,women%20and%207.5%25%20for%20men.

## ការអនុវត្តចំពោះអាហារូបត្ថម្ភ

និន្នាការនៃការអនុវត្តអាហារូបត្ថម្ភបានសង្កេតឃើញចំណុចឈានទៅរកការកើនឡើងនៃការបរិភោគស្បៀងអាហារដែលសម្បូរទៅដោយជាតិខ្លាញ់ និងជាតិស្ករ ដូចជាអាហារកែច្នៃ និងការកែច្នៃលើស ប៉ុន្តែមានការបរិភោគបន្លែតិច មិនសូវញឹកញាប់ដែលជាការអភិវឌ្ឍដែលកំពុងជំរុញឱ្យមានកំណើន "បន្ទុកបីដង" នៃភាពកង្វះអាហារូបត្ថម្ភនៅកម្ពុជា ពោលគឺការកើតឡើងព្រមគ្នានូវភាពកង្វះអាហារូបត្ថម្ភ និងកង្វះមីក្រូសារជាតិជាប់ជាយូរមក រួមជាមួយនឹងការកើននូវការលើសអាហារូបត្ថម្ភក្នុងចំណោមប្រជាជនដូចគ្នា។ ឧទាហរណ៍ សមាមាត្រកុមារដែលមានអាយុក្រោម៥ឆ្នាំ ដែលលើសទម្ងន់ជាច្រើន ក៏មានបញ្ហាក្រេះក្រិនផងដែរ ដែលបង្ហាញពីភាពសម្បូរបែបនៃអាហារដែលបានបរិភោគ ប៉ុន្តែកង្វះសារជាតុចិញ្ចឹមធ្ងន់ធ្ងរ[3]។ សមាមាត្រកុមារដែលមានអាយុក្រោម៥ឆ្នាំជាច្រើននៅតែមានក្រេះក្រិន (កង្វះអាហារូបត្ថម្ភរ៉ាំរ៉ៃ) (២២%) ឬស្គមស្គាំង (កង្វះអាហារូបត្ថម្ភស្រួចស្រាល)(១០%)[4] ។ អត្រាប្រេវ៉ាឡង់នៃការលើសទម្ងន់ និងធាត់ខ្លាំងចំពោះមនុស្សពេញវ័យកំពុងកើនឡើង ហើយត្រូវបានគេព្យាករណ៍ថានឹងកើនឡើងបន្ថែមទៀតនៅក្នុងប៉ុន្មានឆ្នាំខាងមុខនេះ ដោយស្ត្រីនឹងរងផលប៉ះពាល់កាន់តែច្រើន។

ការអង្កេត អ.ស.ស.ក (CSES) បានរកឃើញពីការថយចុះនៃគុណភាពរបបអាហារត្រូវបានឆ្លុះបញ្ចាំងថាប្រទេសកម្ពុជាមានវឌ្ឍនភាពតិចតួចឆ្ពោះទៅរកការសម្រេចបាននូវគោលដៅអាហារូបត្ថម្ភជាសាកលមួយចំនួនរបស់ខ្លួនរួមទាំងការកាត់បន្ថយអត្រាប្រេវ៉ាឡង់នៃភាពស្លេកស្លាំងដែលបន្តប៉ះពាល់ដល់ស្ត្រីក្នុងវ័យបន្តពូជជាងពាក់កណ្តាល(៥១,៥%) និងការស្គមស្គាំងក្នុងវ័យកុមារតូចដែលនៅទ្រឹងចាប់តាំងពីឆ្នាំ២០១៤មក។ នៅក្នុងនោះសមាសភាពនៃរបបអាហារ និងទម្ងន់ខ្លួនប្រាណ គឺជាកត្តាកំណត់ដ៏សំខាន់នៃអាហារូបត្ថម្ភ និងស្ថានភាពសុខភាពរបស់បុគ្គលម្នាក់ៗ ក៏ដូចជាមរណភាពរបស់បុគ្គលម្នាក់ៗផងដែរ។

## ឥរិយាបទដោះស្រាយស្បៀងអាហារតាមបែបអវិជ្ជមាន

ក្នុងពេលខ្វះខាតស្បៀងអាហារ គ្រួសារអាចត្រឡប់ទៅរកយុទ្ធសាស្ត្រដោះស្រាយបែបអវិជ្ជមាន ដើម្បីបំពេញតម្រូវការស្បៀងអាហាររបស់ពួកគេ។ តាមទិន្នន័យបង្ហាញថា ស្ថានភាពយុទ្ធសាស្ត្រដោះស្រាយនៅក្នុងឆ្នាំ២០១៩/២០ នៅតែមិនផ្លាស់ប្តូរចាប់តាំងពីឆ្នាំ២០១៧មក ដោយមានគ្រួសារត្រឹមតែ ២,៥% បានប្រើប្រាស់យុទ្ធសាស្ត្រដោះស្រាយ ផ្អែកលើស្បៀងអាហារ ដូចជាកាត់បន្ថយចំនួនពេលអាហារ ឬបរិមាណអាហារ។ ហើយមានតែគ្រួសារ ២% ប្រើយុទ្ធសាស្ត្រដោះស្រាយផ្អែកលើការប្រកបរបរចិញ្ចឹមជិវិតឬជីវភាពរស់នៅ ដូចជាការខ្ចីប្រាក់ ឬខ្ចីអាហារជាដើម។ គ្រួសារដែលមានមេគ្រួសារជាស្ត្រី និងគ្រួសារអត្តសញ្ញាណកម្មក្រីក្រ ទំនងជាត្រឡប់ទៅរកយន្តការដោះស្រាយបែបអវិជ្ជមានច្រើនជាងគេ។ ទោះជាយ៉ាងណាក៏ដោយក៏ជារឿងសំខាន់ដែលត្រូវចងចាំថា តួលេខទាំងនេះសំដៅទៅលើមុនពេលនៃជំងឺរាតត្បាតកើតឡើង ហើយដែលការទទួលយកយន្តការដោះស្រាយបែបអវិជ្ជមាន បានកើនឡើងគួរឱ្យកត់សម្គាល់ក្នុងអំឡុងពេលពេលនៃការរាតត្បាតរបស់ជំងឺ COVID-១៩។

[3] Ibid.
[4] National Institute of Statistics [Cambodia], Ministry of Health [Cambodia] and ICF. 2022. *Cambodia Demographic and Health Survey 2021–22 Key Indicators Report*.

## ពិនិត្យវិភាគឱ្យស៊ីជម្រៅ

លទ្ធផលវិភាគលំអិតបង្ហាញថា មានភាពខុសគ្នាគួរឱ្យកត់សម្គាល់នៅក្នុងសូចនាករសន្តិសុខស្បៀងអាហារ និងអាហារូបត្ថម្ភ រវាងគ្រួសារដែលរស់នៅក្នុងរាជធានីភ្នំពេញ និង នៅតំបន់ទីប្រជុំជនដទៃទៀត និងជនបទ ។ គិតជាមធ្យម គ្រួសារដែលរស់នៅក្នុងរាជធានីភ្នំពេញ មានលទ្ធភាពទទួលបានស្បៀងអាហារដែលមានជីវជាតិប្រសើរជាងគ្រួសាររស់នៅក្នុងតំបន់ផ្សេងទៀត ដោយសារនៅរាជធានីភ្នំពេញ មានស្បៀងអាហារចម្រុះ និងប្រាក់ចំណូលគ្រួសារខ្ពស់ជាង។ ផ្ទុយទៅវិញគ្រួសារមានមេគ្រួសារជាស្ត្រី និងគ្រួសារមានសមាជិករស់នៅមានពិការភាព កាន់តែមានស្ថានភាពសន្តិសុខស្បៀងនិងអាហារូបត្ថម្ភអាក្រក់ជាងមធ្យមភាគទូទាំងប្រទេសស្ទើរតែគ្រប់សូចនាករទាំងអស់។

គ្រួសារដែលមានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ បានបោះជំហានទៅមុខយ៉ាងខ្លាំងក្នុងអំឡុងពេលប៉ុន្មានឆ្នាំកន្លងមកដែលទាក់ទងនឹងសន្តិសុខស្បៀងអាហារ។ ទោះបីជាយ៉ាងណាក៏ដោយ ខណៈពេលដែលមនុស្សជាច្រើនទទួលទានរបបអាហារដែលមិនមានគម្លាតឆ្ងាយពីមធ្យមភាគថ្នាក់ជាតិទាំងសមាសភាព និងភាពចម្រុះនៃអាហារក៏ដោយ ក៏ពួកគេនៅមានបញ្ហាលើផ្នែកប្រើប្រាស់យុទ្ធសាស្ត្រដោះស្រាយបែបអវិជ្ជមាន និងលទ្ធភាពឬសមត្ថភាពផ្នែកសេដ្ឋកិច្ចនៅមានកម្រិតទាប។ ការរកឃើញបានបង្ហាញថាមាន៣០% នៃគ្រួសារដែលមានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (ID Poor) គឺមានកម្រិតចំណាយនៅក្រោមខ្សែបន្ទាត់ភាពក្រីក្រថ្នាក់ជាតិ ហើយនិងចំណាយប្រមាណ៦០%នៃប្រាក់ចំណូលដែលពួកគេមាន គឺទៅលើស្បៀងអាហារ។ ដូច្នេះពួកគេត្រូវសម្របសម្រួលទៅតាមលទ្ធភាពរបស់ពួកគេក្នុងការបំពេញតម្រូវការចាំបាច់ទាំងអស់ ជាពិសេសនៅក្នុងគ្រានៃប្រាក់ចំណូលធ្លាក់ចុះ ឬ គ្រាដែលមានវិបត្តិថ្លៃស្បៀងអាហារដែលពេលនោះពួកគេអាចត្រូវបានបង្ខំឱ្យផ្តល់អាទិភាពធនធានដែលខ្វះខាតរបស់ពួកគេ។

## សេចក្តីសន្និដ្ឋាន

បន្ទាប់ពីមាននិន្នាការវិជ្ជមានភាគច្រើនក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ទិន្នន័យអង្កេត អ.ស.ស.ក ឆ្នាំ២០១៩/២០ បង្ហាញពីការបញ្ច្រាស់បន្តិចនៅក្នុងសូចនាករសន្តិសុខស្បៀងអាហារ និងអាហារូបត្ថម្ភមួយចំនួននៅក្នុងប្រទេសកម្ពុជា បើប្រៀបធៀបទៅនឹងឆ្នាំ២០១៧ រួមទាំងការបរិភោគស្បៀងអាហារ មានភាពសម្បូរបែបនៃរបបអាហារ និងការទទួលទានមីក្រូសារជាតិ (វីតាមីន A និងជាតិដែកដែលបានមកពីសាច់សត្វ)។ ទោះបីជាយ៉ាងនេះក្តី សន្តិសុខស្បៀងអាហារ ជារួមមានភាពប្រសើរឡើងដោយសារតែមានភាពប្រសើរឡើងគួរឱ្យកត់សម្គាល់ក្នុងចំណោមគ្រួសារមានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងគ្រួសារដែលមានសមាជិកមានពិការភាព។ ទោះជាយ៉ាងណាក៏ដោយក៏មានប្រមាណ ២៥%នៃគ្រួសារកម្ពុជា នៅតែមានភាពងាយរងគ្រោះទៅនឹងអសន្តិសុខស្បៀងអាហារ ដែលភាគច្រើនដោយសារតែសមត្ថភាពផ្នែកសេដ្ឋកិច្ចរបស់ពួកគេនៅទាប បើធៀបទៅនឹងឆ្នាំ២០១៧ ដែលមានអត្រា ២៩%។ នៅតំបន់ជនបទ តួលេខនេះកើនឡើងដល់ ៣០% នៃគ្រួសារ។

ការរកឃើញពីអង្កេត អ.ស.ស.ក ឆ្នាំ២០១៩/២០ អាចជាការបង្ហាញពីភាពលំអៀងនៃការយល់ឃើញយ៉ាងទូលំទូលាយជុំវិញសន្តិសុខស្បៀងអហារ និងអាហារូបត្ថម្ភនៅកម្ពុជា។ ខណៈពេលដែលភាពអត់ឃ្លានជាទូទៅមិនមែនជាការព្រួយបារម្ភ "ភាពអត់ឃ្លានលាក់កំបាំង" ក៏ដោយ ក៏ភាពកង្វះមីក្រូសារជាតិសំខាន់ៗ និងភាពស្គមស្គាំងរបស់កុមារ គឺជាបញ្ហាសុខភាពសាធារណៈដ៏សំខាន់។ ប៉ុន្តែទោះបីជាផលប៉ះពាល់អវិជ្ជមាននៃកង្វះអាហារូបត្ថម្ភលើសុខភាពមនុស្ស ការស្លាប់ និងការវិវឌ្ឍត្រូវបានចងក្រងជាឯកសារយ៉ាងល្អក៏ដោយ ជួនកាលពួកវាអាចមើលមិនឃើញ និងអូសបន្លាយរយៈពេល។ ដូច្នេះហើយរបបអាហារដែលមានសុខភាពល្អ ប្រហែលជាមិនត្រូវបានចាត់ទុកថាជាអាទិភាពមួយដោយ ប្រជាជនកម្ពុជាភាគច្រើននោះទេ

ខណៈដែលអាហារមានសុខភាព ក៏មានតម្លៃថ្លៃដែលគ្រួសារមិនមានលទ្ធភាពទិញ ដូចលទ្ធផលស្តីពីលទ្ធភាពផ្នែកសេដ្ឋកិច្ចបានបង្ហាញ។ ការបង្កើនការវិនិយោគសាធារណៈទៅលើការវិភាគរកភស្តុតាងឬទល្បីករ និងការលើកកម្ពស់ការយល់ដឹងជាសាធារណៈជុំវិញរបបអាហារដែលធ្វើឱ្យមានសុខភាពល្អ និងមានអត្ថប្រយោជន៍របស់វា ក៏ដូចជាជម្រើសឆ្លើយតបតាមតម្រូវការដូចជាការបញ្ចូលមីក្រូសារជាតិទៅក្នុងអង្ករ និងការពង្រីកការការពារ និងការព្យាបាលការស្គមស្គាំង គឺជាតម្រូវការចាំបាច់ដើម្បីឱ្យកម្ពុជាសម្រេចបាននូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាពផ្នែកអាហារូបត្ថម្ភរបស់ខ្លួននៅឆ្នាំ២០៣០។

# ១. សេចក្តីផ្តើម

## ១.១. សាវតា

ផ្នែកវិភាគ និង ធ្វើផែនទីភាពងាយរងគ្រោះ (VAM) នៃកម្មវិធីស្បៀងអាហារពិភពលោករបស់អង្គការសហប្រជាជាតិ (WFP) និងវិទ្យាស្ថានជាតិស្ថិតិ (NIS)នៃក្រសួងផែនការ (MOP) មានប្រវត្តិសហការ និងបទពិសោធន៍យូរមកហើយក្នុងការប្រើប្រាស់ទិន្នន័យអង្កេតថ្នាក់ជាតិ និងជំរឿនប្រជាជនដើម្បីធ្វើការវិភាគស៊ីជម្រៅលើសន្តិសុខស្បៀងអាហារ និងអាហារូបត្ថម្ភក្នុងគ្រួសារ និងផលិតរបាយការណ៍រួមគ្នាសម្រាប់ផ្សព្វផ្សាយ ដោយចាប់ផ្តើម ជាមួយនឹងរបាយការណ៍ស្តីពីការប៉ាន់ប្រមាណភាពក្រីក្រ និងកង្វះអាហារូបត្ថម្ភនៅតាមតំបន់តូច(SAE)នៅកម្ពុជាក្នុងឆ្នាំ១៩៩៩ ។

ក្នុងឆ្នាំ២០១៣ WFP ដោយមានការគាំទ្រផ្នែកបច្ចេកទេសពីសាកលវិទ្យាល័យ Massey ក្នុងប្រទេសញ៉ូសេឡែន និងបានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយ NIS បានធ្វើបច្ចុប្បន្នភាពនៃការសិក្សានៅតាមតំបន់តូចអំពីភាពក្រីក្រ និងកង្វះអាហារូបត្ថម្ភនៅកម្ពុជា ដោយប្រើទិន្នន័យពីការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា (អ ស ស ក) ឆ្នាំ២០០៩ ជំរឿនទូទៅប្រជាជនឆ្នាំ២០០៨ (ជំរឿន ២០០៨) ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា (CDHS) ឆ្នាំ ២០១០ និងការអង្កេតមនុស្សមាត្រកម្ពុជា (CAS) ឆ្នាំ ២០០៨។ របាយការណ៍នេះបានផ្តល់ព័ត៌មានដ៏មានតម្លៃដល់រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ជុំវិញការកំណត់គោលដៅសម្រាប់កម្មវិធីជំនួយសង្គមដែលមានគោលបំណង ដើម្បីកាត់បន្ថយភាពក្រីក្រ អសន្តិសុខស្បៀង និងកង្វះអាហារូបត្ថម្ភ។

ក្នុងឆ្នាំ២០១៣/២០១៤ ក្រុមការងារវិភាគនិងធ្វើផែនទីរបស់ WFP បានសហការជាមួយ NIS ដើម្បីធ្វើសមាហរណកម្មសំណួរស្តីពីការ បរិភោគស្បៀងអាហារ និង យុទ្ធសាស្ត្រដោះស្រាយទៅក្នុងការប្រមូលទិន្នន័យរបស់អង្កេត អ ស ស ក ឆ្នាំ ២០១៤ ហើយសូចនាករទាំងនេះត្រូវបានប្រមូលចាប់តាំងពីពេលនោះមកនៅក្នុងការប្រមូលទិន្នន័យការអង្កេត អ ស ស ក ជាបន្តបន្ទាប់ទាំងអស់ (ក្នុងឆ្នាំ ២០១៥ - ២០១៧, ២០១៩ និង ២០២១)។ ក្រោមក្របខណ្ឌនៃផែនការយុទ្ធសាស្ត្រ(CSP) របស់ WFP ឆ្នាំ២០១៩-២០២៣ MoP និង WFP ក្នុងឆ្នាំ ២០២០ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងភាពជាដៃគូយុទ្ធសាស្ត្រលើការអនុវត្តសកម្មភាពរួមគ្នាសម្រាប់ការវិភាគសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ព័ត៌មាន និងអភិបាលកិច្ច ក្នុងគោលបំណងពង្រឹងសមត្ថភាពថ្នាក់ជាតិ និង ស្ថាប័នថ្នាក់ក្រោមជាតិសម្រាប់ NIS និងអគ្គផែនការ (GDP) នៃក្រសួងផែនការ ។ WFP បានផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដល់ការអង្កេតថ្នាក់ជាតិ និងការវាយតម្លៃថ្នាក់ជាតិ (ដូចជា អ ស ស ក, CDHS, on-demand IDPoor assessment សម្រាប់កម្មវិធីកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ)និងបានផ្តល់ការកសាងសមត្ថភាពដល់ក្រុម NIS លើការប្រមូល និងវិភាគទិន្នន័យសន្តិសុខស្បៀង។

ចាប់ពីខែកក្កដា ឆ្នាំ ២០១៩ ដល់ខែមិថុនា ឆ្នាំ ២០២០ NIS បានធ្វើការប្រមូលទិន្នន័យ លើកទី១៧ នៃការអង្កេត អ ស ស ក ក្នុងចំណោមគ្រួសារចំនួន១០០៨០គ្រួសារ ក្នុងខេត្តចំនួន១៩ក្រុមនៅទូទាំងប្រទេសកម្ពុជា ។ នៅពេលដែល COVID-១៩ បានចាប់ផ្តើមរីករាលដាលនៅក្នុងប្រទេសកម្ពុជា ចាប់ពីខែមីនា ឆ្នាំ២០២០ ទិន្នន័យដែលមានតាមរយៈការអង្កេត អ.ស.ស.ក ជាមូលដ្ឋានទិន្នន័យ គ្រាដើមដ៏ល្អមួយ សម្រាប់វាស់វែងពីផលប៉ះពាល់នៃជំងឺរាតត្បាត លើសន្តិសុខស្បៀងអាហារ និងអាហារូបត្ថម្ភគ្រួសារ[5] ។ ក្នុងឆ្នាំ ២០២០/២០២១ WFP បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលជាក់ស្តែងចំនួនពីរលើកដល់មន្ត្រីសំខាន់ៗរបស់NIS ដើម្បីធ្វើការវិភាគទិន្នន័យជាក់ស្តែងនៃសូចនាករសន្តិសុខស្បៀងអាហារនិងអាហារូបត្ថម្ភលើសំណុំ

[5] As data collection took place from mid-2019 to mid-2020, some indicators may already reflect some degree of socioeconomic impact of the COVID-19 pandemic.

ទិន្នន័យការអង្កេត អ.ស.ស.ក ពីឆ្នាំ ២០១៤ដល់ឆ្នាំ ២០១៧ និងឆ្នាំ ២០១៩។ វិធីសាស្ត្រនិងលទ្ធផលត្រូវបានបង្ហាញនៅក្នុងរបាយការណ៍នេះ ហើយលទ្ធផលរបស់សូចនាករផ្សេងជាច្រើនត្រូវបានបង្ហាញនៅក្នុងឧបសម្ព័ន្ធ។

## ១.២. គោលបំណង

គោលបំណងរួមនៃរបាយការណ៍នេះ គឺដើម្បីវាយតម្លៃស្ថានភាពសន្តិសុខស្បៀងអាហារ និងអាហារូបត្ថម្ភ និងស្ថានភាពងាយរងគ្រោះនៃគ្រួសារកម្ពុជា និងវាយតម្លៃពីនិន្នាការរបស់វាតាមពេលវេលា ដោយផ្អែកលើការប្រមូលទិន្នន័យ ការអង្កេត អ ស ស ក ជាច្រើនលើកចាប់តាំងពីឆ្នាំ ២០១៤។ គោលបំណងជាក់លាក់គឺ៖

១. ដើម្បីធ្វើការវិភាគស្ថានភាពសន្តិសុខស្បៀងអាហារ និងអាហារូបត្ថម្ភរបស់គ្រួសារ តាមរយៈការប៉ាន់ស្មានសូចនាករសំខាន់ៗសម្រាប់៖

- ក. ការបរិភោគស្បៀងអាហារ រួមទាំងពិន្ទុ នៃការបរិភោគស្បៀងអាហារ (FCS)
- ខ. គុណភាពនៃរបបអាហាររួមបញ្ចូលទាំង ពិន្ទុ របបអាហារចម្រុះ (DDS) និងពិន្ទុនៃការបរិភោគស្បៀងអាហារដែលមានអាហារូបត្ថម្ភ(FCS-N)
- គ. ស្ថានភាពសន្តិសុខស្បៀងអាហារ តាមរយៈរួមផ្សំគ្នានៃសូចនាករផ្សេងៗរួមមានសន្ទស្សន៍សន្តិសុខស្បៀង (FSI/CARI) និងពិន្ទុនៃភាពអត់ឃ្លានរបស់គ្រួសារ (HHS)

២. ដើម្បីវិភាគភាពងាយរងគ្រោះរបស់គ្រួសារតាមរយៈសូចនាករ សំខាន់ៗសម្រាប់

ក. ឥរិយាបទដោះស្រាយបញ្ហាស្បៀងអាហារប្រកបដោយភាពអវិជ្ជមាន រួមទាំងយុទ្ធសាស្ត្រដោះស្រាយនានាផ្អែកលើស្បៀងអាហារ និងសន្ទស្សន៍យុទ្ធសាស្ត្រដោះស្រាយតាមការកាត់បន្ថយការបរិភោគស្បៀងអាហារ(rCSI) និងយុទ្ធសាស្ត្រដោះស្រាយផ្អែកលើការប្រកបរបរចិញ្ចឹមជិវិតឬជីវភាពរស់នៅ និងសន្ទស្សន៍យុទ្ធសាស្ត្រដោះស្រាយតាមការប្រកបរបរចិញ្ចឹមជិវិតឬជីវភាពរស់នៅ។

ខ.ភាពងាយរងគ្រោះផ្អែកសេដ្ឋកិច្ច រួមទាំងការចំណាយលើស្បៀងអាហារ (FES) និងលទ្ធភាព/សមត្ថភាពផ្អែកសេដ្ឋកិច្ចរបស់គ្រួសារដើម្បីបំពេញតម្រូវការចាំបាច់ផ្សេងៗ (ECMEN)។

ការវិភាគលើសូចនាករផ្សេងៗទាំងនេះរួមគ្នា គឺបង្កើតបាននូវរូបភាពទូលំទូលាយនៃស្ថានភាពសន្តិសុខស្បៀងអាហារ និងស្ថានភាពងាយរងគ្រោះនៃគ្រួសារកម្ពុជានៅក្នុងឆ្នាំ២០១៩/២០) និងនៅគ្រប់ជុំអង្កេតពីឆ្នាំ២០១៤ដល់ឆ្នាំ២០១៩/២០។ របាយការណ៍វិភាគនេះនឹងផ្តល់ព័ត៌មានដ៏មានតម្លៃដល់អ្នកធ្វើគោលនយោបាយ និងអ្នកអនុវត្តនៃក្រសួងក្នុងរដ្ឋាភិបាល និងស្ថាប័នអន្តរក្រសួងដែលធ្វើការលើសន្តិសុខស្បៀងអាហារ អាហារូបត្ថម្ភ និងការគាំពារសង្គមនៅកម្ពុជា ក៏ដូចជាដៃគូអភិវឌ្ឍន៍ជាតិ អន្តរជាតិ និងអ្នកសិក្សាស្រាវជ្រាវតាមគ្រឹស្ថានសិក្សាផ្សេងៗរួមមានក្រសួងផែនការ (MoP) ក្រុមប្រឹក្សាស្តារនិងអភិវឌ្ឍន៍កសិកម្ម និងជនបទ(CARD) ក្រសួងសុខាភិបាល(MoH) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ(MAFF) ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវជន (MoSVY) ក្រុមប្រឹក្សាជាតិគាំពារសង្គម (NSPC) សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP) ។

# ២. វិធីសាស្ត្រ

របាយការណ៍វិភាគទិន្នន័យសន្តិសុខស្បៀងអាហារ និងអាហារូបត្ថម្ភ គឺជាកិច្ចខិតខំប្រឹងប្រែងរួមគ្នារវាងវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ (MOP) និងកម្មវិធីស្បៀងអាហារពិភពលោក (WFP) របស់អង្គការសហប្រជាជាតិ។ របាយការណ៍

នេះផ្អែកលើការវិភាគទិន្នន័យពីការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា(អ.ស.ស.ក)[6] ឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៩/២០ ដែលធ្វើឡើងដោយក្រុមវិភាគទិន្នន័យសន្តិសុខស្បៀងអាហារ និងអាហារូបត្ថម្ភ (FSNDAT) របស់ NIS និងក្រុមវិភាគ និងធ្វើផែនទី (VAM) របស់ WFP ដោយប្រើប្រាស់កម្មវិធីវិភាគស្ថិតិ(SPSS) ។ រហូតមកដល់បច្ចុប្បន្ននេះការអង្កេត អ ស ស ក ត្រូវបានធ្វើឡើងចំនួន១៧លើករួចមកហើយ ដោយ NIS នៅក្នុងឆ្នាំ១០៩៩៣/១៩៩៤, ១៩៩៦, ១៩៩៧, ១៩៩៩ និង ២០០៤ និងបានធ្វើអង្កេតជាប្រចាំឆ្នាំចាប់ពីឆ្នាំ២០០៧ ដល់២០១៧។ ការធ្វើអង្កេតជារៀងរាល់ពីរឆ្នាំម្តងចាប់តាំងពីឆ្នាំ២០១៩មក ដោយឡែកការជ្រើសរើសសំណាកគំរូធំនៅរៀងរាល់ប្រាំឆ្នាំម្តង (មានន័យថាក្នុងឆ្នាំ ២០០៤, ២០០៩, ២០១៤ និងឆ្នាំ២០១៩/២០)។ ផ្នែកសន្តិសុខស្បៀងអាហារ និងយុទ្ធសាស្ត្រដោះស្រាយបែបអវិជ្ជមាន ត្រូវបានដាក់បញ្ចូលជាលើកដំបូងនៅក្នុងការអង្កេត អ.ស.ស.ក ឆ្នាំ២០១៤ និងរក្សាសម្រាប់ការប្រមូលទិន្នន័យអង្កេត អ ស ស ក ជាបន្តបន្ទាប់រហូតមក។ ការវិភាគទិន្នន័យបច្ចុប្បន្នគឺផ្អែកលើអង្កេតដែលមានសំណាកគំរូធំពីរលើកដែលបានជ្រើសរើសសំណាកគំរូច្រើនជាង ១០,០០០ គ្រួសារ (ក្នុងឆ្នាំ២០១៤ និងឆ្នាំ២០១៩/២០) និងការអង្កេតដែលបានជ្រើសរើសសំណាកគំរូតូចៗចំនួន៣លើកមានសំណាកគំរូ ៣៨៤០ គ្រួសារ (ឆ្នាំ២០១៥ ២០១៦ និង២០១៧)។ ការអង្កេតដែលមានសំណាកគំរូតូច គឺអាចធ្វើការប៉ាន់ប្រមាណនៅថ្នាក់ជាតិ តាមតំបន់ភូមិសាស្ត្រ (ភ្នំពេញ តំបន់ទីប្រជុំជនផ្សេងទៀត និងតំបន់ជនបទ) និងតាមតំបន់អេកូឡូស៊ី (ភ្នំពេញ ទំនាបកណ្តាល ទន្លេសាប ខ្ពង់រាប និងតំបន់ភ្នំ និងឆ្នេរសមុទ្រ)។ ការអង្កេតដែលមានសំណាកគំរូធំ បន្ថែមពីលើការប៉ាន់ប្រមាណនៅថ្នាក់ជាតិ តាមតំបន់ភូមិសាស្ត្រ និងតាមតំបន់អេកូឡូស៊ី គឺអាចធ្វើការប៉ាន់ប្រមាណដល់កម្រិតថ្នាក់ក្រោមជាតិបានមានន័យថាសម្រាប់ក្រុមខេត្តទាំង១៩តំបន់[7]) ស្របតាមការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ។




*រូបភាព១៖ ទំហំសំណាកគំរូតាមខេត្តសម្រាប់ការអង្កេត អ ស ស ក ឆ្នាំ២០១៩/២០*

[6] The aim is to collect sociodemographic and economic information on the living conditions of households and individuals. More information on CSES is available on the NIS website (https://nis.gov.kh/).

[7] Fourteen provinces (Banteay Meanchey, Kampong Cham, Kampong Chhnang, Kampong Speu, Kampong Thom, Kandal, Kratie, Phnom Penh, Prey Veng, Pursat, Siem Reap, Svay Rieng, Takeo and Otdar Meanchey) and five sets of provinces (Battambang and Pailin, Kampot and Kep, Preah Sihanouk and Koh Kong, Preah Vihear and Stung Treng and Mondol Kiri and Ratanak Kiri).

ការជ្រើសរើសសំណាកគំរូការអង្កេត អ ស ស ក គឺផ្អែកលើលទ្ធផលពីការធ្វើជំរឿនទូទៅប្រជាជនកម្ពុជា (ឆ្នាំ២០០៨ និង ២០១៩) ហើយអនុវត្តតាមវិធីសាស្ត្រនៃការជ្រើសរើសសំណាកគំរូមានបីដំណាក់កាល។ ដំណាក់កាលទី១ ជ្រើសរើសភូមិ ឬឯកតាសំណាកគំរូបឋម (PSUs) ចំនួន១០០៨ ដែលត្រូវបានជ្រើសរើសដោយផ្អែកលើ សំណាកគំរូចៃដន្យជាប្រព័ន្ធដែលមានសមាមាត្រប្រូបាប៊ីលីតេទៅនឹងទំហំសំណាកគំរូដោយមិនមានការជ្រើសរើសជំនួសពីគ្រប់ខេត្តទាំងអស់នៅក្នុងប្រទេសកម្ពុជា។ នៅក្នុងដំណាក់កាលទី ២ ជ្រើសរើសមួយមណ្ឌលជំរឿន (EA) ដោយចៃដន្យចេញពី PSU ឬភូមិនីមួយៗដែលបានជ្រើសរើស។ នៅក្នុងដំណាក់កាលទី៣ ជ្រើសរើសគ្រួសារចំនួន១០គ្រួសារ ក្នុងមណ្ឌលជំរឿន (EA) នីមួយៗ ដោយប្រើសំណាកគំរូជ្រើសរើសចៃដន្យជាប្រព័ន្ធសម្រាប់ការអង្កេតសំណាកគំរូតូច និងធំ លើកលែងតែការអង្កេត អ ស ស ក ឆ្នាំ២០១៤ ដែលបានជ្រើសរើស ១២ គ្រួសារក្នុងមួយមណ្ឌលជំរឿន (EA) ។

*តារាង១៖ ទំហំសំណាកគំរូសម្រាប់ការអង្កេត អ ស ស ក ឆ្នាំ២០១៤-២០១៧ និង២០១៩/២០២០ តាមទីប្រជុំជន និងជនបទ*

| ទិន្នន័យអង្កេត អ ស ស ក | ទំហំសំណាកគំរូ (PSUs/ភូមិ) | | | ទំហំសំណាកគំរូ (គ្រួសារ) | | |
|---|---|---|---|---|---|---|
| | ទីប្រជុំជន | ទីជនបទ | សរុប | ទីប្រជុំជន | ទីជនបទ | សរុប |
| អ ស ស ក ២០១៩/២០ | ៣០២ | ៧០៦ | ១០០៨ | ៣០២០ | ៧០៦០ | ១០០៨០ |
| អ ស ស ក ២០១៧ | | | ៣៨៤ | | | ៣,៨៤០ |
| អ ស ស ក ២០១៦ | | | ៣៨៤ | | | ៣,៨៤០ |
| អ ស ស ក ២០១៥ | | | ៣៨៤ | | | ៣,៨៤០ |
| អ ស ស ក ២០១៤ | ៣១២ | ៦៩៦ | ១០០៨ | ៣,៧៤៤ | ៨,៣៥២ | ១២,០៩៦ |

ទិន្នន័យសម្រាប់ការអង្កេត អ ស ស ក ជាធម្មតាត្រូវបានប្រមូលក្នុងរយៈពេល១២ខែ គឺចាប់ពីខែមករា ដល់ខែធ្នូ នៃឆ្នាំប្រតិទិននីមួយៗ លើកលែងតែឆ្នាំ២០១៩/២០ដែលការអង្កេត អ ស ស ក បានប្រមូលទិន្នន័យ ចាប់ពីឆមាសទីពីរនៃឆ្នាំ ២០១៩ រហូតដល់ពាក់កណ្តាល ឆ្នាំ២០២០ ដោយសារតែការអង្កេតបានប្រើប្រាស់ថវិការបស់រដ្ឋាភិបាលដែលត្រូវបានពន្យារពេលក្នុងការ ផ្តល់ថវិកាពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មកក្រសួងផែនការ។ ផ្នែកសំខាន់ៗនៃការអង្កេត អ ស ស ក ដែលបានយកមកវិភាគនៅក្នុងរបាយការណ៍នេះរួមមានការបរិភោគស្បៀងអាហារក្នុងគ្រួសារ យុទ្ធសាស្ត្រដោះស្រាយបែបអវិជ្ជមានការចំណាយលើស្បៀងអាហារ និងមិនមែនស្បៀងអាហារ ដែលត្រូវបានប្រើដើម្បីគណនាសូចនាករផ្សេងៗ នៃសន្តិសុខស្បៀងអាហារ និងអាហារូបត្ថម្ភរបស់គ្រួសារ ។

ការសិក្សានេះផ្តោតលើលទ្ធភាពរបស់គ្រួសារក្នុងការទទួលបានស្បៀងអាហារគ្រប់គ្រាន់ និងជីវជាតិ ដើម្បីសម្រេចបាននូវសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ។ ក្របខណ្ឌវិភាគដែលគាំទ្រក្នុងការវិភាគនេះត្រូវបានបង្ហាញក្នុងរូបភាព២។ របាយការណ៍នេះ ផ្តោតលើការទទួលបានស្បៀងអាហារក្នុងគ្រួសារ ដែលជាកត្តាកំណត់សំខាន់នៃស្ថានភាពអាហារូបត្ថម្ភ តាមរយៈការវាយតម្លៃការបរិភោគស្បៀងអាហារ(ទាំងបរិមាណ និងគុណភាព)។ គុណភាពនៃរបបអាហារក្នុងគ្រួសារ (ភាពគ្រប់គ្រាន់នៃសារជាតុចិញ្ចឹម និងភាពសម្បូរបែបនៃរបបអាហារ) យុទ្ធសាស្ត្រដោះស្រាយបែបអវិជ្ជមានដែលគ្រួសារត្រឡប់ទៅប្រើប្រាស់នៅពេលដែលការទទួលបានស្បៀងអាហារត្រូវបានសម្របសម្រួល និងភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ចដែលអាចជះឥទ្ធិពលដល់ការទទួលបានស្បៀងអាហារ។ សូចនាករសំខាន់ៗសម្រាប់ការវិភាគរួមមាន ពិន្ទុការបរិភោគស្បៀងអាហារ (FCS) ពិន្ទុភាពចម្រុះនៃរបបអាហារ(DDS), ពិន្ទុនៃការបរិភោគស្បៀងអាហារដែលមានអាហារូបត្ថម្ភ(FCS-N) យុទ្ធសាស្ត្រដោះស្រាយផ្អែកលើស្បៀងអាហារ និងសន្ទស្សន៍យុទ្ធសាស្ត្រដោះស្រាយដោយកាត់បន្ថយការបរិភោគ(rCSI) យុទ្ធសាស្ត្រដោះស្រាយផ្អែកលើជីវភាពរស់នៅ និងសន្ទស្សន៍យុទ្ធសាស្ត្រផ្អែកលើជីវភាពរស់នៅ (LCSI), ចំណែកការចំណាយលើស្បៀងអាហារ (FES)

សមត្ថភាពផ្នែកសេដ្ឋកិច្ចរបស់គ្រួសារដើម្បីបំពេញតម្រូវការចាំបាច់ (ECMEN) សន្ទស្សន៍សន្តិសុខស្បៀង (FSI/CARI) និងពិន្ទុនៃភាពអត់ឃ្លានរបស់គ្រួសារ (HHS)។




**សូចនាករសម្រាប់វាស់វែងពីលទ្ធភាពទទួលបានស្បៀងអាហារក្នុងគ្រួសារ**

- ការបរិភោគស្បៀងអាហារ
  - ពិន្ទុនៃការបរិភោគស្បៀងអាហារ (FCS)
- គុណភាពរបបអាហារ
  - ពិន្ទុនៃភាពសម្បូរបែបស្បៀងអាហារ (DDS)
  - ពិន្ទុនៃការបរិភោគស្បៀងអាហារដែលមានអាហារូបត្ថម្ភ (FCS-N)
- យុទ្ធសាស្ត្រដោះស្រាយបញ្ហាបែបអវិជ្ជមាន
  - យុទ្ធសាស្ត្រដោះស្រាយបញ្ហាផ្អែកលើស្បៀងអាហារ (rCSI)
  - យុទ្ធសាស្ត្រដោះស្រាយផ្អែកលើសកម្មភាពរស់នៅ (LCSI)
- ភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច
  - ការចំណាយលើស្បៀងអាហារ (FES)
  - លទ្ធភាពសេដ្ឋកិច្ចដើម្បីបំពេញតម្រូវការចាំបាច់ (ECMEN)
- ស្ថានភាពសន្តិសុខស្បៀង
  - សន្ទស្សន៍សន្តិសុខស្បៀង (CARI)
  - ពិន្ទុនៃភាពអត់ឃ្លានក្នុងគ្រួសារ (HHS)

*រូបភាព២៖ ក្របខណ្ឌវិភាគសន្តិសុខស្បៀងអាហារ និងអាហារូបត្ថម្ភ*

ការវិភាគទិន្នន័យដែលមានស្រាប់នៅក្នុងអង្កេតត្រូវបានរៀបចំឡើង ក្នុងអំឡុងពេលសិក្ខាសាលាបណ្តុះបណ្តាលរួមគ្នាជាមួយវិទ្យាស្ថានជាតិស្ថិតិក្នុងខែតុលា ឆ្នាំ២០២១។ មុនពេលការវិភាគទិន្នន័យ ក្រុម FSNDAT របស់ NIS ត្រូវបានបណ្តុះបណ្តាលដោយក្រុម វិភាគនិងធ្វើផែនទីរបស់ WFP លើបញ្ញាតិ និងសូចនាករសំខាន់ៗ ក្របខ័ណ្ឌវិភាគ និងការវិភាគទិន្នន័យទាក់ទងនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ ការណែនាំ និងការបង្ហាញអំពីរបៀបគណនាសូចនាករទាំងនោះត្រូវបានធ្វើឡើងជាមួយគ្នានឹងការអនុវត្តការវិភាគទិន្នន័យដោយផ្ទាល់ដោយប្រើកម្មវិធីវិភាគស្ថិតិ(SPSS)។លទ្ធផលបឋមត្រូវបានបង្ហាញ និងពិភាក្សាក្នុងចំណោមអ្នកចូលរួមក្នុងវគ្គបណ្តុះបណ្តាលទាំងអស់ សម្រាប់គោលបំណងផ្ទៀងផ្ទាត់មុនពេលរៀបចំរបាយការណ៍នេះ។

# ៣. សន្តិសុខស្បៀងអាហារ និងអាហារូបត្ថម្ភ

## ៣.១ សន្ទស្សន៍សន្តិសុខស្បៀងអាហារ

សន្តិសុខស្បៀងអាហារកើតមានឡើងនៅពេលមនុស្សគ្រប់រូប គ្រប់ពេលវេលា មានលទ្ធភាព ផ្នែករូបវន្តនិងសេដ្ឋកិច្ចក្នុងការទទួលបានស្បៀងអាហារដែលមានសុវត្ថិភាព និងមានជីវជាតិគ្រប់គ្រាន់ សម្រាប់បំពេញតាមតម្រូវការនិងចំណង់ចំណូលចិត្តរបស់ពួកគេដើម្បីឱ្យជីវិតមានសកម្មភាពរស់រវើក និងមានសុខភាពល្អ (FAO, ១៩៩៦)។ វិធីសាស្ត្ររួម បញ្ចូលគ្នាសម្រាប់រាយការណ៍សូចនាករសន្តិសុខស្បៀងអាហារ(CARI) គឺជាវិធីសាស្ត្រមួយដែលត្រូវបានប្រើដើម្បីបញ្ចូលសូចនាករសន្តិសុខស្បៀងផ្សេងៗគ្នាទៅក្នុងសន្ទស្សន៍តែមួយដើម្បីរាយការណ៍អំពីស្ថានភាពសន្តិសុខស្បៀងទាំងមូល ធ្វើចំណាត់ថ្នាក់គ្រួសារ

ជាបួនក្រុមៈ ក្រុមមានសន្តិសុខស្បៀង ក្រុមមានសន្តិសុខស្បៀងតិចតួចឬក្រុមងាយរងគ្រោះទៅនឹងអសន្តិសុខស្បៀង ក្រុមមានអសន្តិសុខស្បៀងមធ្យម និងក្រុមមានអសន្តិសុខស្បៀងធ្ងន់ធ្ងរ។ ការបញ្ចូលគ្នាសន្ទស្សន៍សន្តិសុខស្បៀងឬហៅកាត់ថា (CARI console) គឺជាលទ្ធផលចុងក្រោយនៃវិធីសាស្ត្ររួមសម្រាប់រាយការណ៍សូចនាករសន្តិសុខស្បៀងអាហារ(CARI)។ វាបង្ហាញពីសូចនាករសន្តិសុខស្បៀងទៅក្នុងតារាងសង្ខេប និងបែងចែកជាភាគរយនៃគ្រួសារសម្រាប់សូចនាករនីមួយៗដោយផ្អែកលើចំណុចកម្រិតជាក់លាក់ (តារាង២)។

ការបញ្ចូលរួមគ្នារវាងសន្ទស្សន៍ផ្សេងៗបង្ហាញឱ្យឃើញនូវវិមាត្រ ឬទិដ្ឋភាពនៃសន្តិសុខស្បៀងជាច្រើន។ ទិដ្ឋភាពស្ថានភាពសន្តិសុខស្បៀងបច្ចុប្បន្ន ប្រើប្រាស់សូចនាករសន្តិសុខស្បៀង សម្រាប់វាស់វែងភាពគ្រប់គ្រាន់នៃការបរិភោគស្បៀងអាហារតាមគ្រួសារនាពេលបច្ចុប្បន្ន។ តំបន់ភូមិសាស្ត្រ ឫទិដ្ឋភាពនេះឆ្លុះបញ្ចាំងឱ្យឃើញពីលទ្ធភាពទទួលបានស្បៀង និងភាពមានស្បៀង សម្រាប់បរិភោគក្នុងកម្រិតគ្រួសារ ដោយផ្អែកលើ ក្រុមនៃការបរិភោគស្បៀងអាហារ (FCG) និងសន្ទស្សន៍នៃយុទ្ធសាស្ត្រដោះស្រាយតាមការកាត់បន្ថយស្បៀងអាហារ (rCSI)។ ផ្នែកលទ្ធភាពដោះស្រាយ ប្រើប្រាស់សូចនាករវាស់វែងពីលទ្ធភាពសេដ្ឋកិច្ច និងយុទ្ធសាស្ត្រដោះស្រាយតាមមុខរបរចិញ្ចឹមជីវិតរបស់គ្រួសារនីមួយៗ និងឆ្លុះបញ្ចាំងពីរបៀបដែលគ្រួសារនីមួយៗនោះអាចទ្រទ្រង់នូវស្ថានភាពសន្តិសុខស្បៀងរបស់ពួកគេកន្លងមកយ៉ាងដូចម្តេច។ ផ្នែកនេះគឺផ្អែកលើ ការបញ្ចូលគ្នានៃសូចនាករយុទ្ធសាស្ត្រដោះស្រាយបញ្ហាដោយផ្អែកលើសកម្មភាពរស់នៅ (LCS) និងលទ្ធភាពសេដ្ឋកិច្ចដើម្បីបំពេញតម្រូវការចាំបាច់ (ECMEN)។

តារាង២.ការបញ្ចូលគ្នាសន្ទស្សន៍សន្តិសុខស្បៀង

| អង្កេតសេដ្ឋកិច្ចសង្គមកិច្ច | ភូមិសាស្ត្រ | | សូចនាករ | មានសន្តិសុខស្បៀង | មានសន្តិសុខស្បៀងតិចតួចឬងាយរងគ្រោះទៅនឹងអសន្តិសុខស្បៀង | មានអសន្តិសុខស្បៀងមធ្យម | មានអសន្តិសុខស្បៀងធ្ងន់ធ្ងរ |
|---|---|---|---|---|---|---|---|
| ២០១៩/២០ | ស្ថានភាពបច្ចុប្បន្ន | ការបរិភោគអាហារ | ក្រុមស្បៀងអាហារដែលបានបរិភោគ (FCG) និង& សន្ទស្សន៍នៃយុទ្ធសាស្ត្រដោះស្រាយ(*rCSI*) | ទទួលយកបាន | ទទួលយកបាន&សន្ទស្សន៍នៃយុទ្ធសាស្ត្រដោះស្រាយ(*rCSI*)>=៤ | មធ្យម | អន់ |
| | | | | **៩៨,២%** | **១,៣%** | **0,៤%** | **0,១%** |
| | សត្តមភាពដោះស្រាយ | ងាយរងគ្រោះផ្នែកសេដ្ឋកិច្ច | លទ្ធភាពសេដ្ឋកិច្ចដើម្បីបំពេញតម្រូវការចាំបាច់(*ECMEN*) | ការចំណាយ> បន្ទាត់ក្រីក្រ | - | បន្ទាត់ក្រីក្រ>=ការចំណាយ> បន្ទាត់ក្រីក្រស្បៀងអាហារ | ការចំណាយ<= បន្ទាត់ក្រីក្រស្បៀងអាហារ |
| | | | | **៧៦,៧%** | **-** | **២,៦%** | **២,៧%** |
| | | ការបាត់បង់ទ្រព្យសម្បត្តិ | យុទ្ធសាស្ត្រដោះស្រាយបញ្ហាដោយផ្អែកលើសកម្មភាពរស់នៅ(LCS) | មិនប្រើយុទ្ធសាស្ត្រដោះស្រាយ | ស្រាល | មធ្យម | ធ្ងន់ធ្ងរ |
| | | | | **៩៨%** | **១,៤%** | **0,៣%** | **0,៣%** |
| | **សន្ទស្សន៍សន្តិសុខស្បៀង(FSI)** | | | **៧៥,៥%** | **២៤%** | **0,៥%** | **0,0%** |

ការបូកបញ្ចូលគ្នារវាងសន្ទស្សន៍សន្តិសុខស្បៀង (CARI) នៅក្នុងតារាង២ បានបញ្ជាក់ថាមានគ្រួសារប្រហែល៧៥ភាគរយនៅប្រទេសកម្ពុជាត្រូវបានពិចារណាថាមានសន្តិសុខស្បៀង និងមានគ្រួសារ២៥ភាគរយទៀតជាគ្រួសារដែលងាយរងគ្រោះទៅនឹងអសន្តិសុខស្បៀង(មានសន្តិសុខស្បៀងតិចតួច ឬមានអសន្តិសុខស្បៀងមធ្យម)។ អសន្តិសុខស្បៀងគឺបណ្តាលមកពីភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច ដោយគ្រួសារភាគច្រើនមានពិន្ទុនៃការបរិភោគស្បៀងអាហារដែលអាចទទួលយកបាន

និងមិនបានប្រើប្រាស់យុទ្ធសាស្ត្រដោះស្រាយដែលប៉ះពាល់ធ្ងន់ធ្ងរនោះទេ ប៉ុន្តែសមមាត្រនៃប្រាក់ចំណូលនៅមានភាពទន់ខ្សោយ(ទាប)គួរកត់សម្គាល់ និងលទ្ធភាពសេដ្ឋកិច្ចដើម្បីបំពេញតម្រូវការចាំបាច់នៅមានកម្រិត។ គ្រួសារដែលស្ថិតនៅក្រុមនេះ ប្រហែលជានឹងអាចធ្លាក់ចូលទៅក្នុងក្រុមអសន្តិសុខស្បៀង នៅពេលមានគ្រោះអាសន្ននានាកើតឡើងដូចជាពេលជួបគ្រោះទឹកជំនន់ បាតុភូតជម្ងឺរាតត្បាតកូវីត១៩ និងតម្លៃអាហារឡើងថ្លៃ ។

ការបែងចែកតាមភូមិសាស្ត្របង្ហាញថាគ្រួសារនៅទីក្រុងភ្នំពេញគឺមានផលប៉ះពាល់តិចតួចទៅនឹងអសន្តិសុខស្បៀងជាការសន្មតដោយសារតែប្រាក់ចំណូលរបស់គ្រួសារទាំងនោះមានកម្រិតខ្ពស់ ចំណែកឯគ្រួសារនៅទីជនបទ គឺមានផលប៉ះពាល់ច្រើន។ ស្ទើរតែមួយភាគបី នៃគ្រួសារមានប័ណ្ណក្រក្រី (៣២ភាគរយ) គឺ មានអសន្តិសុខស្បៀង ឬងាយរងគ្រោះទៅនឹងអសន្តិសុខស្បៀង ហើយអសន្តិសុខស្បៀងក្នុងចំណោមគ្រួសារដែលមានស្ត្រីជាមេគ្រួសារវិញ គឺមានកម្រិតទាបជាងតិចតួច (២៩ភាគរយ)។




*រូបភាព៣៖ភាគរយនៃគ្រួសារក្នុងក្រុមសន្តិសុខស្បៀងនីមួយៗតាមតំបន់និងស្ថានភាពគ្រួសារ*

វិភាគនិន្នាការនៃសន្ទស្សន៍សន្តិសុខស្បៀង(FSI) បង្ហាញថាអសន្តិសុខស្បៀងកាន់តែមានភាពប្រសើរឡើងគួរឱ្យកត់សម្គាល់តាំងពីឆ្នាំ២០១៤មកម្ល៉េះ ដែលមានគ្រួសារប្រហែលចំនួន២៥ភាគរយប៉ុណ្ណោះ ងាយរងគ្រោះទៅនឹងអសន្តិសុខស្បៀង

(មានសន្តិសុខស្បៀងតិចតួច ឬមានអសន្តិសុខស្បៀងមធ្យម) នៅក្នុងឆ្នាំ២០១៩/២០នេះ បើធៀបទៅនឹងឆ្នាំ២០១៧មានគ្រួសារចំនួន២៩ភាគរយ។




*រូបភាព៤៖ភាគរយនៃគ្រួសារក្នុងក្រុមសន្តិសុខស្បៀងនីមួយៗតាមឆ្នាំ*

## ៣.២ លទ្ធភាពផ្នែកសេដ្ឋកិច្ចដើម្បីបំពេញតម្រូវការចាំបាច់

លទ្ធភាពផ្នែកសេដ្ឋកិច្ចដើម្បីបំពេញតម្រូវការចាំបាច់ (ECMEN) គឺត្រូវបានកំណត់ដោយការវាស់វែងការចំណាយសរុបរបស់គ្រួសារក្នុងមួយខែ ធៀបទៅនឹងបន្ទាត់ភាពក្រីក្រដែលបានបង្កើតឡើង។ សម្រាប់ការវិភាគបច្ចុប្បន្ននេះ គឺប្រើលទ្ធផលបន្ទាត់ភាពក្រីក្រនិងបន្ទាត់ភាពក្រីក្រស្បៀងអាហារថ្នាក់ជាតិចុងក្រោយ (ឆ្នាំ២០១៩/២០) មាននៅរាជធានីភ្នំពេញ និងតំបន់ទីប្រជុំជនដទៃទៀត(តារាង៣)។

*តារាង ៣៖ បន្ទាត់ភាពក្រីក្រថ្នាក់ជាតិ វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ (រៀល/ម្នាក់/ថ្ងៃ)*

| | រាជធានីភ្នំពេញ | ទីប្រជុំជនផ្សេងទៀត | ជនបទ |
|---|---|---|---|
| បន្ទាត់ភាពក្រីក្រ | ១០ ៩៥១ | ៩ ៥៧១ | ៨ ៩០៨ |
| បន្ទាត់ភាពក្រីក្រស្បៀងអាហារ | ៥ ២៦៦ | ៤ ១៨៥ | ៣ ៨២២ |

លទ្ធភាពផ្នែកសេដ្ឋកិច្ចដើម្បីបំពេញតម្រូវការចាំបាច់(ECMEN) ចែកគ្រួសារចេញជា ៣ ចំណាត់ថ្នាក់ រួមមាន ១. ចំណាយខ្ពស់ជាងបន្ទាត់ភាពក្រីក្រថ្នាក់ជាតិ មានន័យថាគ្រួសារមានលទ្ធភាពបំពេញបាននូវតម្រូវការចាំបាច់របស់ពួកគេ ២.

ចំណាយទាបជាងបន្ទាត់ភាពក្រីក្រថ្នាក់ជាតិ ប៉ុន្តែខ្ពស់ជាងបន្ទាត់ភាពក្រីក្រស្បៀងអាហារ មានន័យថាគ្រួសារទំនងជាគ្មានលទ្ធភាពបំពេញបាននូវតម្រូវការសំខាន់ៗ(រាប់ទាំងស្បៀងអាហារ)របស់ពួកគេបានទេ និង៣.ចំណាយទាបជាងបន្ទាត់ក្រីក្រស្បៀងអាហារមានន័យថាគ្រួសារគ្មានលទ្ធភាពបំពេញបាននូវតម្រូវការស្បៀងអាហាររបស់ពួកគេបានទេ (តារាង៤)។

*តារាង៤៖ ចំណុចដែលបានកំណត់**លទ្ធភាពសេដ្ឋកិច្ចដើម្បីបំពេញតម្រូវការចាំបាច់** Cut-off points for ECMEN*

| | ខ្ពស់ជាងបន្ទាត់ភាពក្រីក្រថ្នាក់ជាតិ | ចន្លោះបន្ទាត់ភាពក្រីក្រថ្នាក់ជាតិ និងបន្ទាត់ភាពក្រីក្រស្បៀងអាហារ | ទាបជាងបន្ទាត់ភាពក្រីក្រស្បៀងអាហារ |
|---|---|---|---|
| ភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច | លទ្ធភាពសេដ្ឋកិច្ចដើម្បីបំពេញតម្រូវការចាំបាច់ > បន្ទាត់ភាពក្រីក្រ | បន្ទាត់ភាពក្រីក្រស្បៀងអាហារ < លទ្ធភាពសេដ្ឋកិច្ចដើម្បីបំពេញតម្រូវការចាំបាច់ <= បន្ទាត់ភាពក្រីក្រ | លទ្ធភាពសេដ្ឋកិច្ចដើម្បីបំពេញតម្រូវការចាំបាច់ <= បន្ទាត់ភាពក្រីក្រស្បៀងអាហារ |

ខណៈដែលគ្រួសារភាគច្រើនមានលទ្ធភាពបំពេញតម្រូវការចាំបាច់របស់ខ្លួនក្នុងឆ្នាំ២០១៩/២០ (៧៧%) ការវិភាគលទ្ធភាពសេដ្ឋកិច្ចដើម្បីបំពេញតម្រូវការចាំបាច់ (ECMEN) ក៏បានបង្ហាញពីការកើនឡើងនូវភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ចក្នុងចំណោមគ្រួសារងាយទទួលរងគ្រោះបំផុត ព្រោះនៅមានគ្រួសារចំនួន២,៧% មិនអាចបំពេញតម្រូវការផ្នែកស្បៀងអាហាររបស់ខ្លួនបាន បើធៀបនឹងឆ្នាំ២០១៧ មានចំនួនតិចជាង 0,៥ % (រូបភាព៥)។ លទ្ធភាពសេដ្ឋកិច្ចដើម្បីបំពេញតម្រូវការចាំបាច់របស់គ្រួសារមានប័ណ្ណក្រីក្រមានភាពល្អប្រសើរឡើងខ្លាំងពីឆ្នាំ២០១៧ ដល់ ឆ្នាំ២០១៩/២០ ប៉ុន្តែគ្រួសារដែលមានប័ណ្ណក្រីក្រចំនួន៥% នៅតែមិនអាចបំពេញតម្រូវការស្បៀងអាហារមូលដ្ឋានរបស់ពួកគេបានក្នុងឆ្នាំ២០១៩/២០។




*រូបភាព ៥៖ និន្នាការភាគរយគ្រួសារក្នុងក្រុមលទ្ធភាពផ្នែកសេដ្ឋកិច្ចដើម្បីបំពេញតម្រូវការចាំបាច់ឆ្នាំ២០១៤-២០១៩/២០*




*រូបភាព៦៖ ភាគរយនៃគ្រួសារក្នុងក្រុមលទ្ធភាពផ្នែកសេដ្ឋកិច្ចដើម្បីបំពេញតម្រូវការចាំបាច់ បែងចែកតាមក្រុម*

## ៣.៣ ការចំណាយលើស្បៀងអាហារ

ការចំណាយលើស្បៀងអាហារ គឺជាសូចនាករបង្ហាញថាតើមានសមាមាត្រប៉ុន្មាននៃថវិការបស់គ្រួសារត្រូវបានប្រើសម្រាប់ស្បៀងអាហារ ហើយផ្តល់ឱ្យនូវការយល់ដឹងពីរបៀបនៃការចេះចាត់ចែងធនធានកម្រ និងការធ្វើអទិភាពលើតម្រូវការចាំបាច់ផ្សេងៗ។ ការចំណាយលើស្បៀងអាហារជាសូចនាករមួយរបស់លទ្ធភាពទទួលបានស្បៀងអាហារនិងភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច។ ភាគនៃការចំណាយលើស្បៀងអាហារក្នុងចំណាយសរុបរបស់គ្រួសារកាន់តែខ្ពស់នោះ ភាពងាយរងគ្រោះរបស់គ្រួសារកាន់តែខ្ពស់។ ឧទាហរណ៍ ការកើនឡើងតម្លៃស្បៀងអាហារនិងវិបត្តិប្រាក់ចំណូល គឺជះឥទ្ធិពលជាពិសេសដល់លទ្ធភាពទទួលបានស្បៀងអាហាររបស់គ្រួសារដែលមានភាគចំណាយលើស្បៀងអាហារខ្ពស់ ពីព្រោះពួកគេមានភាពបត់បែនតិចតួចក្នុងការប្រើប្រាស់ថវិកាដែលមានរបស់ពួកគេ។

ការចំណាយលើស្បៀងអាហារជាមធ្យមថ្នាក់ជាតិ គឺមិនមានការប្រែប្រួលច្រើនទេ ចាប់តាំងពីឆ្នាំ២០១៤មក មានប្រមាណ ៥០% នៃចំណាយសរុបរបស់គ្រួសារ ត្រូវបានប្រើសម្រាប់ស្បៀងអាហារ (មើលរូបភាព៧)។ ភាគរយនៃគ្រួសារដែលមានការចំណាយខ្ពស់លើស្បៀងអាហារ (> ៦៥% នៃចំណាយសរុប) បានធ្លាក់ចុះបន្តិចពី១៣,៦%នៅឆ្នាំ២០១៤ ទៅ ១១,៦% នៅឆ្នាំ២០១៩/២០ ដែលបង្ហាញពីការថយចុះនៃភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច(សូមពិនិត្យរូបភាព៨)។




*រូបភាព៧៖ និន្នាការនៃចំណាយជាមធ្យមលើស្បៀងអាហារ តាមឆ្នាំ២០១៤-២០១៩/២០*




*រូបភាព៨ ៖ ភាគរយនៃគ្រួសារក្នុងក្រុមចំណាយលើស្បៀងអាហារ តាមឆ្នាំ*

លទ្ធផលដែលបានមកពីការវិភាគបានបង្ហាញថាពីលទ្ធផលចម្រុះគ្នា (សូមមើលរូបភាព៩)។ ភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ចនៅតែមិនផ្លាស់ប្តូរក្នុងតំបន់ទីប្រជុំជន ដែលមានគ្រួសារមិនលើសពី១០% មានភាពងាយរងគ្រោះទៅនឹងអសន្តិសុខស្បៀងអាហារ (ចំណាយលើស្បៀងអាហារចាប់ពី៦៥% នៃចំណាយសរុបរបស់ពួកគេ) ក្នុងចន្លោះឆ្នាំ២០១៤ និងឆ្នាំ២០១៩/២០។ ទោះជាយ៉ាងណាក្នុងរាជធានីភ្នំពេញ និងតំបន់ជនបទ មានភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ចបានកើនឡើងចន្លោះឆ្នាំ២០១៧ និង២០១៩/២០ ដោយគ្រួសារដែលចំណាយ ចាប់ពី៦៥% នៃចំណាយសរុបរបស់ខ្លួនលើស្បៀងអាហារ មានចំនួនច្រើនជាងមុន។ គ្រួសារដែលរស់នៅតំបន់ជនបទ ដែលបានបង្ហាញថាមានប័ណ្ណក្រីក្រ មានសមាជិកដែលមានពិការភាព និង/ឬ គ្រួសាមានស្ត្រីជាមេគ្រួសារមានភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ចក្នុងឆ្នាំ២០១៩/២០ ដូចដែលបានចង្អុលបង្ហាញដោយការចំណាយជាមធ្យមលើស្បៀងអាហារមានចំនួនច្រើន។




*រូបភាព ៩. ភាគរយនៃគ្រួសារនៅក្នុងភាគចំណែកនៃការចំណាយលំអិតលើក្រុមម្ហូបអាហារនីមួយៗ*

## ៣.៤. ភាពញឹកញាប់នៃការបរិភោគស្បៀងអាហារ

ស្បៀងអាហារទាំងអស់ដែលបានបរិភោគដោយគ្រួសារ ត្រូវបានបែងចែកទៅជា ៩ក្រុមអាហារ រួមមាន៖ ធញ្ញជាតិ/អង្ករ (ធញ្ញជាតិ និងមើម) គ្រាប់ធញ្ញជាតិ(គ្រាប់សណ្តែក និងគ្រាប់ផ្លែឈើ) បន្លែ ផ្លែឈើ ប្រូតេអ៊ីនបានពីសត្វ(ស៊ុត សាច់ និងត្រី) ទឹកដោះគោនិងផលិតផលធ្វើពីទឹកដោះ ប្រេងធា ឬខ្លាញ់ ស្ករ ឬបង្អែម និងគ្រឿងទេស។

ធញ្ញជាតិ/អង្ករ (ធញ្ញជាតិ និងមើម)៖ នៅក្នុងប្រទេសកម្ពុជា ធញ្ញជាតិ និងមើម រួមមានៈ បាយ ពោត នំប៉័ង ដំឡូងមី ត្រាវ ដំឡូងបារាំង ដំឡូងឈើ ដំឡូងផ្វា។ បាយគឺជាធញ្ញជាតិដែលត្រូវបានបរិភោគច្រើនបំផុតសម្រាប់ប្រជាជនកម្ពុជា។ គិតជាមធ្យមពីឆ្នាំ២០១៤ ដល់ឆ្នាំ២០២០ គ្រួសារបានបរិភោគធញ្ញជាតិ និង/ឬមើម ស្ទើរតែជារៀងរាល់ថ្ងៃក្នុងកំឡុងពេលប្រាំពីរថ្ងៃមុនចុះអង្កេត។ តាមសង្កេត ពុំឃើញមានភាពខុសគ្នាក្នុងការបរិភោគធញ្ញជាតិនៅតាមទីតាំងភូមិសាស្ត្រ (ភ្នំពេញ តំបន់ទីប្រជុំជនផ្សេងទៀត និងតំបន់ជនបទ) ទៅតាមស្ថានភាពមេគ្រួសារ និងទៅតាមស្ថានភាពគ្រួសារក្រីក្រ នោះទេ។

គ្រាប់ធញ្ញជាតិ (គ្រាប់សណ្តែក និងគ្រាប់ផ្លែឈើ)៖ ការបរិភោគគ្រាប់ធញ្ញជាតិ (ដូចជាៈ សណ្តែក សណ្តែកដី សណ្តែកគ្រាប់ និងប្រភេទគ្រាប់ធញ្ញជាតិផ្សេងទៀត) គឺមិនសូវនិយមក្នុងការបរិភោគទេនៅប្រទេសកម្ពុជា។ ជាមធ្យម គ្រួសារនៅកម្ពុជាបរិភោគគ្រាប់ធញ្ញជាតិ គឺមានចំនួនតិចជាងមួយថ្ងៃក្នុងមួយសប្តាហ៍នៅ គ្រប់ឆ្នាំអង្កេតទាំងអស់ដែលបានធ្វើកន្លងមក លើកលែងតែនៅក្នុងអង្កេតឆ្នាំ២០១៤ គឺចំនួនថ្ងៃដែលគ្រួសារបរិភោគគ្រាប់ធញ្ញជាតិជាមធ្យមក្នុងមួយសប្តាហ៍ គឺមាន ១,៣ ថ្ងៃ។ ទោះជាយ៉ាងនេះក៏ដោយក៏ការបរិភោគគ្រាប់ធញ្ញជាតិមានការកើនឡើងគួរឱ្យកត់សម្គាល់ផងដែរក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ។ ជាទូទៅ កម្រិតនៃការបរិភោគគ្រាប់ធញ្ញជាតិ គឺមានចំនួនថ្ងៃប្រហាក់ប្រហែលគ្នានៅគ្រប់តំបន់ភូមិសាស្ត្រដែលមានការ

ពាក់ព័ន្ធទាំងអស់ ទោះបីជា គ្រួសារនៅភ្នំពេញ គ្រួសារនៅតំបន់ទីប្រជុំជនផ្សេងទៀត គ្រួសារនៅតាមតំបន់ជនបទ ស្ថានភាពមេគ្រួសារខុសគ្នា ឬ ស្ថានភាពគ្រួសារក្រីក្រផ្សេងគ្នាក៏ដោយ។

បន្លែ៖ បន្លែ រួមមាន បន្លែស្លឹកពណ៌បៃតង បន្លែពណ៌លឿង និងប្រភេទបន្លែមិនមែនពណ៌បៃតង/លឿងផ្សេងទៀត ដែលបន្លែមានស្លឹកពណ៌បៃតង កំពុងតែពេញនិយមក្នុងការបរិភោគយ៉ាងច្រើនជាងគេបំផុត។ ជាមធ្យម ពីឆ្នាំ២០១៤ ដល់ ឆ្នាំ២០២០ គ្រួសារបានបរិភោគបន្លែញឹកញាប់ណាស់ជាមធ្យមប្រាំមួយថ្ងៃក្នុងមួយសប្តាហ៍ ទោះបីជាចំនួនថ្ងៃនៃការបរិភោគបន្លែនេះមានការថយចុះតិចជាង៦ថ្ងៃ នៅឆ្នាំ២០១៩/២០ក៏ដោយ។ តាមការសង្កេត ពុំឃើញមានមានភាពខុសគ្នា ក្នុងការបរិភោគបន្លែនៅក្នុងចំណោមគ្រួសារដែលរស់នៅតាមទីតាំងភូមិសាស្ត្រផ្សេងៗគ្នានោះទេ។

ផ្លែឈើ៖ គ្រួសារកម្ពុជាបរិភោគផ្លែឈើ (ដូចជា ផ្លែឈើពណ៌លឿង ឬពណ៌ទឹកក្រូច និងប្រភេទផ្លែឈើផ្សេងទៀត) តិចជាងបរិភោគបន្លែ គឺ បានបរិភោគ ចន្លោះពី ២ ទៅ ៣ ថ្ងៃ ជាមធ្យមក្នុងមួយសប្តាហ៍។ ការបរិភោគផ្លែឈើ បង្ហាញនិន្នាការកើនឡើងនៅឆ្នាំ២០១៧ និងឆ្នាំ២០១៩/២០ ហើយរហូតមកដល់ពេលនេះ គឺមានការបរិភោគចំនួន ៣ថ្ងៃ ជាមធ្យមក្នុងមួយសប្តាហ៍។ ការបរិភោគផ្លែឈើ គឺមានទំនាក់ទំនងទៅនឹងរដូវកាល ឧទាហរណ៍ រដូវដែលសម្បូរផ្លែឈើដូចជា ស្វាយ ចេក ធូរ៉េន។ល។ ហើយនិងមានការបរិភោគច្រើននៅតំបន់ទីប្រជុំជនជាងតំបន់ផ្សេងៗទៀត។

ប្រូតេអ៊ីនបានពីសត្វ(ស៊ុត សាច់ និងត្រី)៖ សាច់សត្វ ស៊ុត និងត្រី គឺជាប្រភពប្រូតេអ៊ីនដ៏សំខាន់សម្រាប់គ្រួសារនៅកម្ពុជា។ ស្បៀងអាហារដែលប្រើប្រាស់សម្រាប់គណនាការបរិភោគប្រូតេអ៊ីន រួមមាន៖ សាច់គោ សាច់ក្របី សាច់ជ្រូក សាច់មាន់ សាច់ទា សាច់សរីរាង្គ ត្រីនិងប្រភេទសត្វក្នុងទឹកផ្សេងទៀត និងស៊ុត។ ត្រី គឺជាសមាសភាគអាហារសំខាន់បំផុតសម្រាប់ប្រជាជនកម្ពុជា ជាពិសេសសម្រាប់គ្រួសារដែលរស់នៅតាមតំបន់ជនបទ ដែលបានចិញ្ចឹម និង/ឬ ចាប់ត្រីពីទន្លេ ស្ទឹង បឹង និងវាលស្រែ។ តាមការវិភាគបង្ហាញថា ការបរិភោគប្រូតេអ៊ីនដែលបានពីសត្វ គឺមានភាពញឹកញាប់ ដូចគ្នាទៅនឹងការបរិភោគធញ្ញជាតិដែរ ដែលជាមធ្យមត្រូវបានបរិភោគស្ទើរតែប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍ នៅគ្រប់ឆ្នាំអង្កេតទាំងអស់ដែលបានធ្វើកន្លងមក។ លទ្ធផលពីអង្កេតបង្ហាញថា គ្រួសារបរិភោគប្រូតេអ៊ីនដែលបានពីសត្វ គឺមានចំនួនថ្ងៃប្រហាក់ប្រហែលគ្នា ទោះបីជាគ្រួសាររស់នៅក្នុងតំបន់ភូមិសាស្ត្រផ្សេងគ្នា ស្ថានភាពមេគ្រួសារខុសគ្នា ឬស្ថានភាពគ្រួសារក្រីក្រផ្សេងគ្នា ក៏ដោយ។

ទឹកដោះគោ និងផលិតផលធ្វើពីទឹកដោះ៖ ផលិតផលទឹកដោះគោ និងទឹកដោះគោ រួមមាន ទឹកដោះគោឆៅ ម្សៅទឹកដោះគោ ទឹកដោះគោជូ យ៉ូហ្គឺត និងឈីស ត្រូវបានបរិភោគ មិនញឹកញាប់ទេក្នុងចំណោមគ្រួសារនៅកម្ពុជា។ ការរកឃើញបង្ហាញពីនិន្នាការកើនឡើងក្នុងការបរិភោគទឹកដោះគោ និងផលិតផលធ្វើពីទឹកដោះ ដែលកើនឡើងស្ទើរតែពីរដងរវាងឆ្នាំ២០១៤ និងឆ្នាំ២០២០ ដោយគ្រួសារបានបរិភោគស្ទើរតែពីរថ្ងៃក្នុងមួយសប្តាហ៍នៅឆ្នាំ២០១៩/២០។ គ្រួសាររស់នៅរាជធានីភ្នំពេញបរិភោគផលិតផលធ្វើពីទឹកដោះ និងទឹកដោះគោញឹកញាប់ជាងគ្រួសារដែលរស់នៅតំបន់ជនបទ និងតំបន់ទីប្រជុំជនដទៃទៀត។

ខ្លាញ់/ប្រេងឆា៖ ខ្លាញ់ រួមមាន ខ្លាញ់សត្វ ប្រេងបន្លែ ប្រេងកន្ទក់ ប្រេងដូង និងប៊័រ។ ប្រេងបន្លែ និងខ្លាញ់សត្វ (ជាពិសេស សាច់ជ្រូកបីជាន់ សាច់ជ្រូកជាប់ខ្លាញ់) គឺត្រូវបានប្រើប្រាស់ជាចម្បងសម្រាប់ធ្វើឬចម្អិនម្ហូបអាហារនៅកម្ពុជា។ ចំនួនថ្ងៃនៃការបរិភោគគឺមានចន្លោះពី ៣ ទៅ ៤ ថ្ងៃ ក្នុងមួយសប្ដាហ៍ រវាងឆ្នាំ២០១៤ និងឆ្នាំ២០១៧។ ការបរិភោគខ្លាញ់/ប្រេងឆា បានកើនឡើងស្មើរតែ ៥ថ្ងៃក្នុងមួយសប្ដាហ៍ នៅឆ្នាំ២០១៩/២០។ គ្រួសាររស់នៅភ្នំពេញ បរិភោគខ្លាញ់/ប្រេងឆា ញឹកញាប់ជាងគ្រួសារដែលរស់នៅតំបន់ផ្សេងទៀត នៅ គ្រប់ជុំអង្កេតទាំងអស់ដែលបានធ្វើកន្លងមក គឺបានបរិភោគខ្លាញ់/ប្រេងឆាច្រើនជាង ៥ថ្ងៃក្នុងមួយសប្ដាហ៍ នៅឆ្នាំ២០១៩/២០។

ស្ករ/បង្អែម[8]៖ ស្ករ គឺសំដៅទៅលើស្ករគ្រប់ប្រភេទទាំងអស់ បង្អែម និងទឹកឃ្មុំ។ លទ្ធផល បង្ហាញថា ការបរិភោគស្កររបស់គ្រួសារបានកើនឡើងពីរដង គឺពីរថ្ងៃក្នុងមួយសប្ដាហ៍ រវាងឆ្នាំ២០១៥ និងឆ្នាំ២០១៧ ទៅដល់ប្រមាណជា ៤ថ្ងៃក្នុងមួយ សប្ដាហ៍ នៅឆ្នាំ២០១៩/២០។ ការបរិភោគស្ករ/បង្អែម គឺមានចំនួនថ្ងៃប្រហាក់ប្រហែលគ្នាសម្រាប់គ្រួសាររស់នៅភ្នំពេញ គ្រួសាររស់នៅតំបន់ទីប្រជុំជនផ្សេងទៀត និងគ្រួសាររស់នៅតំបន់ជនបទ ក៏ដូចជាសម្រាប់គ្រួសារដែលរស់នៅក្នុងស្ថានភាពមេគ្រួសារខុសគ្នា និងនៅក្នុងស្ថានភាពគ្រួសារក្រីក្រផ្សេងគ្នា ផងដែរ។

គ្រឿងទេស/គ្រឿងផ្សំ៖ គ្រឿងទេស ឬគ្រឿងផ្សំ រួមមាន ស្ករ អំបិល ម្រេច ទឹកស៊ីអ៊ីវ ទឹកត្រី ។ល។ ត្រូវបាន បរិភោគជាទូទៅសម្រាប់គ្រួសារនៅកម្ពុជា ដើម្បីបន្ថែមរសជាតិទៅក្នុងម្ហូបអាហារដែលពួកគេបានទទួលទាន។ ជាមធ្យម ចំនួនថ្ងៃនៃការបរិភោគគ្រឿងទេស ត្រូវបានរាយការណ៍ថាមានចំនួនស្មើរតែ ៧ថ្ងៃក្នុងមួយសប្ដាហ៍ នៅក្នុងគ្រប់ជុំអង្កេតទាំងអស់ដែលបានធ្វើកន្លងមក (២០១៤- ២០១៩/២០)។ លទ្ធផលពីអង្កេត រកមិនឃើញថាមានភាពខុសគ្នា ក្នុងការបរិភោគគ្រឿងទេសនៅគ្រប់តំបន់ភូមិសាស្រ្ត (ភ្នំពេញ តំបន់ទីប្រជុំជនផ្សេងទៀត តំបន់ជនបទ) នៅក្នុងស្ថានភាពមេគ្រួសារផ្សេងៗគ្នា និងនៅក្នុងស្ថានភាពគ្រួសារមានប័ណ្ណក្រីក្រផ្សេងៗគ្នាឡើយ ។

[8] The 2014 survey combined sugars and condiments in the same food group, hence for 2014 they are reported together as "condiments".




*រូបភាព១០៖ ចំនួនថ្ងៃជាមធ្យមនៃការបរិភោគក្រុមអាហារទាំង៩*

## ៣.៥. ពិន្ទុនៃការបរិភោគស្បៀងអាហារ

ពិន្ទុនៃការបរិភោគស្បៀងអាហារ (FCS) វាយតម្លៃពីបរិមាណ និងគុណភាពនៃរបបអាហាររបស់គ្រួសារ ដោយវាស់វែងពីរបបអាហារចម្រុះ ភាពញឹកញាប់នៃការបរិភោគអាហារ និងសារៈសំខាន់នៃអាហារូបត្ថម្ភដែលទាក់ទងទៅនឹងក្រុមអាហារផ្សេងៗ។ ពិន្ទុការបរិភោគស្បៀងអាហារគឺជាពិន្ទុរួមបញ្ចូលគ្នាដែលបានគណនាមកពីចំនួនថ្ងៃនៃការបរិភោគក្រុមអាហារផ្សេងៗដែលគ្រួសារបានបរិភោគក្នុងរយៈពេលប្រាំពីរថ្ងៃមុនការអង្កេត។

ស្បៀងអាហារដែលបានសួរនៅក្នុងអង្កេត ត្រូវបាន បញ្ចូលគ្នាទៅជាប្រាំបួនក្រុមអាហារសំខាន់ៗ។ ភាពញឹកញាប់ឬចំនួនថ្ងៃនៃការបរិភោគ(០-៧ថ្ងៃ) ក្រុមអាហារនីមួយៗ គឺត្រូវបានគណនាដោយផ្អែកទៅលើផលបូកនៃភាពញឹកញាប់ឬចំនួនថ្ងៃនៃការបរិភោគមុខអាហារទាំងអស់ដែលមាននៅក្នុងក្រុមអាហារនីមួយៗ ជាមួយនឹងចំនួនថ្ងៃអតិបរមា[9] គឺ ប្រាំពីរថ្ងៃសម្រាប់ក្រុមអាហារនីមួយៗ។ បន្ទាប់មក ចំនួនថ្ងៃឬភាពញឹកញាប់នៃការបរិភោគក្រុមអាហារនីមួយៗ ត្រូវគុណនឹងមេគុណជាក់លាក់មួយ (តារាង៥) ដែលឆ្លុះបញ្ចាំងពីសារៈសំខាន់នៃអាហារូបត្ថម្ភរបស់វា។ ឧទាហរណ៍ ប្រូតេអ៊ីនបានមកពីសត្វគឺមានសារជាតុចិញ្ចឹមច្រើន ដែលមានមេគុណខ្ពស់ជាងគេ (៤) ខណៈដែលគ្រឿងទេសដែលស្ទើរតែគ្មានសារជាតុចិញ្ចឹមសោះ ហើយត្រូវបានផ្តល់មេគុណទាបជាងគេបំផុត (០)។ ដូច្នេះពិន្ទុនៃការបរិភោគស្បៀងអាហារ គឺជាផលបូកចំនួនថ្ងៃឬភាពញឹកញាប់ (០-៧ថ្ងៃ) នៃការបរិភោគដែលបានផ្តល់មេគុណ របស់ក្រុមអាហារទាំងប្រាំបួន។

[9] The total number of consumption days for some food groups may exceed seven days due to summation of the consumption frequency of various food items in that food groups. In that case, seven is taken as a maximum.

*តារាង៥ ៖ មុខអាហារ ក្រុមអាហារ និងមេគុណរបស់វា*

| រាយមុខ | មុខអាហារ | ក្រុមអាហារ | មេគុណ | ការគណនា |
|---|---|---|---|---|
| ០១ | ធញ្ញជាតិ/អង្ករ៖ បាយ បបរ នំបញ្ចុក គុយទាវ ពោត ផាស្តា នំប៉័ង នំក្រេម នំដូណាត់ | ១.ធញ្ញជាតិចម្បង/ធញ្ញជាតិ និងមើម/ម្សៅ($X_1$) | ២ | **២** *$X_1$ |
| ០២ | ឬស និងមើម៖ ដំឡូងបារាំង ដំឡូងឈើ ដំឡូងជ្វាពណ៌ស ត្រាវ និងប្រភេទមើមផ្សេងទៀត | | | |
| ០៣ | គ្រាប់សណ្តែក និងគ្រាប់ផ្លែឈើ៖ សណ្តែកដី សណ្តែកក្រហម សណ្តែកសៀង សណ្តែកខៀវ សណ្តែកបាយ សណ្តែកបារាំង សណ្តែក cowpeas គ្រាប់ស្វាយចន្ទី គ្រាប់ឈូក គ្រាប់ល្ពៅ គ្រាប់ឪឡឹក និងប្រភេទគ្រាប់ផ្សេងទៀត | ២. គ្រាប់ធញ្ញជាតិ (គ្រាប់សណ្តែក និងគ្រាប់ផ្លែឈើ) ($X_2$) | ៣ | ៣ *$X_2$ |
| ០៤ | បន្លែពណ៌លឿង ឬពណ៌ទឹកក្រូច(បន្លែមានវីតាមីនA ច្រើន)៖ ការ៉ុត ម្ទេសប្លោកក្រហម ល្ពៅ ដំឡូងជ្វាពណ៌លឿង ឬពណ៌ទឹកក្រូច | ៣. បន្លែ ($X_3$) | ១ | ១ *$X_3$ |
| ០៥ | បន្លែស្លឹកពណ៌បៃតង៖ ស្ពៃ ផ្កាស្ពៃ ផ្ទីដូង ស្លឹកបាស់ ស្ពៃស្ពីណាត់ ឬបន្លែស្លឹកខៀវចាស់ ស្លឹកដំឡូងមី | | | |
| ០៦ | បន្លែដទៃទៀត៖ ខ្ទឹមបារាំង ប៉េងបោះ ត្រសក់ ឆៃថាវ សាឡាដ សណ្តែកគួរ គ្រប់ ជាដើម។ល។ | | | |
| ០៧ | ផ្លែឈើពណ៌លឿង ឬពណ៌ទឹកក្រូច(ផ្លែឈើមានវីតាមីនAច្រើន)៖ ស្វាយទុំ ល្ហុងទុំ អាព្រីខត ប៉ែស ប៉េងប៉ោះទុំ ផ្លែសូដា ឬតូមា | ៤. ផ្លែឈើ($X_4$) | ១ | **១** *$X_4$ |
| ០៨ | ផ្លែឈើដទៃទៀត៖ ចេក ប៉ោម ក្រូចពោធិសាត់ ក្រូចឆ្មារ ក្រូចឃ្វិច | | | |
| ០៩ | សាច់សរីរាង្គ(សម្បូរជាតិដែក)៖ ថ្លើម ក្រលៀន បេះដូង និង/ឬ សាច់សរីរាង្គផ្សេងទៀត | ៥. ប្រូតេអ៊ីនបានពីសត្វ (ត្រី ស៊ុត | ៤ | **៤** *$X_5$ |

| | | | | |
|---|---|---|---|---|
| ១០ | សាច់ និងបក្សី (សាច់គោ សាច់ក្របី សាច់ចៀម សាច់ជ្រូក សាច់មាន់ សាច់ទា សាច់សត្វព្រៃ សាច់ងៀត ឬសាច់ប្រឡាក់ និងសាច់សត្វស្លាបដទៃទៀត | សាច់គោ សាច់ជ្រូក សាច់មាន់ សាច់ទា។ល។($X_5$) | | |
| ១១ | ត្រី និងប្រភេទសត្វក្នុងទឹកផ្សេងទៀត (ត្រីទឹកសាប ត្រីទឹកប្រៃ ត្រីប្រឡាក់ ត្រីងៀត ត្រីឆ្អើរ ត្រីខកំប៉ុង កង្កែប ក្តាម ខ្យង បង្គារ និងអាហារសមុទ្រផ្សេងទៀត | | | |
| ១២ | ពង ឬស៊ុត (ស៊ុតមាន់ ស៊ុតទា ពងគ្រួច ពងទាប្រៃ ។ល។ | | | |
| ១៣ | ទឹកដោះគោ និងផលិតផលធ្វើពីទឹកដោះ (ទឹកដោះគោឆៅ ម្សៅទឹកដោះគោ ការ៉េម ទឹកដោះគោជូ ឈីស ។ល។ | ៦. ទឹកដោះគោ និងផលិតផលទឹកដោះគោ ($X_6$) | ៤ | **៤***$X_6$ |
| ១៤ | ប្រេងឆា និងខ្លាញ់ (ប្រេងកន្ទក់ ប្រេងបន្លែ ខ្លាញ់សត្វ ប័រ ប្រេងរុក្ខជាតិ ប្រេងដូង។ល។ | ៧. ប្រេងឆា និងខ្លាញ់ ($X_7$) | ០,៥ | **០,៥***$X_7$ |
| ១៥ | ស្ករ បង្អែម ទឹកឃ្មុំ | ៨. ស្ករ($X_8$) | ០,៥ | **០,៥***$X_8$ |

ពិន្ទុនៃការបរិភោគស្បៀងអាហារ ត្រូវបានបែងចែកទៅជាបីក្រុមនៃការបរិភោគស្បៀងអាហារស្តង់ដារ (អន់ មធ្យម ល្អ) ដោយផ្អែកទៅលើការបង្កើតចំណុចកម្រិត (cut-off points) ដែលបានបង្កើតរួច (សូមមើលតារាង៦)។ នៅកម្ពុជា ក៏ដូចជានៅបណ្តាប្រទេសផ្សេងៗទៀតដែលបរិភោគធញ្ញជាតិញឹកញាប់ (ដូចជាបាយ) នោះ ត្រូវបានប្រើចំណុចកម្រិត ដែលបានកែតម្រូវ ទៅតាមប្រទេសរបស់ខ្លួន។

*តារាង៦ ៖ ចំណុចកម្រិតសម្រាប់ពិន្ទុនៃការបរិភោគស្បៀងអាហារ (ស្តង់ដារ និងកែតម្រូវ)សម្រាប់ក្រុមនៃការបរិភោគអាហារ*

| **ក្រុមប្រើប្រាស់អាហារ** | **ចំណុចកាត់ស្តង់ដារ** | **ចំណុចកាត់កែតម្រូវ** |
|---|---|---|
| អន់ | ០-២១ | ០-២៤,៥ |
| មធ្យម | ២១,៥-៣៥ | ២៥-៣៨,៥ |
| ល្អ | >៣៥ | >៣៨,៥ |

លទ្ធផលបង្ហាញថា ពិន្ទុជាមធ្យមនៃការបរិភោគស្បៀងអាហារ(FCS) គឺខ្ពស់ នៅក្នុងរង្វង់ ៦០ នៅគ្រប់ការអង្កេតទាំងអស់ហើយមានការកើនឡើងគួរឱ្យកត់សម្គាល់ចាប់ពីឆ្នាំ២០១៦មក។ មានន័យថា គ្រួសារបរិភោគបរិមាណអាហារអេប្បរមា និងអាហារចម្រុះ។ នៅឆ្នាំ២០១៩/២០ ស្ទើរតែគ្រប់គ្រួសារទាំងអស់ដែលបានអង្កេត (៩៩.៥%) បានបរិភោគអាហារល្អ ហើយមានតែគ្រួសារ ០.៥ភាគរយ ប៉ុណ្ណោះ ដែលបានបរិភោគអាហារមិនគ្រប់គ្រាន់ (មធ្យម ឬទាប)។ គួរកត់សម្គាល់ថា នេះមានការថយចុះបន្តិច ពីឆ្នាំ២០១៦ និងឆ្នាំ២០១៧ នៅខណៈដែលពេលនោះ គ្រួសារ ៩៩.៨ ភាគរយ បានបរិភោគអាហារល្អ។ ភាពខុសគ្នានេះ គឺមានន័យសំខាន់សម្រាប់ស្ថិតិ។




*រូបភាព១១៖ ភាគរយនៃគ្រួសារក្នុងក្រុមបរិភោគស្បៀងអាហារ តាមឆ្នាំ*

ការវិភាគបែងចែក តាមតំបន់ឬក្រុមបង្ហាញថា ពិន្ទុជាមធ្យមនៃការបរិភោគស្បៀងអាហារ(FCS) នៅតំបន់ទីប្រជុំជនខ្ពស់ជាងតំបន់ជនបទ ហើយខ្ពស់ជាងគេគឺនៅភ្នំពេញ (លើកលែងតែ ឆ្នាំ២០១៥)។ ពិន្ទុនៃការបរិភោគស្បៀងអាហាររបស់គ្រួសារដែលមានស្ត្រីជាមេគ្រួសារ គឺទាបជាងមធ្យមថ្នាក់ជាតិនៅគ្រប់ឆ្នាំទាំងអស់ ហើយនៅឆ្នាំ២០១៩/២០ ក៏ទាបជាងពិន្ទុជាមធ្យមនៃការបរិភោគស្បៀងអាហាររបស់គ្រួសារដែលត្រូវចាត់ថ្នាក់ជាគ្រួសារក្រីក្រផងដែរ (មើលរូបភាព១២)។




*រូបភាព១២ ៖ និន្នាការនៃពិន្ទុជាមធ្យមនៃការបរិភោគសស្បៀងអាហារ បែងចែកតាមក្រុមឆ្នាំ២០១៤-២០១៩/២០*

## ៣.៦. ពិន្ទុរបបអាហារចម្រុះ

ពិន្ទុរបបអាហារចម្រុះ គឺវាស់វែងពីចំនួនក្រុមអាហារផ្សេងៗដែលគ្រួសារបានបរិភោគក្នុងរយៈពេលប្រាំពីរថ្ងៃ និងបង្ហាញពីគុណភាពនៃរបបអាហាររបស់គ្រួសារ។ គ្រួសារដែលបានបរិភោគអាហារបួនក្រុម ឬតិចជាងនេះ ត្រូវបានចាត់ទុកថាជាគ្រួសារបានបរិភោគរបបអាហារចម្រុះកម្រិតទាប។ គ្រួសារដែលបានបរិភោគអាហារពី ៥ ទៅ ៦ ក្រុមអាហារ ត្រូវបានចាត់ទុកថាជាគ្រួសារបានបរិភោគ របបអាហារកម្រិតមធ្យម។ ហើយគ្រួសារដែលបានបរិភោគអាហារលើសពី 6 ក្រុមអាហារ ត្រូវបានចាត់ទុកថាជាគ្រួសារបានបរិភោគ របបអាហារកម្រិតខ្ពស់។

លទ្ធផលបង្ហាញថា ចំណែកនៃគ្រួសារដែលបានបរិភោគរបបអាហារ កម្រិតទាប (តិចជាង ៥ ក្រុមអាហារ) មានការធ្លាក់ចុះគួរឱ្យកត់សម្គាល់នៅចន្លោះឆ្នាំ ២០១៤ និងឆ្នាំ២០១៧ ប៉ុន្តែនៅទ្រឹងនៅក្នុងឆ្នាំ២០១៩/២០ (ភាពខុសគ្នានេះ គឺមានន័យគ្រប់គ្រាន់សម្រាប់ស្ថិតិនៅគ្រប់ឆ្នាំទាំងអស់ លើកលែងតែឆ្នាំ ២០១៧ និងឆ្នាំ២០១៩/២០)។ ទន្ទឹមនឹងនេះ ចំណែកនៃគ្រួសារដែលបានបរិភោគរបបអាហារកម្រិតខ្ពស់ បានធ្លាក់ចុះពោលគឺប្រមាណជាមួយក្នុងចំណោមបួនគ្រួសារ (២៥.៧%) នៅក្នុងឆ្នាំ២០១៧ មកនៅត្រឹមប្រមាណជាមួយក្នុងចំណោមប្រាំគ្រួសារ (២២.៧%) នៅក្នុងឆ្នាំ២០១៩/២០ (ភាពខុសគ្នានេះ គឺមានន័យគ្រប់គ្រាន់សម្រាប់ស្ថិតិ) (សូមមើលរូបភាព១៣)។




*រូបភាព១៣ ៖ ភាគរយគ្រួសារដែលមាន របបអាហារទាប មធ្យម និងខ្ពស់ បែងចែកតាមឆ្នាំ*

ការវិភាគបែងចែក តាមតំបន់ឬក្រុមបង្ហាញថា របបអាហារចម្រុះមានការថយចុះនៅគ្រប់ទីតាំងភូមិសាស្ត្រទាំងអស់ ចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០១៩/២០ លើកលែងតែក្នុងចំណោមគ្រួសារក្រីក្រ គឺមានភាពប្រសើរឡើងគួរឱ្យកត់សម្គាល់ក្នុងការបរិភោគ របបអាហារចម្រុះនេះ (សូមមើលរូបភាព១៥)។ គួរកត់សម្គាល់ថា របបអាហារចម្រុះក្នុងចំណោមគ្រួសារក្រីក្រ គឺប្រហាក់ប្រហែលគ្នាទៅនឹងមធ្យមថ្នាក់ជាតិ។ ជាពិសេស គេសង្កេតឃើញថា ពុំមានភាពខុសគ្នា នៃរបបអាហារចម្រុះរវាងគ្រួសារក្រីក្រ និងគ្រួសារដែលរស់នៅតំបន់ជនបទ ដែលបង្ហាញពីគុណភាពនៃរបបអាហារទាប ដែលនៅតែកើតមានឡើងនៅតាមតំបន់ជនបទភាគច្រើននៃប្រទេសកម្ពុជា។ លទ្ធផលក៏បានបង្ហាញពីភាពខុសគ្នាគួរឱ្យកត់សម្គាល់ផងដែរ នៃរបបអាហារចម្រុះរវាងគ្រួសារដែលរស់នៅភ្នំពេញ និងតំបន់ផ្សេងៗទៀត ដែលចំណែកនៃគ្រួសាររស់នៅក្នុងរាជធានីមាន របបអាហារកម្រិតខ្ពស់ (៤០%) គឺច្រើនជាងទ្វេដងបើប្រៀបធៀបទៅនឹងគ្រួសារនៅតាមតំបន់ជនបទ (១៨%) ហើយច្រើនជាងស្ទើរតែទ្វេដងបើប្រៀបធៀបទៅនឹងគ្រួសារដែលរស់នៅតំបន់ទីប្រជុំជនផ្សេងទៀត (២៤%) (មើលរូបភាព១៤)។




*រូបភាព១៤៖ ភាគរយគ្រួសារដែលមាន របបអាហារទាប មធ្យម និងខ្ពស់ បែងចែកបែងចែកតាមក្រុម*




*រូបភាព១៥៖ និន្នាការពិន្ទុមធ្យមនៃរបបអាហារចម្រុះបែងចែកបែងចែកតាមក្រុម ឆ្នាំ២០១៤-២០១៩/២០*

## ៣.៧. ពិន្ទុនៃការបរិភោគស្បៀងអាហារ- អាហារូបត្ថម្ភ

ពិន្ទុនៃការបរិភោគស្បៀងអាហារ - អាហារូបត្ថម្ភ (FCS-N) បង្ហាញអំពីគុណភាពរបបអាហារដែលមានអាហារូបត្ថម្ភ ដែលបានបរិភោគដោយគ្រួសារ។ ផ្អែកលើភាពញឹកញាប់ឬចំនួនថ្ងៃនៃការបរិភោគអាហារដែលសម្បូរអាហារូបត្ថម្ភនោះ សូចនាករមួយត្រូវបានគណនាឡើងដើម្បីវាយតម្លៃពីស្ថានភាពអាហារូបត្ថម្ភរបស់គ្រួសារ ។ សូចនាករនេះ វាស់វែងពីភាពញឹកញាប់ឬចំនួនថ្ងៃនៃការបរិភោគស្បៀងអាហារដែលសម្បូរវីតាមីនអា ប្រូតេអ៊ីន និងជាតិដែក របស់គ្រួសារក្នុងរយៈពេល ៧ ថ្ងៃកន្លងមក។ ភាពញឹកញាប់ឬចំនួនថ្ងៃនៃការបរិភោគអាហារសម្បូរមីក្រូ និងម៉ាក្រូសារជាតិសំខាន់ៗទាំងនេះកាន់តែខ្ពស់ ធ្វើឱ្យគ្រួសារមានលទ្ធភាពកាន់តែខ្ពស់ក្នុងការទទួលបានអាហារូបត្ថម្ភគ្រប់គ្រាន់។ ប្រូតេអ៊ីនដើរតួនាទីយ៉ាងសំខាន់សម្រាប់ការលូតលាស់ និងមានសារៈសំខាន់សម្រាប់ទប់ស្កាត់ភាពស្គមស្គាំង និងភាពក្រេះក្រិន ដែលភាគច្រើនកើតឡើងក្នុងរយៈពេល ១០០០ថ្ងៃ ដំបូងនៃជីវិត។ កង្វះជាតិដែក គឺជាមូលហេតុចម្បងមួយនៃភាពស្លេកស្លាំង និងបានធ្វើឱ្យប៉ះពាល់ប្រមាណជា ២៥ភាគរយ នៃចំនួនប្រជាជនលើពិភពលោក ដែលភាគច្រើន ប៉ះពាល់ដល់កុមារក្នុងវ័យមុនចូលសាលារៀន និងស្ត្រី ដែលជះឥទ្ធិពលរយៈពេលវែងដល់ផលិតភាព និងគុណភាពនៃជីវិត។ កង្វះវីតាមីនអា ប្រសិនបើដោះស្រាយបានមុនពេលកុមារមានអាយុប្រាំឆ្នាំនោះ អាចជួយកាត់បន្ថយអត្រាស្លាប់ និងជំងឺឆ្លងផ្សេងៗបានដូចជា កញ្ជ្រឹល រាគ និងគ្រុនចាញ់។

ការរកឃើញពីការធ្វើអង្កេតផ្សេងៗ បង្ហាញថាចំណែកភាគរយនៃគ្រួសារនៅកម្ពុជា ដែលបរិភោគស្បៀងអាហារសម្បូរវីតាមីនអារាល់ថ្ងៃ មានការកើនឡើងគួរឱ្យកត់សម្គាល់ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៧ ប៉ុន្តែមានការថយចុះបន្តិចនៅឆ្នាំ ២០១៩/២០ មកនៅត្រឹម ៧៤,១ភាគរយ (ភាពខុសគ្នានេះ គឺមានន័យគ្រប់គ្រាន់សម្រាប់ស្ថិតិ)។ សមាមាត្រនៃគ្រួសារ ដែលបរិភោគស្បៀងអាហារសម្បូរប្រូតេអ៊ីនប្រចាំថ្ងៃ គឺមានភាគរយខ្ពស់ ហើយស្ថិតនៅថេរចន្លោះពីឆ្នាំ២០១៤ និងឆ្នាំ២០១៧ (ច្រើនជាង ៩៦%) ប៉ុន្តែ មានការថយចុះបន្តិច ពីឆ្នាំ២០១៧ (៩៨,១%) ដល់ឆ្នាំ២០១៩/២០ (៩៦,៨%) (ភាពខុសគ្នានេះ គឺមានន័យគ្រប់គ្រាន់សម្រាប់ស្ថិតិ)។ គួរកត់សម្គាល់ថា ការបរិភោគស្បៀងអាហារដែលសម្បូរជាតិដែក ក៏មានការថយចុះគួរកត់សម្គាល់ដែរ ចាប់ពីឆ្នាំ២០១៦មក។ នៅឆ្នាំ២០១៩/២០ មានគ្រួសារ ១៩,២ភាគរយ មិនបានបរិភោគស្បៀងអាហារសម្បូរជាតិដែករាល់ថ្ងៃទេ ធៀបទៅនឹងឆ្នាំ២០១៦ ដែលមានត្រឹមតែ ១២,៩ភាគរយ ប៉ុណ្ណោះ (មើលរូបភាព១៦)។




*រូបភាព១៦៖ ភាគរយគ្រួសារ បរិភោគអាហារសម្បូរវីតាមីនអា ប្រូតេអ៊ីន និងជាតិដែក*

ការវិភាគបែងចែកតាមតំបន់ឬក្រុម បង្ហាញពីរូបភាពចម្រុះសម្រាប់ការបរិភោគ អាហារមានមីក្រូសារជាតិ (មើលរូបភាព១៧, ១៨, និង១៩)។ ក្នុងឆ្នាំ២០១-៩២០២០ គ្រួសាររស់នៅភ្នំពេញ បរិភោគអាហារមានវីតាមីនអា ខ្ពស់ជាងគេបំផុត ប៉ុន្តែ បរិភោគអាហារមានជាតិដែក ទាបជាងគេបំផុត។ គ្រួសារដែលមានស្ត្រីជាមេគ្រួសារ បង្ហាញថា បាន បរិភោគអាហារមានវីតាមីនអា និងជាតិដែក ទាបជាងមធ្យមថ្នាក់ជាតិ។ ការបរិភោគស្បៀងអាហារសម្បូរប្រូតេអ៊ីនដែលបានពីសត្វ (រាប់ទាំងស៊ុត សាច់សត្វ និងត្រី) គឺមានភាគរយខ្ពស់នៅគ្រប់តំបន់ភូមិសាស្ត្រទាំងអស់។




*រូបភាព ១៧: ភាគរយនៃគ្រួសារបានប្រើប្រាស់វីតាមីន A*




*រូបភាព ១៨: ភាគរយនៃគ្រួសារបានប្រើប្រាស់អាហារមានប្រូតេអ៊ីនច្រើន*




*រូបភាព ១៩: ភាគរយនៃគ្រួសារបានប្រើប្រាស់អាហារមានជាតិដែក*

## ៣.៨ យុទ្ធសាស្ត្រដោះស្រាយផ្អែកលើការកាត់បន្ថយស្បៀងអាហារ

យុទ្ធសាស្ត្រដោះស្រាយផ្អែកលើការកាត់បន្ថយស្បៀងអាហារ គឺជាសូចនាករដ៏សំខាន់មួយរបស់ស្ថានភាពសន្តិសុខស្បៀងអាហាររបស់គ្រួសារ ដែលវាស់វែងពីឥរិយាបថរបស់គ្រួសារទាក់ទិននឹងការបរិភោគក្នុងអំឡុងពេលខ្វះខាតស្បៀងអាហារ។ អ្នកឆ្លើយតបត្រូវបានសួរអំពីយុទ្ធសាស្ត្រដោះស្រាយផ្អែកលើស្បៀងអាហារ ស្តង់ដារ ដែលពួកគេបានប្រើប្រាស់ដើម្បីដោះស្រាយភាពខ្វះខាតស្បៀង ឬខ្វះថវិកាដើម្បីទិញស្បៀងសម្រាប់គ្រួសាររបស់ពួកគេ ក្នុងរយៈពេល ៧មុនថ្ងៃចុះអង្កេត ។ សន្ទស្សន៍នៃយុទ្ធសាស្ត្រដោះស្រាយដោយកាត់បន្ថយការបរិភោគអាហារ(rCSI)គឺត្រូវបានគណនាចេញពីការរួមបញ្ចូលគ្នានៃចម្លើយរបស់សំណួរខាងលើ។ យុទ្ធសាស្ត្រដោះស្រាយតាមការកាត់បន្ថយការបរិភោគអាហារ (rCSI) របស់គ្រួសារកាន់តែខ្ពស់នោះ ឥរិយាបថនៃការដោះស្រាយកាន់តែធ្ងន់ធ្ងរ ហើយភាពងាយរងគ្រោះទៅនឹងអសន្តិសុខស្បៀងក៏កាន់តែខ្លាំង។




*រូបភាព២០៖ និន្នាការនៃមធ្យមភាគសន្ទស្សន៍យុទ្ធសាស្ត្រដោះស្រាយផ្អែកលើស្បៀងអាហារ(rCSI) បែងចែកតាមក្រុម ឆ្នាំ២០១៤-២០១៩/២០*

ការរកឃើញបង្ហាញថាសន្ទស្សន៍ដោះស្រាយផ្អែកលើការកាត់បន្ថយស្បៀងអាហារគឺមានភាពប្រសើរឡើងជាបន្តបន្ទាប់នៅចន្លោះឆ្នាំ២០១៤ និងឆ្នាំ២០១៩/២០ ដែលបង្ហាញពីសម្ពាធតិចលើគ្រួសារក្នុងការដោះស្រាយភាពខ្វះខាតស្បៀងអាហារ (ភាពខុសគ្នារវាងឆ្នាំទាំងអស់គឺមានន័យសមស្របតាមស្ថិតិ) (មើលរូបភាព២០)។ ជារួម មធ្យមភាគសន្ទស្សន៍ដោះស្រាយផ្អែកលើការកាត់បន្ថយស្បៀងអាហារបានថយចុះពី០,៥៦ ក្នុងឆ្នាំ២០១៤ ទៅ ០,១៣ ក្នុងឆ្នាំ២០១៩/២០ ប៉ុន្តែមានកម្រិតថយចុះតិចតាំងពីឆ្នាំ២០១៦មក (គឺខុសគ្នា០,០៣)។

ការប្រើប្រាស់យុទ្ធសាស្ត្រដោះស្រាយផ្អែកលើការកាត់បន្ថយស្បៀងអាហារគឺខ្ពស់បំផុតក្នុងចំណោមគ្រួសារដែលមានប័ណ្ណក្រីក្រនិងគ្រួសារដែលមានស្ត្រីជាមេគ្រួសារ និងទាបបំផុតក្នុងចំណោមគ្រួសារដែលរស់នៅទីប្រជុំជនជាពិសេសគ្រួសារដែលរស់នៅរាជធានីភ្នំពេញ។

ការវិភាគអំពីនិន្នាការបង្ហាញថាមានការថយចុះខ្លាំងនូវចំនួនគ្រួសារដែលប្រើប្រាស់យុទ្ធសាស្ត្រដោះស្រាយបញ្ហាយ៉ាងតិចមួយក្នុងចំណោមយុទ្ធសាស្ត្រដោះស្រាយផ្អែកលើស្បៀងអាហារទាំងប្រាំ (មើលរូប២១) ដោយមានតែមួយគ្រួសារក្នុងចំណោម ២០ គ្រួសារ (៥%) បានប្រើប្រាស់យុទ្ធសាស្ត្រយ៉ាងតិចមួយក្នុងឆ្នាំ២០១៩/២០ ធៀបនឹងឆ្នាំ២០១៤ ដែលមានមួយគ្រួសារក្នុងចំណោមប្រាំគ្រួសារ (១៩,៦%)។ ហើយក្នុងឆ្នាំ២០១៩/២០ មានគ្រួសារមិនលើសពី ២%ទេ ដែលបានប្រើប្រាស់យុទ្ធសាស្ត្រដោះស្រាយបញ្ហានីមួយៗ។




*រូបភាព២១៖ ភាគរយនៃគ្រួសារដែលប្រើប្រាស់យុទ្ធសាស្ត្រដោះស្រាយបញ្ហាផ្អែកលើស្បៀងអាហារឆ្នាំ២០១៤-២០១៩/២០*

ការវិភាគដោយបំបែកតាមតំបន់ឬក្រុមបង្ហាញថាគ្រួសារដែលមានប័ណ្ណក្រីក្រ បានកាត់បន្ថយការប្រើប្រាស់យុទ្ធសាស្ត្រដោះស្រាយបញ្ហាផ្អែកលើការកាត់បន្ថយអាហារបានច្រើនជាងគេចាប់ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៩/២០ គឺថយចុះចំនួន២៩ %។ និន្នការថយចុះនេះក៏មានបង្ហាញក្នុងគ្រួសារដែលមានស្ត្រីជាមេគ្រួសារ និងគ្រួសារដែលរស់នៅតំបន់ជនបទផងដែរ (មើលរូបភាព២២)។




*រូបភាព២២៖ ភាគរយនៃគ្រួសារ ដែលបានប្រើប្រាស់យ៉ាងហោចមួយយុទ្ធសាស្ត្រដោះស្រាយផ្អែកលើការបរិភោគស្បៀងអាហារ បែងចែកតាមក្រុម*

## ៣.៩ យុទ្ធសាស្ត្រដោះស្រាយបញ្ហាផ្អែកលើសកម្មភាពរស់នៅ

យុទ្ធសាស្ត្រដោះស្រាយផ្អែកលើសកម្មភាពរស់នៅ (សំដៅផងដែរដល់យុទ្ធសាស្ត្រកាត់បន្ថយទ្រព្យសកម្ម) ជាសូចនាករបង្ហាញពីលទ្ធភាពយុទ្ធសាស្ត្រដោះស្រាយរយៈពេលវែងរបស់គ្រួសារ។ គ្រួសារត្រូវបានសួរថាតើពួកគេបានប្រើប្រាស់យុទ្ធសាស្ត្រដោះស្រាយផ្អែកលើសកម្មភាពរស់នៅឬប្រកបរបរចិញ្ចឹមជិវិតណាខ្លះក្នុងអំឡុងពេល៣០ថ្ងៃមុនថ្ងៃចុះអង្កេត។ យុទ្ធសាស្ត្រដោះស្រាយទាំងនេះត្រូវបានបែងចែកជាផ្នែកៗតាមកម្រិតធ្ងន់ធ្ងររបស់វាដូចជា មិនបានប្រើប្រាស់ កម្រិតស្រាល(តានតឹង) កម្រិតមធ្យម(វិបត្តិ) និងកម្រិតធ្ងន់(អាសន្ន)។ យុទ្ធសាស្ត្រទាំងនេះអាចមានឥទ្ធិពលអវិជ្ជមានដល់លទ្ធភាពដោះស្រាយនិងភាពធន់រយៈពេលវែងរបស់គ្រួសារ ដែលនឹងអាចប៉ះពាល់ដល់ផលិតភាពនាពេលអនាគតរបស់ពួកគេ។ យុទ្ធសាស្ត្រដែលមានកម្រិតស្រាលឬតានតឹងចង្អុលបង្ហាញពីការថយចុះនូវលទ្ធភាពដោះស្រាយក្នុងពេលមានវិបត្តិនាពេលអនាគតដោយសារតែធនធានបច្ចុប្បន្នថយចុះឬបំណុលកើនឡើង។ ចំណែកយុទ្ធសាស្ត្រដែលកម្រិតមធ្យមឬវិបត្តិជារឿយៗទាក់ទិនដោយផ្ទាល់ទៅនឹងការធ្លាក់ចុះនូវផលិតភាពនាពេលអនាគត។ យុទ្ធសាស្ត្រដែលមាន កម្រិតធ្ងន់ធ្ងរឬអាសន្នក៏មានឥទ្ធិពលដល់ផលិតភាពនាពេលអនាគតដែរ ប៉ុន្តែវាមានសភាពធ្ងន់ធ្ងរឬធ្ងន់ជាបដាងយុទ្ធសាស្ត្រដែលមានវិបត្តិ។

របកគំហើញបង្ហាញថាក្នុងឆ្នាំ២០១៤ គ្រួសារប្រមាណ១៥% បានប្រើប្រាស់យុទ្ធសាស្ត្រដោះស្រាយបញ្ហាផ្អែកលើសកម្មភាពរស់នៅឬប្រកបរបរចិញ្ចឹមជីវិត ដែលយុទ្ធសាស្ត្រទាំងនោះភាគច្រើនស្ថិតក្នុងកម្រិតធ្ងន់ធ្ងរ។ ចន្លោះឆ្នាំ២០១៤ និងឆ្នាំ២០១៧ ភាគរយនៃគ្រួសារដែលបានប្រើប្រាស់យុទ្ធសាស្ត្រដោះស្រាយបញ្ហាផ្អែកលើសកម្មភាពរស់នៅ បានថយចុះគួរឱ្យកត់សម្គាល់ទៅ ៤% ក្នុងឆ្នាំ២០១៥ ទៅ ២% ក្នុងឆ្នាំ២០១៦ និងទៅ ១% ក្នុងឆ្នាំ២០១៧ ប៉ុន្តែបានកើនឡើងបន្តិចវិញ គឺទៅ ២% ក្នុងឆ្នាំ២០១៩/២០ (មើលរូបភាព២៣) (ភាពខុសគ្នាគឺមានន័យសំខាន់ស្ថិតិ)។ យុទ្ធសាស្ត្រដោះស្រាយដែលបានប្រើដោយគ្រួសារញឹកញាប់ជាងគេគឺយុទ្ធសាស្ត្រដែលមានកម្រិតស្រាលឬតានតឹង (ឧ. ការចំណាយប្រាក់ដែលបានសន្សំ និងខ្ចីប្រាក់ និងស្បៀងអាហារពីគេជាដើម) (មើលរូបភាព២៥)។




*រូបភាព២៣៖ ភាគរយនៃគ្រួសារដែលបានប្រើប្រាស់យុទ្ធសាស្ត្រផ្អែកលើសកម្មភាពរស់នៅ បែងចែកតាមឆ្នាំ*

ស្រដៀងគ្នាទៅនឹងស្ថានភាពប្រើប្រាស់យុទ្ធសាស្ត្រដោះស្រាយផ្អែកលើការកាត់បន្ថយស្បៀងអាហារដែរ គ្រួសារមានប័ណ្ណក្រីក្របានកាត់បន្ថយបានច្រើននូវការប្រើប្រាស់យុទ្ធសាស្ត្រដែលមានគ្រោះថ្នាក់ (កម្រិតធ្ងន់ធ្ងរឬអាសន្ន និងកម្រិតមធ្យមឬវិបត្តិ) ចន្លោះឆ្នាំ២០១៤ និងឆ្នាំ២០១៩/២០ គឺថយចុះចំនួន ៣៣,៥ចំណុចភាគរយ (មើលរូបភាព២៤)។




*រូបភាព២៤៖ ភាគរយនៃគ្រួសារដែលបានប្រើប្រាស់យុទ្ធសាស្ត្រដោះស្រាយផ្អែកលើសកម្មភាពរស់នៅ បែងចែកបែងចែកតាមក្រុម*




*រូបភាព២៥៖ ភាគរយនៃគ្រួសារដែលបានប្រើប្រាស់យុទ្ធសាស្ត្រដោះស្រាយផ្អែកលើសកម្មភាពរស់នៅ តាមយុទ្ធសាស្ត្រ*

## ៣.១០. ពិន្ទុនៃភាពអត់ឃ្លានតាមគ្រួសារ

ពិន្ទុនៃភាពអត់ឃ្លានក្នុងគ្រួសារ (HHS) អនុញ្ញាតិឱ្យគ្រួសារដែលមានបញ្ហាខ្វះខាតស្បៀងអាហារ ត្រូវបានគេវាយតម្លៃដោយការវាស់វែង និងព្យាយាមកំណត់ពីទស្សនៈនៃភាពអត់ឃ្លានក្នុងគ្រួសារមួយ។

របកគំហើញបង្ហាញថា ភាពអត់ឃ្លានមិនមែនជាបញ្ហាគំរាមកំហែងដល់គ្រួសារកម្ពុជាទេ។ ប៉ុន្តែក្នុងឆ្នាំ២០១៩/២០នៅមានគ្រួសារចំនួន២% ស្ថិតក្នុងស្ថានភាពអត់ឃ្លានមធ្យម និងធ្ងន់ធ្ងរ ដែលអត្រានេះខ្ពស់ជាងឆ្នាំ២០១៤ (០,៦%) ឆ្នាំ២០១៥ (១,២%) ឆ្នាំ២០១៦ (០,៥%) និងឆ្នាំ២០១៧ (០,២%)។




*រូបភាព ២៦៖ ភាគរយនៃគ្រួសារតាមចំណាត់ថ្នាក់ភាពអត់ឃ្លានរបស់គ្រួសារ*




*រូបភាព២៧៖ ភាគរយនៃគ្រួសារតាមចំណាត់ថ្នាក់ភាពអត់ឃ្លានរបស់គ្រួសារ បែងចែកតាមក្រុម*

## ៤.សេចក្តីសន្និដ្ឋាន និងអនុសាសន៍

### សន្តិសុខស្បៀងអាហារ

លទ្ធផលដែលបានមកពីវិធីសាស្ត្ររួមបញ្ចូលគ្នាមួយ សម្រាប់រាយការណ៍អំពីសូចនាករសន្តិសុខស្បៀង (CARI) បានបញ្ជាក់ថាមានគ្រួសារប្រហែល៧៥ភាគរយនៅប្រទេសកម្ពុជាមានសន្តិសុខស្បៀង និងមាន២៥ភាគរយ មានភាពងាយរងគ្រោះទៅនឹងអសន្តិសុខស្បៀងនៅឆ្នាំ២០១៩/២០ហើយអសន្តិសុខស្បៀងនៅប្រទេសកម្ពុជា គឺបណ្តាលមកពីភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ចជាចម្បង។ ទោះបីជាគ្រួសារភាគច្រើនមាន ពិន្ទុនៃការបរិភោគស្បៀងអាហារល្អឬអាចទទួលយកបាន និងមិនបានប្រើប្រាស់យុទ្ធសាស្ត្រដោះស្រាយ ដែលធ្វើឱ្យខូចប្រយោជន៍ក៏ដោយ ប៉ុន្តែសមាមាត្រនៃគ្រួសារជាច្រើនមានប្រាក់ចំណូលនៅទាប ព្រមទាំងលទ្ធភាពសេដ្ឋកិច្ចដើម្បីបំពេញតម្រូវការចាំបាច់របស់ពួកគេក៏នៅមានកម្រិតនៅឡើយ។ គ្រួសារទាំងនេះអាចធ្លាក់ចូលទៅក្នុងភាពអសន្តិសុខស្បៀងយ៉ាងងាយស្រួលក្នុងគ្រាមានវិបត្តិ ឬគ្រោះមហន្តរាយផ្សេងៗ ដូចជាទឹកជំនន់ តាមរដូវ ឫវិបត្តិប្រាក់ចំណូលដែលបណ្តាលមកពីជម្ងឺរាតត្បាត កូវីត១៩ និងការឡើងថ្លៃម្ហូបអាហារនៅពេលវិបត្តិអ៊ុយក្រែនកើតឡើង។

### ភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច

ជាមធ្យម គ្រួសារកម្ពុជាបានចំណាយប្រាក់ប្រហែលពាក់កណ្តាល (៤៨,៧ភាគរយ)នៃប្រាក់ចំណូលសរុបរបស់ពួកគេទៅលើម្ហូបអាហារ ហើយគ្រួសារដែលត្រូវបានចាត់ថ្នាក់ជាគ្រួសារក្រីក្របានចំណាយប្រាក់ស្បៀងអាហារច្រើនរហូតដល់៦០ភាគរយ។ បញ្ហានេះសំខាន់ណាស់ពីព្រោះ គ្រួសារដែលមានការបែងចែកចំណាយលើស្បៀងអាហារខ្ពស់ អាចឃើញពីលទ្ធភាព

របស់ពួកគេក្នុងការបំពេញតម្រូវការស្បៀងអាហារ និងអាហារូបត្ថម្ភចាំបាច់ ដែលត្រូវតែ សម្របសម្រួលការបរិភោគរបស់ពួកគេក្នុងគ្រាមានវិបត្តិតម្លៃ ឬប្រាក់ចំណូល។

ទោះបីជាមានភាពប្រសើរឡើងចាប់តាំងពីឆ្នាំ ២០១៧ ក៏ដោយ ក៏មានគ្រួសារកម្ពុជាចំនួន ២៣ភាគរយ មិនមានលទ្ធភាពផ្នែកសេដ្ឋកិច្ចដើម្បីបំពេញតម្រូវការចាំបាច់ របស់ពួកគេបាននៅឡើយ ដោយសារពួកគេមានការចំណាយនៅក្រោមបន្ទាត់នៃភាពក្រីក្រថ្នាក់ជាតិ។ គ្រួសារប្រហែល ៣ភាគរយ មិនអាចបំពេញតម្រូវការស្បៀងអាហាររបស់ពួកគេបានទេ ដោយសារតែការចំណាយរបស់ពួកគេនៅក្រោមខ្សែបន្ទាត់ភាពក្រីក្រនៃស្បៀងអាហារថ្នាក់ជាតិ ដែលកើនឡើងច្រើនជាងពីរភាគរយ ធៀបនឹងឆ្នាំ២០១៧។ ភាគរយនេះគឺ កើនឡើងដល់៥% ក្នុងចំណោមគ្រួសារដែលមានជនពិការ គ្រួសារត្រូវបានចាត់ថ្នាក់ជាគ្រួសារក្រីក្រ និងគ្រួសារដែលស្ត្រីជាមេគ្រួសារ ។

## ការបរិភោគស្បៀងអាហារ

តាមលទ្ធផលដែលបានមកពីការវិភាគទិន្នន័យអង្កេតសេដ្ឋកិច្ចសង្គមកិច្ច បង្ហាញថាកម្រិតនៃការបរិភោគស្បៀងអាហាររបស់ប្រជាជនកម្ពុជាដោយវាស់វែងតាមរយៈពិន្ទុនៃការបរិភោគស្បៀងអាហារ គឺមានលក្ខណៈគ្រប់គ្រាន់ពីព្រោះគ្រួសារកម្ពុជាភាគច្រើនបានបំពេញនូវតម្រូវការពិន្ទុនៃការបរិភោគស្បៀងអាហារដែលអាចទទួលយកបាន មានន័យថាពួកគេបរិភោគបរិមាណស្បៀងអប្បបរមានិងអាហារចម្រុះ។ តែទោះជាយ៉ាងនេះក្ដីក៏នៅមាន ការថយចុះតិចតួច ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០១៩/២០។ ពិន្ទុនៃការបរិភោគស្បៀងអាហារជាមធ្យមនៅទីប្រជុំជនមានកម្រិតខ្ពស់ ជាងនៅទីជនបទ នេះបញ្ជាក់ឱ្យឃើញថានៅទីប្រជុំជនមាន លទ្ធភាពទទួលបានស្បៀងប្រសើរជាងនៅទីជនបទ ហើយនៅទីក្រុងភ្នំពេញលទ្ធភាពទទួលបានស្បៀងមានកម្រិតខ្ពស់ជាងគេគ្រប់ឆ្នាំ(លើកលែងឆ្នាំ២០១៥)។ ខណៈពេលពិន្ទុនៃការបរិភោគស្បៀងអាហារក្នុងចំណោមគ្រួសារដែលមានស្ត្រីជាមេគ្រួសារមានកម្រិតទាបជាងថ្នាក់ជាតិនៅគ្រប់ឆ្នាំនៃការអង្កេត។ គេសង្កេតឃើញថានៅឆ្នាំ២០១៩/២០ វាក៏មានកម្រិតទាបជាងគ្រួសារ ដែលចាត់ថ្នាក់ជាគ្រួសារក្រីក្រទៅទៀត ។

គ្រួសារកម្ពុជាបរិភោគអាហារមូលដ្ឋានសំខាន់(ជាពិសេសបាយ) ប្រូតេអ៊ីននៅក្នុងសាច់សត្វ (ជាពិសេសត្រីទឹកសាប) និងគ្រឿងផ្សំផ្សេងៗ (ទឹកត្រី ទឹកស៊ីអ៊ីវ,,,។ល។) ជាប្រចាំរាល់ថ្ងៃ។ ផ្អែកតាមអង្កេតនៅឆ្នាំ២០១៩/២០ ចំនួនថ្ងៃនៃការបរិភោគ ប្រេងឆា/ខ្លាញ់សត្វនិងស្ករមានការកើនឡើងគួរឱ្យកត់សម្គាល់បើប្រៀបនឹងឆ្នាំមុនៗ ជាពិសេសនៅទីក្រុងភ្នំពេញដែលនេះប្រហែលជាអាចប្រឈមនឹងវិបត្តលើសទម្ងន់និង ជំងឺមិនឆ្លងផ្សេងៗទៀត។ ទឹកដោះគោស្រស់និងផលិតផលធ្វើពីទឹកដោះក៍មានការបរិភោគជាញឹកញាប់ជាងមុនផងដែរនៅឆ្នាំ២០១៩/២០ ដែលចំនួនថ្ងៃនៃការបរិភោគខ្ពស់ជាងគេបំផុត គឺនៅក្នុងចំណោមគ្រួសារដែលរស់នៅទីក្រុងភ្នំពេញ។ ខណៈពេលជាមធ្យមគ្រួសារបរិភោគផ្លែឈើ ញឹកញាប់ជាងមុននោះ ការបរិភោគបន្លែបៃជាមាននិន្នាការធ្លាក់ចុះ។

ទោះបីជាមធ្យមភាគនៃការបរិភោគត្រី និងសាច់ក្រហមរបស់ប្រជាជនកម្ពុជាមានលក្ខណៈលើសពីចំនុចដៅនៃរបបអាហារតាមអនុសាសន៍ក៏ដោយ ក៏ការបរិភោគអាហារចម្បងៗផ្សេងៗទៀតព្រមទាំងសារជាតុចិញ្ចឹមគឺស្ថិតនៅក្រោមកម្រិតអនុសាសន៍/ណែនាំនៅឡើយ សម្រាប់អាហារទាំងនោះ រួមមានទាំងគ្រាប់សណ្តែកមាន(៤ភាគរយនៃការ បរិភោគតាមការណែនាំ) គ្រាប់សណ្តែកដីមាន(៦ភាគរយ) ផលិតផលធ្វើពីទឹកដោះគោមាន(១០ភាគរយ) គ្រាប់ធញ្ញជាតិគ្រប់មុខមាន(១៣

ភាគរយ) ផ្លែឈើមាន(២៤ភាគរយ) និងបន្លែមាន(៣៩ភាគរយ)[10] ។ ទាំងនេះបង្ហាញឱ្យឃើញថាក្រៅពីកម្រិតនៃការបរិភោគស្បៀងអាហារដែលអាចទទួលយកបានជាទូទៅនោះ កម្រិតរបបអាហារដែលមានសុខភាពប្រហែលជានៅទាបនៅឡើយ។

## គុណភាពរបបអាហារ

លទ្ធផលចង្អុលបង្ហាញ គុណភាពរបបអាហារនៅឆ្នាំ២០១៩/២០ មានភាពយ៉ាប់យ៉ឺនជាងមុនដោយសារទាំង របបអាហារចម្រុះនិង ការបរិភោគមីក្រូសារជាតិសំខាន់ៗ (រួមមាន វីតាមីនអេ ជាតិដែក) មានការធ្លាក់ចុះ។ ស្រដៀងគ្នាទៅ នឹងពិន្ទុនៃការបរិភោគស្បៀងអាហារដែរ របបអាហារចម្រុះនៅតែរក្សាបាននៅកម្រិតខ្ពស់នៅទីក្រុងភ្នំពេញដែលមានប្រហែលជា១ភាគ ៤ នៃគ្រួសារបង្ហាញពី របបអាហារចម្រុះកម្រិតខ្ពស់ ទោះបីជា របបអាហារចម្រុះនៅតំបន់ផ្សេងទៀតមានភាពយ៉ាប់យ៉ឺនជាងមុន។

ការវិភាគគុណភាពអាហាររូបត្ថម្ភបង្ហាញថា ការបរិភោគស្បៀងអាហារដែលសម្បូរដោយវីតាមីនអា និងជាតិដែក បានធ្លាក់ចុះជាពិសេសនៅតំបន់ទីប្រជុំជន។ បញ្ហានេះគឺសំខាន់ណាស់ ពីព្រោះបញ្ហាកង្វះមីក្រូសារជាតិដូចជាវីតាមីនអា និងជាតិដែករយៈពេលយូរនោះគឺបណ្តាលឱ្យមានបញ្ហាខ្វះអាហាររូបត្ថម្ភពុំរ៉ៃ។ នៅឆ្នាំ២០១៩/២០ ស្ទើរតែ ១ភាគ៥ ស្មើនិង (១៩,២%) នៃគ្រួសារគឺមិនបានបរិភោគអាហារដែលមានជាតិដែកទៀងទាត់ទេ(មានដូចជាត្រី សាច់សត្វ សាច់បក្សី) ដែលអាចធ្វើឱ្យពួកគេប្រឈម នឹងការកើនឡើងនូវជម្ងឺស្លេកស្លាំង និងមានគ្រួសារជាង១ភាគ៤ ស្មើរនឹង (២៥,៥ភាគរយ) មិនបានបរិភោគអាហារដែលមានវីតាមីនអា ទៀងទាត់ទេ(មានដូចជាផ្លែឈើ និងបន្លែពណ៌ទឹកក្រូចផ្សេងៗ) ដែលអាចធ្វើឱ្យមានផលប៉ះពាល់ដល់មុខងារប្រព័ន្ធការពាររាង្គកាយ រាង្គកាយមិនសូវលូតលាស់ និងអភិវឌ្ឍ ព្រមទាំងផលិតភាពផងដែរ។

## ការអនុវត្តចំពោះអាហាររូបត្ថម្ភ

និន្នាការដែលបានសង្កេតចង្អុលបង្ហាញពីការផ្លាស់ប្តូរបន្តិចម្តងៗនូវរបបអាហាររបស់ប្រជាជនកម្ពុជាឆ្ពោះទៅរកការបរិភោគស្បៀងអាហារដែលមានផ្ទុកជាតិខ្លាញ់ និងស្ករច្រើន មានដូចជាអាហារកែច្នៃនិងអាហារទុកបានយូរ ប៉ុន្តែមិនសូវបរិភោគបន្លែញឹកញាប់ទេ នេះជាការអភិវឌ្ឍន៍ដែលកំពុងជម្រុញឱ្យមានបន្ទុកដល់ទៅបីដងនៃ កង្វះអាហាររូបត្ថម្ភនៅប្រទេសកម្ពុជា មានន័យថាការរស់នៅជាមួយភាពកង្វះអាហាររូបត្ថម្ភជាប់ជាយូរយារមកហើយ និងកង្វះមីក្រូសារជាតិ រួមជាមួយនឹងការលេចឡើងនូវការលើសអាហារូបត្ថម្ភ ដែលកើតឡើងព្រមគ្នាក្នុងចំណោមប្រជាជនតែមួយ។ ជាឧទាហរណ៍ មានសមាមាត្រកុមារ អាយុក្រោម៥ឆ្នាំជាច្រើន ដែលលើសទម្ងន់គឺជាកុមារក្រេះក្រិនផងដែរ ដែលវាចង្អុលឱ្យឃើញពីភាពសម្បូរបែបនៃអាហារប៉ុន្តែកង្វះសារជាតិចិញ្ចឹមធ្ងន់ធ្ងរ[11] ។ សមាមាត្រ កុមារដែលមានអាយុក្រោម៥ឆ្នាំជាច្រើននៅតែមានភាពក្រេះក្រិន(កង្វះអាហាររូបត្ថម្ភពុំរ៉ៃ) មាន(២២ភាគរយ) ឬស្គមស្គាំង(កង្វះអាហាររូបត្ថម្ភស្រួចស្រាល) មាន(១០ភាគរយ)[12] ។ អត្រាប្រេវ៉ាឡង់នៃការលើសទម្ងន់និងជម្ងឺធាត់របស់មនុស្សពេញវ័យបាន កើនឡើង ហើយត្រូវបានគេព្យាករណ៍ថានឹងកើនឡើងបន្ថែមទៀតនៅក្នុងប៉ុន្មានឆ្នាំខាងមុខនេះ ដោយស្ត្រីនឹងរងផលប៉ះពាល់ច្រើន។

របកគំហើញពីការធ្វើអង្កេតសេដ្ឋកិច្ច សង្គមកិច្ចបង្ហាញ ពីការធ្លាក់ចុះនូវគុណភាពនៃរបបអាហារ នេះត្រូវបានឆ្លុះបញ្ចាំងពីការពិតរបស់ប្រទេសកម្ពុជាដែលមានការវិវត្តន៍តិចតួចឆ្ពោះទៅការសម្រេចបាននូវគោលដៅអាហាររូបត្ថម្ភជាសាកល

---

[10] https://globalnutritionreport.org/resources/nutrition-profiles/asia/south-eastern-asia/cambodia/#:~:text=Cambodia's%20obesity%20prevalence%20is%20lower,women%20and%207.5%25%20for%20men.

[11] Ibid.

[12] National Institute of Statistics [Cambodia], Ministry of Health [Cambodia] and ICF. 2022. *Cambodia Demographic and Health Survey 2021–22 Key Indicators Report*.

មួយចំនួនរបស់ខ្លួន រួមទាំងផ្នែកដែលទាក់ទងនឹងការកាត់បន្ថយអត្រាប្រេវ៉ាឡង់នៃភាពស្លេកស្លាំង ដែលនៅតែបន្តប៉ះពាល់ដល់ជាងពាក់កណ្តាល (៥១,៥ភាគរយ) នៃស្ត្រីក្នុងវ័យបន្តពូជ និងកុមារស្គមស្គាំង ហើយនៅទ្រឹងតាំងពីឆ្នាំ ២០១៤។ របបអាហារ និងទម្ងន់រាងកាយ គឺជាកត្តាកំណត់ដ៏សំខាន់នៃស្ថានភាពអាហារូបត្ថម្ភ និង សុខភាពក៏ដូចជាអត្រាមរណៈរបស់បុគ្គលម្នាក់ៗ។

## ឥរិយាបទដោះស្រាយបញ្ហាតាមបែបអវិជ្ជមាន

ទិន្នន័យបង្ហាញថាការអនុវត្តយន្តការដោះស្រាយបញ្ហាតាមបែបអវិជ្ជមាននៅឆ្នាំ២០១៩/២០ គឺមានលក្ខណៈស្រដៀងគ្នាច្រើនទៅនឹងឆ្នាំ២០១៧ ដែលមានគ្រួសារត្រឹមតែ២,៥ភាគរយប៉ុណ្ណោះដែលអនុវត្តន៍យុទ្ធសាស្ត្រដោះស្រាយបញ្ហាផ្អែកលើការកាត់បន្ថយអាហារជាមូលដ្ឋាន និងមានគ្រួសារត្រឹមតែ២ភាគរយប៉ុណ្ណោះដែលអនុវត្តន៍យុទ្ធសាស្ត្រដោះស្រាយបញ្ហាដោយផ្អែកលើសកម្មភាពរស់នៅឬការប្រកបរបរចិញ្ចឹមជីវិត។ គ្រួសារដែលមានស្ត្រីជាមេគ្រួសារនិងគ្រួសារក្រីក្រទំនងជាងាយទទួលយកយន្តការដោះស្រាយបញ្ហាតាមបែបអវិជ្ជមាន។ ប៉ុន្តែ វាជារឿងសំខាន់ដែលត្រូវចងចាំថា តួលេខទាំងនេះសំដៅទៅលើពេលវេលាមុនការរាតត្បាតនៃជំងឺរាតត្បាត ហើយការទទួលយកឬប្រើប្រាស់យន្តការដោះស្រាយបញ្ហាតាមបែបអវិជ្ជមាននេះ បានកើនឡើងគួរឱ្យកត់សម្គាល់ក្នុងអំឡុងពេលជំងឺរាតត្បាតកូវីដ១៩។

## ពិនិត្យវិភាគឱ្យស៊ីជម្រៅ

ការវិភាគតាមកម្រិតបែងចែកបង្ហាញលទ្ធផលថា មានភាពខុសគ្នា ច្រើនគួរឱ្យកត់សម្គាល់នៅក្នុងសូចនាករសន្តិសុខស្បៀង និងអាហារូបត្ថម្ភភាគច្រើនបំផុតរវាងគ្រួសារដែលរស់នៅក្នុងទីក្រុងភ្នំពេញ និងគ្រួសាររស់នៅតំបន់ទីប្រជុំជនផ្សេងទៀតនិងគ្រួសាររស់នៅទីជនបទ ។ ជាមធ្យម គ្រួសារដែលរស់នៅក្នុងរាជធានីមានលទ្ធភាពទទួលបានអាហារដែលមានសារជាតិចិញ្ចឹមឬអាហារូបត្ថម្ភប្រសើរជាងគ្រួសារនៅក្នុងតំបន់ផ្សេងទៀតនៃប្រទេស ដោយសារអ្នករស់នៅរាជធានីភាពមានស្បៀងអាហារចម្រុះប្រសើរជាង និងប្រាក់ចំណូលគ្រួសារខ្ពស់ជាង។ ផ្ទុយទៅវិញ គ្រួសារដែលស្ត្រីជាមេគ្រួសារ និងគ្រួសារដែលមានសមាជិកមានពិការភាព គឺស្ថានភាពភាពមានស្បៀងអាហារចម្រុះ និងប្រាក់ចំណូលគ្រួសារទាបខ្លាំង(ឆ្ងាយដាច់)ជាងមធ្យមភាគថ្នាក់ជាតិស្ទើរតែគ្រប់សូចនាករទាំងអស់ ។

គ្រួសារដែលមានអត្តសញ្ញាណប័ណ្ណក្រីក្របានបោះជំហានទៅមុខយ៉ាងខ្លាំងក្នុងអំឡុងពេលប៉ុន្មានឆ្នាំកន្លងមកនេះ ទាក់ទិននឹងសន្តិសុខស្បៀង។ មានគ្រួសារជាច្រើនទទួលបានរបបអាហារចម្រុះ និងសម្បូរបែប ដែលមិនសូវខុសគ្នាខ្លាំងពីមធ្យមភាគថ្នាក់ជាតិទេប៉ុន្តែពួកគេបានប្រើប្រាស់យុទ្ធសាស្ត្រដោះស្រាយបញ្ហាតាមបែបអវិជ្ជមាន និងលទ្ធភាពសេដ្ឋកិច្ចនៅមានកម្រិតទាប។ ការរកឃើញបានបង្ហាញថាមាន៣០ភាគរយនៃគ្រួសារក្រីក្រ មានការចំណាយក្រោមខ្សែបន្ទាត់ភាពក្រីក្រថ្នាក់ជាតិ ហើយចំណាយ ៦០ភាគរយ នៃប្រាក់ចំណូលសរុបរបស់ពួកគេលើស្បៀងអាហារ ដើម្បីលៃលក ឬសម្របសម្រួលតាមលទ្ធភាពរបស់ពួកគេក្នុងការបំពេញតម្រូវការចាំបាច់នានា ជាពិសេសនៅក្នុងគ្រានៃវិបត្តិប្រាក់ចំណូល ឬទំនិញឡើងថ្លៃដែលពេលនោះពួកគេអាចបង្ខំចិត្តផ្តល់អាទិភាពលើធនធានកម្រ ឬស្តួចស្តើងរបស់ពួកគេ។

## សេចក្តីសន្និដ្ឋាន

បន្ទាប់ពីមាន និន្នាការវិជ្ជមានភាគច្រើនក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ទិន្នន័យអង្កេតសេដ្ឋកិច្ចសង្គមកិច្ចឆ្នាំ២០១៩/២០ បង្ហាញពីការបញ្ច្រាស់គ្នាតិចតួចលើសូចនាករសន្តិសុខស្បៀង និងអាហារូបត្ថម្ភមួយចំនួននៅក្នុងប្រទេសកម្ពុជាបើប្រៀបធៀបទៅនឹងឆ្នាំ២០១៧ដែលសូចនាករទាំងនោះរួមមានការបរិភោគស្បៀងអាហាររបបអាហារចម្រុះ និងការបរិភោគមីក្រូសារជាតិ។ ទោះបីជាយ៉ាងណាក៏ដោយ សន្តិសុខស្បៀងជារួមត្រូវបានវាស់វែងដោយវិធីសាស្ត្ររួមបញ្ចូលគ្នាសម្រាប់រាយការណ៍សូចនាករ

សន្តិសុខស្បៀង (CARI) មានភាពប្រសើរឡើងនូវលទ្ធភាពផ្នែកសេដ្ឋកិច្ច ជាពិសេសសម្រាប់គ្រួសារក្រីក្រនិងគ្រួសារដែលមានសមាជិកមានពិការភាព។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ក៏នៅមានប្រមាណ ២៥ភាគរយ នៃគ្រួសារកម្ពុជានៅតែងាយរងគ្រោះដោយអសន្តិសុខស្បៀងពីព្រោះលទ្ធភាពផ្នែកសេដ្ឋកិច្ចនៅមានកម្រិតទាប ជាយូរមកហើយ (ធៀបនឹងឆ្នាំ២០១៧ មាន២៩ភាគរយ)។

ការរកឃើញពីអង្កេតសេដ្ឋកិច្ចសង្គមកិច្ចឆ្នាំ២០១៩/២០ អាចបង្ហាញពីភាពលំអៀងនៃការយល់ឃើញយ៉ាងទូលំទូលាយជុំវិញសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា ខណៈពេលដែលភាពអត់ឃ្លានជាទូទៅមិនមែនជាការព្រួយបារម្ភនោះ "**ភាពអត់ឃ្លានដែលមិនបញ្ចេញឱ្យឃើញ**" ពោលគឺកង្វះមីក្រូសារជាតិសំខាន់ៗ និងជម្ងឺស្គមស្គាំងលើកុមារ គឺជាបញ្ហាសុខភាពសាធារណៈដ៏សំខាន់។ ដូច្នេះហើយ ប្រជាជនកម្ពុជាភាគច្រើន ប្រហែលជាមិនបានចាត់ទុករបបអាហារដែលមានសុខភាពល្អជាអាទិភាពនៅឡើយ ខណៈដែលអាហារទាំងនោះក៏អាចថ្លៃហួសសមត្ថភាពសម្រាប់ពលរដ្ឋមួយចំនួនទៀតផង ដូចលទ្ធផលស្តីពីភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ចបានបង្ហាញ។ ការបង្កើនការវិនិយោគសាធារណៈទៅលើការស្វែងរកភស្តុតាងនានា និងការលើកកម្ពស់ការយល់ដឹង ជុំវិញរបបអាហារដែលធ្វើឱ្យមានសុខភាពល្អ និងអត្ថប្រយោជន៍របស់វា ក៏ដូចជាជម្រើសឆ្លើយតបសមស្រប ដូចជាការបញ្ចូលមីក្រូសារជាតិទៅក្នុងអង្ករ និងការពង្រីកការការពារ និងការព្យាបាលជម្ងឺស្គមស្គាំង ទាំងនេះជាតម្រូវការចាំបាច់របស់ប្រទេសកម្ពុជាដើម្បីសម្រេចបាននូវគោលដៅអាហារូបត្ថម្ភនៅឆ្នាំ២០៣០។

# ឧបសម្ព័ន្ធ

## សង្ខេបសូចនាករនៃសន្តិសុខស្បៀងអាហារ និងអាហារូបត្ថម្ភ ( FSN )

# ឧបសម្ព័ន្ធ: សង្ខេបសូចនាករនៃសន្តិសុខស្បៀងអាហារ និងអាហារូបត្ថម្ភ ( FSN )

## ១.១ សន្ទស្សន៍សន្តិសុខស្បៀងអាហារ

| បរិកលក្ខណៈជាប្រវត្តិ | អសសក២០១៤ | | | | អសសក២០១៥ | | | |
|---|---|---|---|---|---|---|---|---|
| | មានសន្តិសុខស្បៀង | ងាយរងគ្រោះទៅនឹងអសន្តិសុខស្បៀង | មានអសន្តិសុខស្បៀងមធ្យម | មានអសន្តិសុខស្បៀងធ្ងន់ធ្ងរ | មានសន្តិសុខស្បៀង | ងាយរងគ្រោះទៅនឹងអសន្តិសុខស្បៀង | មានអសន្តិសុខស្បៀងមធ្យម | មានអសន្តិសុខស្បៀងធ្ងន់ធ្ងរ |
| **កម្ពុជា** | **៤២,៨%** | **៥៣,៤%** | **៣,៧%** | **0,១%** | **៦0,៤%** | **៣៨,៧%** | **0,៩%** | **0,0%** |
| **ភូមិសាស្ត្រ/តំបន់** | | | | | | | | |
| ទីប្រជុំជន | ៥៤,៥% | ៤២,៩% | ២,៥% | 0,១% | ៧៤,៩% | ២៣,៥% | 0,៦% | 0,0% |
| ទីជនបទ | ៣៦,៥% | ៥៩,១% | ៤,៣% | 0,១% | ៥៤,៨% | ៤៤,២% | ១,0% | 0,0% |
| ភ្នំពេញ | ៧៤,៣% | ២៤,៥% | ១,២% | 0,0% | ៨៣,២% | ១៦,៧% | 0,២% | 0,0% |
| **តំបន់ភូមិសាស្ត្រ** | | | | | | | | |
| ទំនាបកណ្តាល | ៣៩,៤% | ៥៦,៣% | ៤,៣% | 0,0% | ៥៨,៨% | ៣៩,៩% | ១,៤% | 0,0% |
| ខ្ពង់រាបនិងភ្នំ | ៣៧,៦% | ៥៧,២% | ៤,៩% | 0,៤% | ៥១,៤% | ៤៧,២% | ១,៤% | 0,0% |
| ទន្លេសាប | ៣៨,៧% | ៥៧,២% | ៤,១% | 0,0% | ៥៧,៦% | ៤១,៩% | 0,៥% | 0,0% |
| ឆ្នេរនិងសមុទ្រ | ៣៨,៥% | ៦0,២% | ១,៣% | 0,0% | ៦0,៦% | ៣៩,៤% | 0,0% | 0,0% |
| ភ្នំពេញ | ៧៤,៣% | ២៤,៥% | ១,២% | 0,0% | ៨៣,២% | ១៦,៧% | 0,២% | 0,0% |
| **ភាពជាមេគ្រួសារ** | | | | | | | | |
| បុរស | ៤៣,៣% | ៥៣,៣% | ៣,៣% | 0,១% | ៦១,0% | ៣៨,២% | 0,៨% | 0,0% |
| ស្ត្រី | ៤១,២% | ៥៣,៥% | ៥,២% | 0,១% | ៥៨,៤% | ៤0,៤% | ១,២% | 0,0% |
| **អាយុមេគ្រួសារ** | | | | | | | | |
| < ៣0 | ៤0,១% | ៥៥,២% | ៤,៦% | 0,២% | ៥៥,៣% | ៤២,៤% | ២,៣% | 0,0% |
| ៣0 - ៣៩ | ៣៨,៦% | ៥៧,៩% | ៣,៥% | 0,0% | ៥៦,៤% | ៤២,៧% | 0,៩% | 0,0% |
| ៤0 - ៤៩ | ៤៥,១% | ៥១,៥% | ៣,៣% | 0,១% | ៦២,៦% | ៣៦,៨% | 0,៦% | 0,0% |
| ៥0 - ៥៩ | ៤៥,៧% | ៥១,៤% | ២,៨% | 0,១% | ៦៣,៩% | ៣៥,៦% | 0,៦% | 0,0% |
| ៦0+ | ៤៣,0% | ៥១,៩% | ៥,១% | 0,១% | ៥៩,៦% | ៣៩,៤% | ១,0% | 0,0% |
| **កម្រិតសិក្សាអប់រំមេគ្រួសារ** | | | | | | | | |
| គ្មាន ឬមានការសិក្សាអប់រំតិចតួច | ២៧,៤% | ៦៥,៨% | ៦,៧% | 0,១% | ៤៨,២% | ៥0,៦% | ១,២% | 0,0% |
| មិនបានបញ្ចប់កម្រិតបឋមសិក្សា | ៣៧,៥% | ៥៨,៥% | ៣,៩% | 0,១% | ៥៥,១% | ៤៤,១% | 0,៨% | 0,0% |
| បានបញ្ចប់កម្រិតបឋមសិក្សា | ៤៧,៥% | ៥0,១% | ២,៥% | 0,0% | ៦៣,៨% | ៣៥,៣% | 0,៩% | 0,0% |
| បានបញ្ចប់កម្រិតមធ្យមសិក្សាបឋមភូមិ | ៥៨,៦% | ៣៩,៨% | ១,៤% | 0,១% | ៧៧,៧% | ២១,៧% | 0,៦% | 0,0% |
| បានបញ្ចប់កម្រិតមធ្យមសិក្សាទុតិយភូមិ | ៧២,៤% | ២៦,0% | ១,៧% | 0,0% | ៨៤,៣% | ១៥,៥% | 0,៣% | 0,0% |
| ការសិក្សាអប់រំក្រោយមធ្យមសិក្សា | ៨២,៨% | ១៦,២% | ១,0% | 0,0% | ៩៤,៨% | ៥,២% | 0,0% | 0,0% |
| **ទំហំគ្រួសារ** | | | | | | | | |
| ១ ដល់ ៣ | ៥៥,៨% | ៤0,៣% | ៣,៨% | 0,១% | ៧៥,៦% | ២៣,៧% | 0,៧% | 0,0% |
| ៤ ដល់ ៥ | ៤២,៥% | ៥៤,៤% | ៣,១% | 0,0% | ៦១,0% | ៣៨,0% | ១,0% | 0,0% |
| ៦+ | ២៧,៥% | ៦៧,៤% | ៤,៩% | 0,២% | ៤១,៤% | ៥៧,៨% | 0,៧% | 0,0% |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| គ្រួសារមានបណ្ណក្រីក្រ | | | | | | | | |
| ទេ | ៤៥,៨% | ៥១,៤% | ២,៧% | ០,០% | ៦៤,៥% | ៣៥,០% | ០,៥% | ០,០% |
| បាទ/ចាស | ១៧,៣% | ៦៩,៧% | ១២,៦% | ០,៤% | ៣២,៣% | ៦៤,៥% | ៣,២% | ០,០% |
| គ្រួសារមានសមាជិកមានពិការភាព | | | | | | | | |
| ទេ | ៤៤,២% | ៥២,៤% | ៣,៣% | ០,១% | | | | |
| បាទ/ចាស | ៣៤,៩% | ៥៨,៩% | ៦,១% | ០,១% | | | | |

## ១.១ សន្ទស្សន៍សន្តិសុខស្បៀងអាហារ ( ត )

| ចរិកលក្ខណៈជាប្រវត្តិ | អសសក២០១៦ | | | | អសសក២០១៧ | | | | អសសក២០១៩/២០ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | មានសន្តិសុខស្បៀង | ងាយរងគ្រោះទៅនឹងអសន្តិសុខស្បៀង | មានអសន្តិសុខស្បៀងមធ្យម | មានអសន្តិសុខស្បៀងធ្ងន់ធ្ងរ | មានសន្តិសុខស្បៀង | ងាយរងគ្រោះទៅនឹងអសន្តិសុខស្បៀង | មានអសន្តិសុខស្បៀងមធ្យម | មានអសន្តិសុខស្បៀងធ្ងន់ធ្ងរ | មានសន្តិសុខស្បៀង | ងាយរងគ្រោះទៅនឹងអសន្តិសុខស្បៀង | មានអសន្តិសុខស្បៀងមធ្យម | មានអសន្តិសុខស្បៀងធ្ងន់ធ្ងរ |
| **កម្ពុជា** | **៧០,១%** | **២៩,៦%** | **០,៣%** | **០,០%** | **៧១,០%** | **២៨,៥%** | **០,៤%** | **០,០%** | **៧៥,៥%** | **២៤,០%** | **០,៥%** | **០,០%** |
| ភូមិសាស្ត្រ/តំបន់ | | | | | | | | | | | | |
| ទីប្រជុំជន | ៨០,៦% | ១៨,៩% | ០,៥% | ០,០% | ៨០,១% | ១៩,៦% | ០,៣% | ០,០% | ៧៩,៦% | ២០,១% | ០,២% | ០,០% |
| ទីជនបទ | ៦៥,៦% | ៣៤,១% | ០,៣% | ០,០% | ៦៧,៣% | ៣២,១% | ០,៥% | ០,០% | ៦៩,៩% | ២៩,៤% | ០,៧% | ០,០% |
| ភ្នំពេញ | ៩០,៩% | ៩,១% | ០,០% | ០,០% | ៨៨,៣% | ១១,៧% | ០,០% | ០,០% | ៩២,៦% | ៧,៤% | ០,០% | ០,០% |
| តំបន់ភូមិសាស្ត្រ | | | | | | | | | | | | |
| ទំនាបកណ្តាល | ៧០,៧% | ២៩,០% | ០,២% | ០,០% | ៧១,៨% | ២៨,០% | ០,២% | ០,០% | ៧៤,១% | ២៥,៤% | ០,៥% | ០,០% |
| ខ្ពង់រាបនិងភ្នំ | ៦៣,៣% | ៣៥,៥% | ១,២% | ០,០% | ៦៩,២% | ២៩,៦% | ០,៩% | ០,០% | ៧១,៧% | ២៧,៣% | ១,០% | ០,០% |
| ទន្លេសាប | ៦៣,២% | ៣៦,៧% | ០,២% | ០,០% | ៦៤,៥% | ៣៥,០% | ០,៦% | ០,០% | ៦៨,៧% | ៣០,៩% | ០,៤% | ០,០% |
| ឆ្នេរនិងសមុទ្រ | ៧៥,២% | ២៤,៨% | ០,០% | ០,០% | ៧០,៩% | ២៨,៤% | ០,៦% | ០,០% | ៨៤,០% | ១៥,៧% | ០,៣% | ០,០% |
| ភ្នំពេញ | ៩០,៩% | ៩,១% | ០,០% | ០,០% | ៨៨,៣% | ១១,៧% | ០,០% | ០,០% | ៩២,៦% | ៧,៤% | ០,០% | ០,០% |
| ភាពជាមេគ្រួសារ | | | | | | | | | | | | |
| បុរស | ៦៩,៩% | ២៩,៨% | ០,៣% | ០,០% | ៧០,៦% | ២៩,១% | ០,៣% | ០,០% | ៧៦,៨% | ២២,៨% | ០,៤% | ០,០% |
| ស្ត្រី | ៧០,៩% | ២៩,០% | ០,២% | ០,០% | ៧២,៥% | ២៦,៥% | ១,០% | ០,០% | ៧០,៨% | ២៨,៣% | ០,៩% | ០,០% |
| អាយុមេគ្រួសារ | | | | | | | | | | | | |
| < ៣០ | ៦៩,៧% | ២៩,៧% | ០,៦% | ០,០% | ៧៦,១% | ២៣,២% | ០,២% | ០,៤% | ៧៧,៥% | ២១,៩% | ០,៦% | ០,០% |
| ៣០ - ៣៩ | ៦៦,៤% | ៣៣,៦% | ០,០% | ០,០% | ៦៦,៩% | ៣២,៤% | ០,៧% | ០,០% | ៧៤,៩% | ២៤,៦% | ០,៥% | ០,០% |
| ៤០ - ៤៩ | ៧១,៣% | ២៨,៣% | ០,៤% | ០,០% | ៧៣,០% | ២៦,៨% | ០,១% | ០,០% | ៧៨,៥% | ២១,១% | ០,៤% | ០,០% |
| ៥០ - ៥៩ | ៧១,៩% | ២៧,៩% | ០,២% | ០,០% | ៧០,៣% | ២៩,៣% | ០,៥% | ០,០% | ៧៥,០% | ២៤,៦% | ០,៤% | ០,០% |
| ៦០+ | ៧១,០% | ២៨,៦% | ០,៤% | ០,០% | ៧២,៦% | ២៧,០%% | ០,៤% | ០,០% | ៧៣,១% | ២៦,៤% | ០,៥% | ០,០% |
| កម្រិតសិក្សាអប់រំមេគ្រួសារ | | | | | | | | | | | | |
| គ្មាន ឬមានការសិក្សាអប់រំតិចតួច | ៥៧,៣% | ៤១,៩% | ០,៨% | ០,០% | ៥៤,៦% | ៤៤,១% | ១,៣% | ០,០% | ៦០,៣% | ៣៨,២% | ១,៥% | ០,០% |
| មិនបានបញ្ចប់កម្រិតបឋមសិក្សា | ៦៥,១% | ៣៤,៦% | ០,៣% | ០,០% | ៦៦,៦% | ៣២,៩% | ០,៤% | ០,០% | ៧១,៣% | ២៨,៤% | ០,៣% | ០,០% |
| បានបញ្ចប់កម្រិតបឋមសិក្សា | ៧៣,៩% | ២៦,០% | ០,២% | ០,០% | ៧៦,៩% | ២៣,០% | ០,១% | ០,០% | ៨០,២% | ១៩,៤% | ០,៣% | ០,០% |
| បានបញ្ចប់កម្រិតមធ្យមសិក្សាបឋមភូមិ | ៨០,២% | ១៩,៦% | ០,៣% | ០,០% | ៨៤,២% | ១៥,៨% | ០,០% | ០,០% | ៨៨,៨% | ១១,០% | ០,២% | ០,០% |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| បានបញ្ចប់កម្រិតមធ្យមសិក្សាទុតិយភូមិ | ៩១,៧% | ៨,៣% | 0,0% | 0,0% | ៩0,២% | ៩,៨% | 0,0% | 0,0% | ៩0,៥% | ៩,៥% | 0,១% | 0,0% |
| ការសិក្សាអប់រំក្រោយមធ្យមសិក្សា | ៩៨,១% | ១,៩% | 0,0% | 0,0% | ១00,0% | 0,0% | 0,0% | 0,0% | ៩៥,៧% | ៤,៣% | 0,0% | 0,0% |
| ទំហំគ្រួសារ | | | | | | | | | | | | |
| ១ ដល់ ៣ | ៨៤,៨% | ១៥,១% | 0,២% | 0,0% | ៨៨,៣% | ១១,២% | 0,៦% | 0,0% | ៨៥,0% | ១៤,២% | 0,៧% | 0,0% |
| ៤ ដល់ ៥ | ៦៩,៣% | ៣0,៥% | 0,៣% | 0,0% | ៧0,៧% | ២៩,0% | 0,២% | 0,១% | ៧៧,៤% | ២២,៣% | 0,៣% | 0,0% |
| ៦+ | ៥១,៩% | ៤៧,៦% | 0,៥% | 0,0% | ៤៧,១% | ៥២,៤% | 0,៦% | 0,0% | ៥៨,២% | ៤១,៤% | 0,៤% | 0,0% |
| គ្រួសារមានប័ណ្ណក្រីក្រ | | | | | | | | | | | | |
| ទេ | ៧៤,0% | ២៥,៩% | 0,១% | 0,0% | ៧៤,៧% | ២៥,0% | 0,២% | 0,0% | ៧៧,៨% | ២១,៩% | 0,៣% | 0,0% |
| បាទ/ចាស | ៤0,៥% | ៥៧,៩% | ១,៦% | 0,0% | ៤៣,១% | ៥៤,៨% | ១,៨% | 0,២% | ៦៨,៤% | ៣0,៧% | 0,៩% | 0,0% |
| គ្រួសារមានសមាជិកមានពិការភាព | | | | | | | | | | | | 0,0% |
| ទេ | | | | | | | | | ៧៧,៨% | ២១,៩% | 0,៤% | 0,0% |
| បាទ/ចាស | | | | | | | | | ៦៤,៣% | ៣៤,៦% | ១,0% | 0,0% |

## ១.២. សមត្ថភាពសេដ្ឋកិច្ចដើម្បីឆ្លើយតបតម្រូវការចាំបាច់

| ចរិកលក្ខណៈជាប្រវត្តិ | អង្កេតសេដ្ឋកិច្ច សង្គមកិច្ច២០១៤ | | | អង្កេតសេដ្ឋកិច្ច សង្គមកិច្ច២០១៥ | | | អង្កេតសេដ្ឋកិច្ច សង្គមកិច្ច២០១៦ | | | អង្កេតសេដ្ឋកិច្ច សង្គមកិច្ច២០១៧ | | | អង្កេតសេដ្ឋកិច្ច សង្គមកិច្ច២០១៩/២០ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ខ្ពស់ជាងបន្ទាត់ភាពក្រីក្រថ្នាក់ជាតិ | ចន្លោះបន្ទាត់ភាពក្រីក្រថ្នាក់ជាតិនិងបន្ទាត់ភាពក្រីក្រស្បៀងអាហារ | ទាបជាងបន្ទាត់ភាពក្រីក្រស្បៀងអាហារ | ខ្ពស់ជាងបន្ទាត់ភាពក្រីក្រថ្នាក់ជាតិ | ចន្លោះបន្ទាត់ភាពក្រីក្រថ្នាក់ជាតិនិងបន្ទាត់ភាពក្រីក្រស្បៀងអាហារ | ទាបជាងបន្ទាត់ភាពក្រីក្រស្បៀងអាហារ | ខ្ពស់ជាងបន្ទាត់ភាពក្រីក្រថ្នាក់ជាតិ | ចន្លោះបន្ទាត់ភាពក្រីក្រថ្នាក់ជាតិនិងបន្ទាត់ភាពក្រីក្រស្បៀងអាហារ | ទាបជាងបន្ទាត់ភាពក្រីក្រស្បៀងអាហារ | ខ្ពស់ជាងបន្ទាត់ភាពក្រីក្រថ្នាក់ជាតិ | ចន្លោះបន្ទាត់ភាពក្រីក្រថ្នាក់ជាតិនិងបន្ទាត់ភាពក្រីក្រស្បៀងអាហារ | ទាបជាងបន្ទាត់ភាពក្រីក្រស្បៀងអាហារ | ខ្ពស់ជាងបន្ទាត់ភាពក្រីក្រថ្នាក់ជាតិ | ចន្លោះបន្ទាត់ភាពក្រីក្រថ្នាក់ជាតិនិងបន្ទាត់ភាពក្រីក្រស្បៀងអាហារ | ទាបជាងបន្ទាត់ភាពក្រីក្រស្បៀងអាហារ |
| កម្ពុជា | ៥0,៧% | ៤៤,0% | ៥,៣% | ៦២,៤% | ៣៦,២% | ១,៤% | ៧0,៩% | ២៨,៣% | 0,៨% | ៧១,៥% | ២៨,0% | 0,៥% | ៧៦,៧% | ២0,៦% | ២,៧% |
| ភូមិសាស្ត្រ/តំបន់ | | | | | | | | | | | | | | | |
| ទីប្រជុំជន | ៦៣,២% | ៣២,៩% | ៣,៩% | ៧៦,៥% | ២២,៩% | 0,៦% | ៨១,៧% | ១៧,៨% | 0,៥% | ៨១,១% | ១៨,៤% | 0,៥% | ៨១,៣% | ១៦,៤% | ២,៣% |
| ជនបទ | ៤៤,៨% | ៤៩,១% | ៦,0% | ៥៧,១% | ៤១,២% | ១,៦% | ៦៦,៤% | ៣២,៧% | 0,៩% | ៦៧,៨% | ៣១,៨% | 0,៥% | ៧១,១% | ២៥,៨% | ៣,១% |
| រាជធានីភ្នំពេញ | ៧៨,0% | ២0,២% | ១,៨% | ៨៤,១% | ១៥,៦% | 0,៣% | ៩១,១% | ៨,៧% | 0,២% | ៨៨,៩% | ១0,៧% | 0,៤% | ៩៣,២% | ៥,៤% | ១,៥% |
| តំបន់ | | | | | | | | | | | | | | | |
| ទំនាបកណ្តាល | ៤៨,៩% | ៤៦,៨% | ៤,៣% | ៦១,១% | ៣៧,១% | ១,៨% | ៧១,៨% | ២៧,៤% | 0,៧% | ៧២,៦% | ២៧,0% | 0,៥% | ៧៥,0% | ២១,៥% | ៣,៥% |
| ខ្ពង់រាប/ភ្នំ | ៤៥,៩% | ៤៨,១% | ៥,៩% | ៥៤,៩% | ៤៣,៣% | ១,៨% | ៦៤,៤% | ៣៤,៦% | ១,0% | ៦៩,៧% | ៣0,២% | 0,២% | ៧២,៦% | ២៥,0% | ២,៥% |
| ទន្លេសាប | ៤៥,៣% | ៤៦,៨% | ៧,៩% | ៥៨,៩% | ៣៩,៩% | ១,២% | ៦៣,៦% | ៣៥,៣% | ១,១% | ៦៤,៨% | ៣៤,៥% | 0,៧% | ៧0,៦% | ២៦,៩% | ២,៥% |
| ឆ្នេរសមុទ្រ | ៤៨,៤% | ៤៧,៣% | ៤,៣% | ៦៣,១% | ៣៦,២% | 0,៧% | ៧៥,៦% | ២៣,៨% | 0,៦% | ៧0,៩% | ២៩,១% | 0,0% | ៨៥,៥% | ១២,១% | ២,៤% |
| រាជធានីភ្នំពេញ | ៧៨,0% | ២0,២% | ១,៨% | ៨៤,១% | ១៥,៦% | 0,៣% | ៩១,១% | ៨,៧% | 0,២% | ៨៨,៩% | ១0,៧% | 0,៤% | ៩៣,២% | ៥,៤% | ១,៥% |
| គ្រួសារដែលមានស្ត្រីជាមេគ្រួសារ | | | | | | | | | | | | | | | |
| បុរស | ៥0,៧% | ៤៤,៥% | ៤,៨% | ៦២,៧% | ៣៦,១% | ១,២% | ៧0,៤% | ២៨,៩% | 0,៧% | ៧១,0% | ២៨,៦% | 0,៤% | ៧៧,៧% | ២0,២% | ២,១% |
| ស្ត្រី | ៥0,៦% | ៤២,៤% | ៧,0% | ៦១,៧% | ៣៦,៦% | ១,៨% | ៧២,៣% | ២៦,៤% | ១,៣% | ៧៣,៤% | ២៥,៩% | 0,៧% | ៧២,៧% | ២២,២% | ៥,0% |
| អាយុរបស់មេគ្រួសារ | | | | | | | | | | | | | | | |
| < ៣0 | ៤៩,0% | ៤៦,២% | ៤,៨% | ៥៨,១% | ៤១,៥% | 0,៤% | ៧0,0% | ៣0,0% | 0,0% | ៧៧,៨% | ២១,៨% | 0,៤% | ៧៩,២% | ១៨,៥% | ២,៣% |

| | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៣០ - ៣៩ | ៤៦,៥% | ៤៨,៥% | ៥,០% | ៥៨,៥% | ៤០,២% | ១,៣% | ៦៧,២% | ៣២,៤% | ០,៤% | ៦៨,១% | ៣១,៥% | ០,៤% | ៧៥,៧% | ២២,៣% | ២,០% |
| ៤០ - ៤៩ | ៥១,៨% | ៤២,៣% | ៥,៩% | ៦៤,៣% | ៣៣,៨% | ១,៩% | ៧១,៥% | ២៧,២% | ១,២% | ៧៣,១% | ២៦,៨% | ០,១% | ៧៩,៥% | ១៨,៤% | ២,១% |
| ៥០ - ៥៩ | ៥៣,៨% | ៤២,២% | ៤,០% | ៦៦,០% | ៣២,៤% | ១,៦% | ៧២,៧% | ២៦,៤% | ០,៨% | ៧០,៥% | ២៩,០% | ០,៥% | ៧៥,៨% | ២១,៨% | ២,៤% |
| ៦០⁺ | ៥១,២% | ៤២,១% | ៦,៦% | ៦១,៥% | ៣៧,៦% | ០,៩% | ៧២,២% | ២៦,៩% | ០,៩% | ៧២,៩% | ២៦,៣% | ០,៨% | ៧៥,០% | ២០,៦% | ៤,៤% |
| **ការអប់រំរបស់មេគ្រួសារ** | | | | | | | | | | | | | | | |
| គ្មាន ឬមានការសិក្សាអប់រំតិចតួច | ៣៥,២% | ៥៤,៤% | ១០,៤% | ៥០,២% | ៤៧,១% | ២,៨% | ៥៨,២% | ៤០,៤% | ១,៥% | ៥៥,៤% | ៤៣,៣% | ១,៤% | ៦១,៩% | ៣៣,២% | ៥,០% |
| មិនបានបញ្ចប់កម្រិតបឋមសិក្សា | ៤៥,៧% | ៤៩,២% | ៥,០% | ៥៧,៧% | ៤០,៦% | ១,៧% | ៦៦,១% | ៣២,៨% | ១,១% | ៦៧,២% | ៣២,៥% | ០,៣% | ៧២,៥% | ២៤,៩% | ២,៦% |
| បានបញ្ចប់កម្រិតបឋមសិក្សា | ៥៤,៥% | ៤១,៩% | ៣,៦% | ៦៥,៩% | ៣៣,៧% | ០,៤% | ៧៤,៥% | ២៥,២% | ០,៣% | ៧៧,៦% | ២២,២% | ០,២% | ៨១,៥% | ១៦,១% | ២,៤% |
| បានបញ្ចប់កម្រិតមធ្យមសិក្សាបឋមភូមិ | ៦៦,៩% | ៣១,៣% | ១,៨% | ៧៨,៤% | ២១,១% | ០,៥% | ៨០,៥% | ១៩,៣% | ០,២% | ៨៤,៥% | ១៥,៣% | ០,២% | ៨៩,៦% | ៩,២% | ១,២% |
| បានបញ្ចប់កម្រិតមធ្យមសិក្សាទុតិយភូមិ | ៨០,៤% | ១៧,៥% | ២,១% | ៨៤,៨% | ១៥,២% | ០,០% | ៩២,២% | ៧,៥% | ០,៣% | ៩០,២% | ៩,៨% | ០,០% | ៩០,៩% | ៧,៧% | ១,៤% |
| ការសិក្សាអប់រំក្រោយមធ្យមសិក្សា | ៩០,៦% | ៨,០% | ១,៤% | ៩៤,៨% | ៥,២% | ០,០% | ៩៨,៧% | ១,៣% | ០,០% | ១០០,០% | ០,០% | ០,០% | ៩៦,៦% | ២,០% | ១,៤% |
| **ទំហំរបស់គ្រួសារ** | | | | | | | | | | | | | | | |
| ១ ដល់ ៣ | ៦៧,៧% | ២៩,៣% | ៣,១% | ៨០,១% | ១៩,៨% | ០,១% | ៨៦,៣% | ១៣,៤% | ០,៣% | ៨៩,៥% | ១០,៣% | ០,១% | ៨៧,០% | ៩,៦% | ៣,៤% |
| ៤ ដល់ ៥ | ៤៩,០% | ៤៦,៣% | ៤,៨% | ៦២,០% | ៣៧,០% | ១,០% | ៦៩,៦% | ៣០,០% | ០,៤% | ៧០,៩% | ២៨,៨% | ០,៣% | ៧៨,២% | ២០,០% | ១,៩% |
| ៦⁺ | ៣៣,០% | ៥៧,៩% | ៩,១% | ៤២,៤% | ៥៤,០% | ៣,៦% | ៥២,៤% | ៤៥,២% | ២,៤% | ៤៧,៣% | ៥១,៣% | ១,៤% | ៥៩,០% | ៣៧,៥% | ៣,៦% |
| **គ្រួសារដែលមានប័ណ្ណក្រីក្រ** | | | | | | | | | | | | | | | |
| ទេ | ៥៣,៤% | ៤២,២% | ៤,៤% | ៦៦,០% | ៣២,៨% | ១,២% | ៧៤,៦% | ២៤,៩% | ០,៥% | ៧៥,១% | ២៤,៥% | ០,៤% | ៧៨,៨% | ១៩,២% | ២,០% |
| បាទ/ចាស⁺ | ២៧,៣% | ៥៩,២% | ១៣,៤% | ៣៧,៩% | ៥៩,២% | ២,៩% | ៤២,២% | ៥៤,៣% | ៣,៥% | ៤៤,៨% | ៥៤,៥% | ០,៧% | ៧០,០% | ២៥,១% | ៤,៨% |
| **គ្រួសារដែលមានសមាជិកមានពិការភាព** | | | | | | | | | | | | | | | |
| ទេ | ៥១,៦% | ៤៣,៦% | ៤,៧% | | | | | | | | | | ៧៨,៨% | ១៩,០% | ២,២% |
| បាទ/ចាស⁺ | ៤៥,០% | ៤៦,៣% | ៨,៧% | | | | | | | | | | ៦៦,១% | ២៨,៨% | ៥,១% |

## ១.៣ ចំណាយ និងការរួមចំណែកនៃចំណាយ

| ចរិកលក្ខណៈជាប្រវត្តិ | អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ២០១៤ | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | ការចំណាយជាមធ្យមលើស្បៀងអាហារ(គិតជារៀល) | ការចំណាយជាមធ្យមលើស្បៀងអាហារប្រចាំខែ (គិតជារៀល) | ការចំណាយជាមធ្យមមិនមែនស្បៀងអាហារប្រចាំខែ(គិតជារៀល) | ការចំណាយជាមធ្យមលើស្បៀងអាហារ(គិតជារៀល) | ការចំណាយជាមធ្យមលើស្បៀងអាហារប្រចាំខែ (គិតជារៀល) | ការចំណាយជាមធ្យមមិនមែនស្បៀងអាហារប្រចាំខែ(គិតជារៀល) | ការចំណាយជាមធ្យមលើស្បៀងអាហារ (គិតជារៀល) | ភាគរយនៃគ្រួសារក្នុងក្រុមការចំណាយលើស្បៀងអាហារ | | | |
| | គ្រួសារ | គ្រួសារ | គ្រួសារ | ក្នុង១ម្នាក់ | ក្នុង១ម្នាក់ | ក្នុង១ម្នាក់ | | ទាប (<៥០%) | មធ្យម (៥០% - <៦៥%) | ខ្ពស់ (៦៥% - <៧៥%) | ខ្ពស់ខ្លាំង (>= ៧៥%) |
| **កម្ពុជា** | **១ ៥៣១ ៣០៥** | **៦៨៩ ៩២០** | **៨៤១ ៣៨៥** | **៣៤៣ ៩០៧** | **១៥៤ ៩០៤** | **១៨៩ ០០៤** | **៥០,២%** | **៤៦,៩%** | **៣៩,៥%** | **១១,២%** | **២,៤%** |
| **ភូមិសាស្ត្រ/តំបន់** | | | | | | | | | | | |
| ទីប្រជុំជន | ១ ៩១០ ៦១៩ | ៨១១ ៨៧០ | ១ ០៩៨ ៧៤៩ | ៤២០ ២៩០ | ១៧៩ ១៣៦ | ២៤១ ១៥៤ | ៤៨,០% | ៥៣,០% | ៣៧,០% | ៨,៧% | ១,៣% |
| ជនបទ | ១ ៣២៧ ៥៣០ | ៦២៣ ៧៥៩ | ៧០៣ ៧៧១ | ២៩៧ ៥៥០ | ១៣៩ ៨១៤ | ១៥៧ ៧៣៦ | ៥១,៤% | ៤២,៨% | ៤១,៦% | ១២,៧% | ២,៨% |
| រាជធានីភ្នំពេញ | ២ ៥៥០ ៥២៥ | ១ ០២២ ០៣១ | ១ ៥២៨ ៤៩៤ | ៥៦៧ ០៥២ | ២២៨ ១៧២ | ៣៣៨ ៨៨០ | ៤៣,៦% | ៦៨,៦% | ២៧,៤% | ៣,៥% | ០,៦% |
| **តំបន់** | | | | | | | | | | | |
| ទំនាបកណ្តាល | ១ ៣៨៩ ៥៦៩ | ៦៦៥ ០០៣ | ៧២៤ ៥៦៥ | ៣២១ ៣១៣ | ១៤៥ ៦០២ | ១៧៥ ៧១១ | ៥២,៦% | ៣៩,១% | ៤៣,១% | ១៣,០% | ៤,៨% |
| ខ្ពង់រាប/ភ្នំ | ១ ៤១០ ៩២៨ | ៦៣៩ ៩៣០ | ៧៧០ ៩៩៧ | ៣០១ ៣៨៣ | ១៤៤ ២៩០ | ១៥៧ ០៩៣ | ៥០,៤% | ៤៦,៣% | ៤០,៤% | ១១,៥% | ១,៨% |
| ទន្លេសាប | ១ ៤០១ ៨៤៩ | ៦៤៣ ៣៤៦ | ៧៥៨ ៥០៣ | ៣១៣ ០២៨ | ១៤៣ ៥៩៩ | ១៦៩ ៤២៩ | ៥០,៧% | ៤៤,៧% | ៤០,៥% | ១២,១% | ២,៧% |
| ឆ្នេរសមុទ្រ | ១ ៣៧១ ១៩៨ | ៦៧៣ ០៩៣ | ៦៩៨ ១០៥ | ៣០៥ ៤៦៦ | ១៥០ ៤០១ | ១៥៥ ០៦៥ | ៥២,៥% | ៣៩,៨% | ៤២,៧% | ១៥,៣% | ២,២% |
| រាជធានីភ្នំពេញ | ២ ៥៥០ ៥២៥ | ១ ០២២ ០៣១ | ១ ៥២៨ ៤៩៤ | ៥៦៧ ០៥២ | ២២៨ ១៧២ | ៣៣៨ ៨៨០ | ៤៣,៦% | ៦៨,៦% | ២៧,៤% | ៣,៥% | ០,៦% |
| **គ្រួសារដែលមានស្ត្រីជាមេគ្រួសារ** | | | | | | | | | | | |
| បុរស | ១ ៦០៨ ៥៨២ | ៧២៣ ៥៩១ | ៨៨៤ ៩៩១ | ៣៤៥ ៣៤៨ | ១៥៥ ៣៦១ | ១៨៩ ៩៨៧ | ៥០,០% | ៤៧,៣% | ៣៩,៦% | ១០,៨% | ២,៣% |
| ស្ត្រី | ១ ២៦១ ៥៨២ | ៥៧២ ៥៥៩ | ៦៨៩ ៤០០ | ៣៣៧ ៦១៧ | ១៥២ ៩០៦ | ១៨៤ ៧១១ | ៥០,៧% | ៤៥,៤% | ៣៩,១% | ១២,៨% | ២,៦% |
| **អាយុរបស់មេគ្រួសារ** | | | | | | | | | | | |
| < ៣០ | ១ ១២៥ ៣៨៤ | ៥៦១ ២៤៧ | ៥៦៤ ១៣៧ | ៣២៦ ៦០៥ | ១៦២ ២៣៩ | ១៦៤ ៣៦៦ | ៥៣,៨% | ៣៥,៥% | ៤៥,១% | ១៥,៣% | ៤,១% |
| ៣០ - ៣៩ | ១ ៤០២ ៩១០ | ៦៧២ ០០៣ | ៧៣០ ៩០៧ | ៣២៣ ១៩៤ | ១៥៤ ៣៥៨ | ១៦៨ ៨៣៥ | ៥១,៨% | ៤០,៥% | ៤៤,២% | ១២,៤% | ២,៩% |
| ៤០ - ៤៩ | ១ ៧០៥ ៧៨១ | ៧៥៥ ៦៥១ | ៩៥០ ១៣០ | ៣៤៥ ៨៣៥ | ១៥៣ ៤៨២ | ១៩២ ៣៥៣ | ៤៩,៦% | ៤៨,៤% | ៣៨,៩% | ១០,៧% | ២,០% |
| ៥០ - ៥៩ | ១ ៧២៨ ៦០២ | ៧៤៣ ៥០៩ | ៩៨៥ ០៩៣ | ៣៦៥ ១០២ | ១៥៧ ០៣៨ | ២០៨ ០៦៣ | ៤៨,២% | ៥៣,៦% | ៣៥,១% | ៩,៨% | ១,៦% |
| ៦០⁺ | ១ ៤៣៤ ០៨១ | ៦៣២ ៦៥៣ | ៨០១ ៤២៨ | ៣៤៥ ៦១៤ | ១៥១ ៩៥៨ | ១៩៣ ៦៥៥ | ៤៩,៧% | ៤៩,៦% | ៣៧,៤% | ១០,៤% | ២,៦% |
| **ការអប់រំរបស់មេគ្រួសារ** | | | | | | | | | | | |
| គ្មានឬមានការសិក្សាអប់រំតិចតួច | ១ ១២០ ៨៤៣ | ៥៧២ ០៧៦ | ៥៤៨ ៧៦៧ | ២៥៧ ៩៣២ | ១៣១ ៦០១ | ១២៦ ៣៣១ | ៥៤,៦% | ៣៤,១% | ៤៣,០% | ១៨,២% | ៤,៧% |
| មិនបានបញ្ចប់កម្រិតបឋមសិក្សា | ១ ៣៨៩ ៨០៥ | ៦៤៦ ១៦៨ | ៧៤៣ ៦៣៧ | ៣០៥ ៨៩៦ | ១៤២ ២៦២ | ១៦៣ ៦៣៥ | ៥០,៧% | ៤៥,២% | ៤១,៧% | ១១,០% | ២,២% |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| បានបញ្ចប់កម្រិតបឋមសិក្សា | ១ ៦១៧ ៨៩៣ | ៧១៩ ៣០៤ | ៨៩៨ ៥៨៩ | ៣៥៦ ៥២៥ | ១៥៨ ៧៦៨ | ១៩៧ ៧៥៧ | ៤៩,២% | ៤៨,៦% | ៤១,០% | ៩,០% | ១,៤% |
| បានបញ្ចប់កម្រិតមធ្យមសិក្សាបឋមភូមិ | ១ ៩៣០ ៤៤៧ | ៨០២ ៧៦៤ | ១ ១២៧ ៦៨៣ | ៤៣៦ ៩៨០ | ១៨១ ៨៩៨ | ២៥៥ ០៨២ | ៤៦,៥% | ៥៩,១% | ៣២,២% | ៧,២% | ១,៥% |
| បានបញ្ចប់កម្រិតមធ្យមសិក្សាទុតិយភូមិ | ២ ២៣២ ០៦៦ | ៨៩៩ ៥៣៤ | ១ ៣៣២ ៥៣២ | ៥០៤ ៤៦៥ | ២០៣ ៥២២ | ៣០០ ៩៤៣ | ៤៤,៦% | ៦៤,០% | ២៩,៤% | ៥,៤% | ១,២% |
| ការសិក្សាអប់រំក្រោយមធ្យមសិក្សា | ៣ ១៦០ ០២៨ | ១ ១៥០ ៨២៥ | ២ ០០៩ ២០៣ | ៧៦៣ ០៦៥ | ២៧៩ ០៨២ | ៤៨៣ ៩៨៣ | ៤០,៣% | ៨០,៨% | ១៧,២% | ២,០% | ០,០% |
| **ទំហំរបស់គ្រួសារ** | | | | | | | | | | | |
| ១ ដល់ ៣ | ១ ១១១ ៨៤៦ | ៥១២ ៦៨៣ | ៥៩៩ ១៦៤ | ៤៤៤ ០៧៧ | ២០៤ ៨៥៣ | ២៣៩ ២២៤ | ៥១,០% | ៤៣,៦% | ៤១,២% | ១២,៥% | ២,៨% |
| ៤ ដល់ ៥ | ១ ៥៩៦ ៣២៩ | ៧០៨ ៨៤៧ | ៨៨៧ ៤៨២ | ៣៥៩ ៧៣៩ | ១៥៩ ៧១៣ | ២០០ ០២៦ | ៤៩,៦% | ៤៨,៥% | ៣៩,៣% | ១០,០% | ២,២% |
| ៦+ | ១ ៩២១ ៨៨៣ | ៨៧០ ៩៧៩ | ១ ០៥០ ៩០៤ | ២៨១ ៦៦៥ | ១២៧ ៥៧២ | ១៥៤ ០៩៣ | ៥០,២% | ៤៧,៨% | ៣៧,៨% | ១២,១% | ២,៣% |
| **គ្រួសារដែលមានប័ណ្ណក្រីក្រ** | | | | | | | | | | | |
